ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ រូបថតធ្វើឱ្យចងចាំអំពីសារមន្ទីរទួលស្លែង

◆ ដំណើរជីវិត អ៊ឹង ស៊ីម៉ូណាទី : ភាពបែកបាក់ ភាពសោកសង្រេង

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៧២ ខែមេសា ឆ្នាំ២០១៤


# មាតិកា


◆រូបថតធ្វើឲ្យចងចាំអំពីសារមន្ទីរទួលស្លែង ........ ១

**ផ្នែកឯកសារ**

◆ យុវជន យុវនារីបដិវត្តន៍អបអរ ........ ៣

◆ អឿន ហៅ បឿន អតីតយុទ្ធជន ........ ៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ដំណើរជីវិត អ៊ឹង ស៊ីម៉ូណារី ........ ១២

◆ នៅតែចង់ដឹងពីរបបខ្មែរក្រហម ........ ២២

◆ ការរត់គេចពីអំពើឃោរឃៅរបស់ខ្មែរក្រហម ........ ៣២

◆ ស្ថានភាពប្រជាជននៅឃុំព្រះរំកិល ........ ៣៨

**ផ្នែកច្បាប់**

◆ ដំណើរវិវឌ្ឍន៍ប្រកបដោយភាពស្មុគស្មាញ ........ ៤១

**វេទិកាពិភាក្សាសាធារណៈ**

◆ សំណួរ-ចម្លើយទាក់ទងទៅនឹងជំងឺផ្លូវចិត្ត........ ៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ប្ដូរឈ្មោះដើម្បីរក្សាជីវិត........ ៥៦

◆ រឿងរ៉ាវរបស់យាយខ្ញុំ........ ៦០

◆ ជីវិតក្នុងរបបខ្មែរក្រហម ........ ៦១




អ្នកភូមិចូលរួមវេទិកាសាធារណៈ នៅស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង




**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នាដៃលេខនេះ :** ហូ ថុនា, លី សុខឃាង, មីន សាណាស់, លឹម ជ័យទ័ត្ត, ការ ស៊ុនបូណាត, អៀង ណារី, យុន មុន្នីរ័ត្ន, សៀ ទី **អ្នកនិពន្ធនិងស្រាវជ្រាវ :** ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ :** នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ :** ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក :** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ :** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ :** ឆេង រ៉េង Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# រូបថតធ្វើឱ្យចងចាំអំពីសារមន្ទីរទួលស្លែង

ក្នុងខែមេសា ឆ្នាំ២០១៤នេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានដាក់តាំងរូបថតធំៗចំនួនពីរផ្ទាំង នៅក្នុងបរិវេណសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ រូបថតទាំងពីរផ្ទាំងនេះត្រូវបានដាក់តាំងក្រោមប្រធានបទ “ការចងចាំនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង” របស់គម្រោងសារមន្ទីរនៃការចងចាំ ។ រូបថតទីមួយ គឺជារូបដែលថតដោយទាហានវៀតណាមកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ នៅពីមុខខ្លោងទ្វារខាងកើតសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងសព្វថ្ងៃ ដោយបង្ហាញអំពីយុទ្ធជន-យុទ្ធនារីខ្មែរនៃរណសិរ្សរំដោះជាតិកម្ពុជាចំនួនប្រាំពីរនាក់ ឈរថតជាមួយនឹងកុមារចំនួនបួននាក់ ដែលត្រូវបានរកឃើញដោយទ័ពរណសិរ្សក្រោយពេលកងទ័ពទាំងនោះចូលដល់អតីតមន្ទីរស-២១ ឬ គុកទួលស្លែង នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ រូបថតនេះត្រូវបានរក្សាទុកក្នុងបណ្ណសាររបស់វៀតណាម តាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ២០០៩ ទើបប្រគល់មកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

កុមារទាំងបួននាក់នៅក្នុងរូបថតនេះគឺជាអ្នករួចរស់រានមានជីវិតពីគុកទួលស្លែងក្រោយពីឪពុកម្ដាយរបស់ខ្លួនត្រូវបានខ្មែរក្រហមសម្លាប់នៅទីនោះ ។ កុមារទាំងនោះ រួមមាន ៖ នង ចាន់ផល ដែលកាលនោះមានអាយុ៧ឆ្នាំ ចំណែកប្អូនប្រុសរបស់ខ្លួនឈ្មោះ នង ចាន់នី អាយុ៥ឆ្នាំ ។ ឪពុករបស់ នង ចាន់ផល និង នង ចាន់នី ត្រូវបានបញ្ជូនទៅមន្ទីរស-២១ មុនពេលកុមារទាំងពីរព្រមទាំងម្ដាយរបស់ខ្លួនត្រូវបានបញ្ជូនទៅទីនោះមុនពេលកងទ័ពរណសិរ្សមកដល់ ។ ម្ដាយរបស់ នង ចាន់ផល ឈ្មោះ មុំ យ៉ុវ




ផ្ទាំងរូបថតទីមួយបង្ហាញពីយុទ្ធជន-យុទ្ធនារីខ្មែរកំពុងបី និងនិយាយជាមួយកុមារនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩

ត្រូវបានបញ្ជូនមកដល់គុកទួលស្លែង នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ គឺមុនការដួលរលំនៃរបបខ្មែរក្រហមចំនួនប្រាំពីរថ្ងៃ ។

នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ទាហានវៀតណាមបានរកឃើញកុមារចំនួនប្រាំនាក់នៅក្នុងបរិវេណគុកទួលស្លែងដែលនៅមានជីវិតនៅឡើយពីរបបខ្មែរក្រហម ក្នុងនោះកុមារចំនួនពីរនាក់មិនត្រូវបានស្គាល់ឈ្មោះទេ ។ កុមារម្នាក់ត្រូវបានទាហានវៀតណាមដាក់ឈ្មោះថា "មករា" ដោយយកឈ្មោះខែ "មករា" ដែលទាហានទាំងនោះបានជួបជាមួយកុមារនោះ ។ ចំណែកក្មេងម្នាក់ទៀតដែលជាទារកនៅឡើយមិនទាន់បានដាក់ឈ្មោះនៅឡើយទេ ។ ក្រោយមក ដោយសារតែសុខភាពរបស់ទារកនោះមានសភាពធ្ងន់ធ្ងរពេក ព្រោះគ្មានអាហារហូបអស់រយៈពេលជាច្រើនថ្ងៃមកហើយ ទារកនោះក៏ស្លាប់ទៅទាំងមិនទាន់មានឈ្មោះផង ។ កុមារម្នាក់ទៀតត្រូវបានស្គាល់ឈ្មោះថា "សុជាតិ" តែសព្វថ្ងៃមិនដឹងថារស់នៅទីណាទេ ។

ផ្ទាំងរូបថតនេះត្រូវបានដាក់នៅវាលធំទូលាយមួយឋិតនៅចន្លោះរវាងអគារ "ក" និងអគារ "ខ" ដែលអាចផ្តល់លទ្ធភាពដល់អ្នកមកទស្សនាសារមន្ទីរអាចមើលបានយ៉ាងងាយស្រួលពេលដើរឆ្លងពីអាគារមួយទៅអាគារមួយទៀត ។

គោលបំណងនៃការតាំងផ្ទាំងរូបថត "ការចងចាំនៃសារមន្ទីរទួលស្លែង" នេះ គឺចង់បង្ហាញថា ក្នុងចំណោមអ្នករួចរស់រានមានជីវិតពីគុកទួលស្លែង ក៏មានកុមារចំនួនប្រាំនាក់ផ្សេងទៀតដែរ ហើយកុមារទាំងនោះមិនសូវមានលើកយកមកនិយាយទេ នៅពេលដែលនិយាយអំពីអ្នករួចរស់ជីវិតពីគុកទួលស្លែង ។ ជាមួយគ្នានេះដែរ រូបថតនេះក៏មានបំណងបង្ហាញដល់សាធារណជនឲ្យបានដឹងថា កុមារប្រៀបដូចជាក្រដាសសស្អាតបរិសុទ្ធមួយដូច្នោះដែរ ហើយការចាប់កុមារមកឃុំឃាំងគឺជាទង្វើដ៏ព្រៃផ្សៃនិងជាបទឧក្រិដ្ឋមួយដែលខ្មែរក្រហមបានប្រព្រឹត្ត ។

ចំណែកផ្ទាំងរូបថតទីពីរបង្ហាញអំពីការធ្វើដំណើរវិលត្រឡប់ទៅកាន់ភូមិកំណើតវិញរបស់ប្រជាជនកម្ពុជាក្រោយរបបខ្មែរក្រហមដួលរលំក្នុងខែមករា ឆ្នាំ១៩៧៩ ។ ប្រជាជនកម្ពុជាទាំងក្មេងទាំងចាស់ដែលបានចាកចេញពីភូមិកំណើតទៅរស់នៅតំបន់ផ្សេងៗទូទាំងប្រទេសអស់រយៈពេលជិតបួនឆ្នាំ បានធ្វើដំណើរត្រឡប់ទៅលំនៅដ្ឋានវិញដើម្បីស្វែងរកគ្រួសារដែលអាចរស់រានមានជីវិត ។ ជាអកុសល ប្រជាជនកម្ពុជាម្នាក់ក្នុងចំណោមបួននាក់បានស្លាប់ក្នុងរបបខ្មែរក្រហមធ្វើឲ្យគ្រប់គ្រួសារនីមួយៗរបស់ប្រជាជនកម្ពុជាបាត់បង់សមាជិកយ៉ាងហោចណាស់ម្នាក់ ។ រូបថត



ផ្ទាំងរូបថតទីពីបង្ហាញពីការវិលត្រឡប់ទៅស្រុកកំណើតវិញ ក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩

នេះបង្ហាញពីក្តីសង្ឃឹមនិងភាពមិនងាយទ្រុឌទ្រោមរបស់ប្រជាជនកម្ពុជា និងចាប់ផ្តើមជីវិតឡើងវិញពីគ្មានធនធានអ្វីទាំងអស់ក្រោយរបបខ្មែរក្រហមដួលរំលំក្នុងខែមករា ឆ្នាំ១៩៧៩ ។

នាអនាគតដ៏ខ្លីខាងមុខ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងដាក់តាំងបង្ហាញរូបថតរបស់អ្នកទោសគុកទួលស្លែងចំនួន១.០០០បន្ថែមទៀត ។ រូបថតពណ៌ខ្មៅ-សទាំងនេះ គឺជារូបថតកម្រដែលសាធារណជនមិនដែលបានឃើញ ដោយសារតែរូបទាំងនេះទើបតែរកឃើញថ្មីដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ការដាក់តាំងរូបនេះគឺដើម្បីឲ្យប្រជាជនកម្ពុជាមានឱកាសស្វែងរកសាច់ញាតិរបស់ខ្លួនដែលបានបាត់បង់ក្នុងរបបខ្មែរក្រហម ។

**ញាណ សុជាតិ**

# យុវជន យុវនារីកម្ពុជាទទួលអំណរខួបឆ្នាំទី២ នៃឯករាជ្យជាតិ ថ្ងៃ១៧ មេសា ដ៏មហាអស្ចារ្យ

*ដកស្រង់ចេញពីទស្សនាវដ្ដី “យុវជនយុវនារីបដិវត្តន៍” លេខ៤ មេសា ឆ្នាំ១៩៧៧ ឯកសារលេខ D២១៨០០*

ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ សម្រាប់ប្រជាជនកម្ពុជាដែលធ្លាប់បានរស់នៅ និងរួចជីវិតពីរបបខ្មែរក្រហម គឺជាថ្ងៃចាប់ផ្ដើមនៃប្រវត្តិសាស្ត្រថ្មីដ៏ជូរចត់សម្រាប់ប្រជាជាតិទាំងមូល ។ សំឡេងហ៊ោកញ្ជ្រៀវ ស្រែកជ័យឃោស អបអរសាទរដល់កងទ័ពរំដោះខ្មែរក្រហមប្រកបដោយក្ដីរីករាយ ព្រោះម្នាក់ៗសង្ឃឹមថា ប្រទេសមានសុខសន្តិភាពឡើងវិញ លាន់កងរំពងពេញទីក្រុង ។ មិនយូរប៉ុន្មាន សំឡេងដ៏រីករាយមួយនេះ ក្លាយទៅជាសំឡេងនៃទុក្ខសោក ម្ដាយយំស្រែកហៅរកកូន សំឡេងហៅរកគ្រួសារដោយក្ដីភ័យខ្លាច សំឡេងស្រែកថ្ងូររបស់អ្នកជំងឺដែលត្រូវបង្ខំឲ្យចេញពីមន្ទីរពេទ្យ បន្ទាប់ពីយោធាខ្មែរក្រហម បង្ខំឲ្យប្រជាជនចាកចេញពីលំនៅដ្ឋានជាបន្ទាន់ ចំនួនបីថ្ងៃដោយគ្មានការលើកលែងចំពោះនរណាម្នាក់ឡើយ អ្នកដែលជំទាស់នឹងត្រូវបាញ់សម្លាប់ភ្លាមៗ ក្រោមហេតុផលថា បោសសម្អាតខ្មាំងនិងខ្លាចអាមេរិកាំងមកទម្លាក់គ្រាប់បែក ។ គ្រួសារជាច្រើនបានបែកគ្នាចាប់តាំងពីថ្ងៃ ១៧ មេសា នោះមក ហេតុនេះ ថ្ងៃ ១៧មេសា សម្រាប់ប្រជាជនកម្ពុជា គឺជាថ្ងៃចាប់ផ្ដើមនៃការព្រាត់ប្រាសគ្រួសារ ញាតិមិត្ត និងជាថ្ងៃដែលប្រជាជនខ្មែរទាំងអស់ធ្លាក់ទៅក្នុងស្ថាននរកទាំងរស់ អស់រយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ។

ប៉ុន្តែសម្រាប់ខ្មែរក្រហមវិញ បានចាត់ទុក ថ្ងៃ១៧ មេសា



ពិធីអបអរខួបទី៣ នៃមហាជ័យជម្នះ ១៧មេសា នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៧ នៅស្តាតអូឡាំពិក

ឆ្នាំ១៩៧៥ គឺជាថ្ងៃមហាអស្ចារ្យនៃកងទ័ពបដិវត្តន៍កម្ពុជា ដែលបានរំដោះប្រទេសចេញពីនឹមត្រួតត្រារបស់ចក្រពត្តិ វណ្ណៈសក្តិភូមិ និង ពួកនាយទុន ។ ខ្មែរក្រហមចាត់ទុកថ្ងៃនេះ ជាថ្ងៃទទួលបាននូវឯករាជ្យជាតិពេញលេញ និងជាថ្ងៃដែលសកលលោកដឹងព្វថា កងទ័ពបដិវត្តន៍កម្ពុជាបានទទួលជ័យជម្នះជាប្រវត្តិសាស្ត្រ លើកងទ័ពចក្រពត្តិអាមេរិក ។ ពិសេស គឺរំដោះប្រជាជន កម្មករ កសិករក្រីក្រទាំងអស់ រួចផុតពីការជិះជាន់ សង្កត់សង្កិន មើលងាយ មើលថោក ពីចក្រពត្តិអាណានិគម ពីវណ្ណៈសក្តិភូមិ នាយទុន ប្រតិកិរិយាទាំងអស់ និងជាស្ថាពរ ។ ខាងក្រោមនេះ ជាអត្ថបទដកស្រង់ចេញពីទស្សនាវដ្តី «យុវជន យុវនារីបដិវត្តន៍» លេខ៤ ខែមេសា ឆ្នាំ១៩៧៧ ដែលទាក់ទងទៅនឹងខ្លឹមសារនៃថ្ងៃ ១៧មេសា ឆ្នាំ១៩៧៥ តើថ្ងៃនេះមានអត្ថន័យ យ៉ាងណាខ្លះ សម្រាប់កម្ពុជាប្រជាធិបតេយ្យ?

នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៧នេះ យុវជន-យុវនារីកម្ពុជាទូទាំងប្រទេស បានធ្វើបុណ្យទទួលអំណរខួបឆ្នាំទី២ នៃថ្ងៃឯករាជ្យជាតិ ក្នុងបរិយាកាសមហាសាមគ្គី សកម្មប្រយុទ្ធក្លៀវក្លា និង ដោយក្តីរំភើបរីករាយឥតឧបមា ។

ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលយើងបញ្ចប់នូវបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដោយជោគជ័យ ហើយឈានចូលដំណាក់កាលថ្មី នៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម នៅកម្ពុជាប្រជាធិបតេយ្យយើង តទៅទៀត ។ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលប្រទេសជាតិ មាតុភូមិជាទីស្នេហាត្រូវបានរំដោះទាំងមូល ទាំងស្រុង និងជាស្ថាពរ ជាថ្ងៃដែលប្រជាជនកម្ពុជា យុវជន យុវនារីកម្ពុជា ពិសេសប្រជាជនកម្មករ ពលករ និងកសិករក្រីក្រទាំងអស់ ត្រូវបានរំដោះរួចផុតពីការជិះជាន់ សង្កត់សង្កិន មើលងាយ មើលថោក គ្រប់បែបយ៉ាងរបស់ចក្រពត្តិអាណានិគមនិយម ទាំងចាស់ ទាំងថ្មី និងរបស់វណ្ណៈសក្តិភូមិ វណ្ណៈនាយទុន ឃោរឃៅប្រតិកិរិយាបានទាំងស្រុង និងជាស្ថាពរ ។ ដូច្នេះ ថ្ងៃ១៧ មេសា ជាថ្ងៃមហាជោគជ័យ មានអត្ថន័យជាប្រវត្តិសាស្ត្រធំធេងណាស់ ចំពោះប្រជាជន យុវជន យុវនារីកម្ពុជាយើង ក៏ដូចចំពោះប្រជាជនសកលលោក ដែលស្នេហាឯករាជ្យ និងយុត្តិធម៌ដែរ ។

ដូច្នេះ យុវជន យុវនារីកម្ពុជាយើង រួមជាមួយប្រជាជនកម្មករ កសិករសមូហភាពទូទាំងប្រទេស និងកងទ័ពបដិវត្តន៍កម្ពុជាយើងទាំងមូល ធ្វើបុណ្យខួបឆ្នាំទី២ រំឭកថ្ងៃឯករាជ្យជាតិ ១៧មេសា ដ៏មហាអស្ចារ្យនេះ មួយ៉ាងគឺ ដើម្បីគោរពវិញ្ញាណក្ខន្ធរបស់វីរជន វីរនារីបដិវត្តន៍យើង របស់ប្រជាជន កម្មករ កសិករយើង ដែលបានពលីក្នុងការតស៊ូដ៏តឹងតែង ស្វិតស្វាញកន្លងមក ដើម្បីបុព្វហេតុរំដោះប្រទេសជាតិ រំដោះប្រជាជន និងរំដោះវណ្ណៈក្រីក្រកម្ពុជាយើង ។ តែមួយ៉ាងទៀតក៏ដើម្បីរៀនសូត្រ នូវមូលហេតុនៃមហាជ័យជម្នះ ១៧មេសា រៀនសូត្រនូវអត្ថន័យនៃមហាជ័យជម្នះនេះ ហើយជាពិសេស គឺរៀនសូត្រអំពីគោលជំហរ វីរភាពបដិវត្តន៍ដ៏ខ្ពង់ខ្ពស់អស្ចារ្យរបស់វីរជន វីរនារី និងប្រជាជន កម្មករ កសិករយើងកន្លងមក ដើម្បីជំរុញសន្ទុះនៃកិច្ចការពារប្រទេស និងកសាងប្រទេស ក្នុងរយៈកាលថ្មី នៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមបច្ចុប្បន្ននេះ និងតទៅអនាគតទៀត ឲ្យកាន់តែមហាលោតផ្លោះមហាអស្ចារ្យឡើងថែមទៀត ។

ក្នុងឱកាសបុណ្យខួបឆ្នាំទី២ នៃថ្ងៃឯករាជ្យជាតិ ១៧មេសា ដ៏មហាអស្ចារ្យនេះ យុវជន យុវនារីកម្ពុជាយើង ចងចាំមិនភ្លេចនូវមូលហេតុសំខាន់ៗ ដែលជាកត្តាកំណត់នាំឲ្យយើងដណ្តើមបានមហាជោគជ័យ ជាប្រវត្តិសាស្ត្រ កាលពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ កន្លងទៅនេះ ។ យុវជន យុវនារីកម្ពុជាយើង ចងចាំមិនភ្លេច ហើយរៀនសូត្រអំពីមូលហេតុ នៃជ័យជម្នះទុកធ្វើជាមេរៀនជារៀងរហូត ក្នុងកិច្ចកសាងប្រទេស និងការពារប្រទេសបច្ចុប្បន្ននេះ ក៏ដូចតទៅអនាគតទៀត ។

◆ **មូលហេតុសំខាន់ៗទី១** នៃមហាជ័យជម្នះជាប្រវត្តិសាស្ត្រ ១៧មេសា ដ៏មហាអស្ចារ្យនេះ គឺមកពីមានបក្សកុម្មុយនីស្តកម្ពុជាត្រឹមត្រូវ ភ្លឺស្វាង ដឹកនាំមាគ៌ានយោបាយ មាគ៌ាសតិអារម្មណ៍ និងមាគ៌ាចាត់តាំងត្រឹមត្រូវ ។ បើគ្មានបក្សកុម្មុយនីស្តកម្ពុជាមួយត្រឹមត្រូវ ភ្លឺស្វាង ដឹកនាំតាមមាគ៌ាគ្រប់ផ្នែកត្រឹមត្រូវដូច្នេះទេ នោះយើងពុំអាចដណ្តើមបានមហាជ័យជម្នះ ១៧មេសា ដ៏មហាអស្ចារ្យនេះបានឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ចលនាបដិវត្តន៍កម្ពុជាយើងអាចនឹងជួបឧបសគ្គ ជួបការលំបាក ឬ រហូតដល់ទៅបរាជ័យរលំរលាយទៀតផង ។ ដូច្នេះ ប្រទេសជាតិកម្ពុជា ប្រជាជនកម្ពុជា យុវជន យុវនារីកម្ពុជា អាចត្រូវភ្លើងសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវារ បំផ្លិចបំផ្លាញ និង ដុតកម្ទេចវិនាសហិនហោច

ខ្មោចផង្សា យូរអង្វែងតទៅទៀត ឬក៏ត្រូវធ្លាក់ខ្លួនទៅជាខ្ញុំ កញ្ជះចក្រពត្តិនិយម អាណានិគមនិយមបរទេស កាន់តែធ្ងន់ធ្ងរថែមទៀត ។ ឃើញយ៉ាងនេះ យុវជន យុវនារី បដិវត្តន៍យើង ប្ដេជ្ញាលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ច ដើម្បីការពារបក្ស ការពារមាគ៌ាដ៏ត្រឹមត្រូវ ល្អបរិសុទ្ធរបស់បក្សគ្រប់ផ្នែក ឲ្យបានគង់វង្ស ស្ថិតស្ថេរជារៀងរហូត និងកាន់តែរឹងប៉ឹងខ្លាំងក្លាឡើងថែមទៀត ដើម្បីបន្តដឹកនាំបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាដណ្ដើមមហាជ័យជម្នះធំៗថ្មីទៀតជានិច្ច ។ យើងជឿជាក់ថា ឲ្យតែមានបក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យដឹកនាំ យើងប្រាកដជានឹងដណ្ដើមបានជ័យជម្នះធំៗ ។ ថ្មីទៀតជាបន្តបន្ទាប់ រហូតដល់សម្រេចបដិវត្តន៍សង្គមនិយម បានជាស្ថាពរ ហើយឈានទៅបដិវត្តន៍កុម្មុយនីស្តនិយមជាបន្តទៀត ។

◆ **មូលហេតុសំខាន់ទី២** គឺមកពីប្រជាជនកម្ពុជា កសិករក្រីក្រយើង ជាប្រជាជនអង់អាចក្លាហាន មហិមាណាស់ ដើម្បីបុព្វហេតុបដិវត្តន៍ ដើម្បីរំដោះជាតិមាតុភូមិជាទីស្នេហា និងដើម្បីវាយឈ្នះខ្មាំងសត្រូវគ្រប់ប្រភេទ ទាំងចក្រពត្តិអាមេរិក បរិវារ ទាំងពួកក្បត់ដែលជាឆ្កែបម្រើរបស់វា ទាំង វណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុន ដែលជាវណ្ណៈជិះជាន់មានឫសគល់នៅក្នុងសង្គមជាតិយើង ជាង ២០០០ ឆ្នាំមកហើយ ប្រជាជនកម្ពុជាយើង បានធ្វើពលិកម្មសព្វបែបយ៉ាង លះបង់មនោសញ្ចេតនា លះបង់ទ្រព្យសម្បត្តិ ស្បៀងអាហារផ្ទាល់ខ្លួន រហូតដល់លះបង់អាយុជីវិត សាច់ឈាម ខ្លួនប្រាណទៀត ដោយគ្មានស្ដាយស្រណោះ ជំពាក់ជំពិនអ្វីឡើយ ។ ក្រៅពីនេះ ប្រជាជនយើងនៅបានប្រយុទ្ធបង្កបង្កើនផល ទាំងថ្ងៃទាំងយប់ ទាំងប្រាំងទាំងវស្សា ហាលភ្លៀង ហាលខ្យល់ ហាលថ្ងៃ នៅក្រោមគ្រាប់បែក និងគ្រាប់កាំភ្លើងតូច ធំ របស់ខ្មាំងយ៉ាងអង់អាចក្លាហាន ដើម្បីមានស្បៀងឧបត្ថម្ភខ្លួន និងឧបត្ថម្ភសមរភូមិមុខដោយឯករាជ្យ ម្ចាស់ការ ។ ប្រជាជនកម្ពុជាយើង អង់អាចក្លាហានណាស់ មហិមាណាស់ ។ ដូច្នេះហើយ បានជាយើងអាចដណ្ដើមបានមហាជ័យជម្នះ ១៧មេសា ដ៏មហាអស្ចារ្យ ។ ប្រជាជនដែលមានការភ្ញាក់រឭកនយោបាយខ្ពស់យ៉ាងនេះ មានកំហឹងជាតិ និងកំហឹងវណ្ណៈឆេះសន្ធោសន្ធៅជាប់ជានិច្ចយ៉ាងនេះ មានវីរភាពអស់អាចក្លាហានខ្ពង់ខ្ពស់យ៉ាងនេះ ជាកម្លាំងខ្លាំងក្លាមហិមាណាស់ ដែលគ្មានខ្មាំងសត្រូវណា គ្មានអាវុធយុទ្ធភណ្ឌ ឬកាំភ្លើងតូចធំណា អាចសម្លុត ឬជម្នះបានឡើយ ។ ប្រជាជនកម្ពុជាយើងនេះ ដែលហ៊ានលះបង់អ្វីៗទាំងអស់ ដើម្បីបដិវត្តន៍ ហើយដែលធ្លាប់ប្រយុទ្ធវាយឈ្នះចក្រពត្តិអាមេរិក ដែលជាមេក្លោងចក្រពត្តិធំជាងគេ នៅលើសកលលោក អាចធ្វើអ្វីក៏បាន អាចវាយខ្មាំងសត្រូវឈ្លានពានណាក៏ឈ្នះ ។


ប៉ុល ពត ថ្លែងសុន្ទរកថានៅស្ដាតអូឡាំពិក

ឧទាហរណ៍ ក្រោយពេលរំដោះប្រទេសជាតិមាតុភូមិ បានទាំងស្រុង និងជាស្ថាពរហើយ ប្រជាជនកម្មករ កសិករសមូហភាពយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តយើងមានតែបាតដៃទទេ បានប្រយុទ្ធស្ដារសេដ្ឋកិច្ច កសាងប្រទេសយ៉ាងសកម្មក្លៀវក្លាជាបន្តទៀត ។ មកដល់បច្ចុប្បន្ននេះ យើងបានដោះស្រាយបញ្ហាស្បៀង ដែលជាបញ្ហាមួយលំបាកធ្ងន់ធ្ងរបំផុតរបស់ប្រជាជនសកលលោក ហើយជាពិសេស របស់ប្រទេសដែលទើបចេញផុតពីសង្គ្រាមវិនាសកម្ម ដូចកម្ពុជាយើងនេះ បានជោគជ័យ និងដោយឯករាជ្យ ម្ចាស់ការទាំងស្រុង ។ មិនត្រឹមតែប៉ុណ្ណោះ ប្រជាជនយើងនៅបានប្រយុទ្ធលើកភ្លឺ ជីកប្រឡាយ លើកទំនប់ ធ្វើអាងទឹក ជីកព្រែក ខ្ទាត់ខ្ទេងជាក្រឡាឈើត្រង់ ដោះស្រាយបញ្ហា

ទឹកបង្កបង្កើនផល សម្រេចជោគជ័យជាបន្តបន្ទាប់ នៅពាសពេញជនបទកម្ពុជា ។ ក្នុងរយៈតែពីរឆ្នាំប៉ុណ្ណោះ ជនបទកម្ពុជាយើងទាំងមូល បានផ្លាស់ប្តូរមុខមាត់ថ្មីសន្ធាង ពុំធ្លាប់ដែលមានទេ ក្នុងប្រវត្តិសាស្ត្រកម្ពុជាយើង ជាង២០០០ឆ្នាំមកហើយ ។ ឧទាហរណ៍ជាក់ស្តែងនេះ បញ្ជាក់យ៉ាងច្បាស់លាស់ថា ប្រជាជនកម្ពុជាមហិមាណាស់ វាយខ្មាំងសត្រូវណាក៏ឈ្នះ កសាងអ្វីក៏កើត ។ ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើង ប្តេជ្ញាបំពាក់បំប៉នឲ្យខ្លួន នូវមាគ៌ាមហាជន និងទស្សនៈមហាជន ជឿជាក់លើប្រជាជនកម្ពុជាយើង ពឹងផ្អែកលើប្រជាជនកម្ពុជាយើង ក្នុងគ្រប់ភារកិច្ចបដិវត្តន៍ តូច ធំ ក៏ដូចក្នុងគ្រប់ដំណាក់កាលថ្មីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាបច្ចុប្បន្ន និងតទៅអនាគតទៀត ។ យុវជន យុវនារីបដិវត្តន៍យើងមានមោទកភាពខ្ពង់ខ្ពស់ក្រៃលែង ចំពោះប្រជាជនខ្លួន ហើយប្តេជ្ញាគោរពស្រឡាញ់ និងបម្រើប្រជាជនពិសេស ប្រជាជនកម្មករ កសិករសម្ពូហភាពយើង ដោយស្មោះត្រង់អស់ពីចិត្ត ពីថ្លើម គ្រប់ពេលវេលា ជារៀងរហូតទៅ ។ ប្តេជ្ញាការពារផលប្រយោជន៍ប្រជាជន កម្មករ កសិករសម្ពូហភាព ប្តេជ្ញាដោះស្រាយកែប្រែ និងលើកស្ទួយជីវភាពប្រជាជន កម្មករ កសិករសម្ពូហភាពយើងឲ្យចម្រើនធូរធារ ឈានទៅសម្បូរសប្បាយជាច់ខាត ។

◆ **មូលហេតុទី៣** គឺមកពីមានកងទ័ពបដិវត្តន៍កម្ពុជាដ៏អង់អាចក្លាហាន និងខ្លាំងពូកែមហាអស្ចារ្យ កងទ័ពនេះ ជាកងទ័ពកូនចៅប្រជាជន កម្មករ កសិករក្រីក្រ មានការភ្ញាក់រឭកបដិវត្តន៍ខ្ពស់ មានគោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំងបដិវត្តន៍រឹងប៉ឹង ហើយស្ថិតនៅក្រោមការដឹកនាំផ្ទាល់ នៃបក្សកុម្មុយនីស្តកម្ពុជាយើង ។ ដូច្នេះកងទ័ពនេះ ជាឧបករណ៍ផ្តាច់ការដ៏ស្មោះត្រង់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា និងវណ្ណៈអធន ។ កងទ័ពនេះ ខ្លាំងក្លាណាស់ ធ្លាប់បានវាយឈ្នះចក្រពត្តិអាមេរិក និង បរិវារ ដូច្នេះ អាចវាយឈ្នះខ្មាំងសត្រូវតូច ធំ ជិតឆ្ងាយណាទាំងអស់ ឲ្យតែហ៊ានឈ្លានពានទឹកដីកម្ពុជាយើងបច្ចុប្បន្ននេះ ក៏ដូចតទៅអនាគតទៀតដែរ ។ យុវជន យុវនារីបដិវត្តន៍យើង ប្តេជ្ញារៀនសូត្រនូវគំរូវីរភាព គំរូលះបង់ គំរូប្រយុទ្ធស្រួចស្រាវជាច់ខាត និងគំរូស្មោះត្រង់ដោយឥតលក្ខខណ្ឌ ចំពោះបក្សរបស់កងទ័ពបដិវត្តន៍កម្ពុជាយើងជារៀងរហូត ដើម្បីធ្វើជាអ្នកបន្តវេនបដិវត្តន៍រឹងប៉ឹង និងក្រហមឆ្អិនឆ្អៅតរៀងទៅ ។



យុទ្ធជន-យុទ្ធនារី ចូលរួមពិធីអបអរខួបជ័យជម្នះលើកទី៣ នៅស្តាតអូឡាំពិក

◆ **មូលហេតុសំខាន់ទី៤** គឺមកពីគោលជំហរប្រយុទ្ធស្រួចស្រាវ គ្មានរាថយ គ្មានសម្រុះសម្រួល គ្មានស៊ុមគ្រលំជាមួយខ្មាំងសត្រូវណាដាច់ខាត ។ ពោល គឺជាជំហរដាច់ខាតវាយសម្រុកទៅលើខ្មាំងគ្រប់ពេលវេលា ដាច់ខាតយកឈ្នះខ្មាំងសត្រូវគ្រប់ប្រភេទ និងដាច់ខាតជម្នះការលំបាកវេទនា សព្វបែបយ៉ាង ពុះពារឧបសគ្គតូច ធំ ជាបន្តបន្ទាប់ ។ ក្នុងរយៈកាលនៃការតស៊ូបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ជាបន្តបន្ទាប់កន្លងមក បើសិនជាយើងគ្មានគោលជំហរដាច់ខាតវាយយ៉ាងនេះទេ យើងប្រាកដជាពុំអាចដណ្ដើមមហាជ័យជម្នះថ្ងៃ ១៧មេសានេះ បានឡើយ ។

ឧទាហរណ៍ ដើមឆ្នាំ១៩៦៨ យើងមានតែបាតដៃទទេតែយើងហ៊ានតស៊ូអាវុធរួមផ្សំនយោបាយ ដើម្បីការពារមូលដ្ឋានបង្អែកបដិវត្តន៍ ការពារកម្លាំងបដិវត្តន៍ មិនឲ្យខ្មាំងបង្ក្រាបវាតត្បាត ឬបំផ្លិចបំផ្លាញបានជាដាច់ខាត ។ បើមិនដូច្នេះទេ ចលនាបដិវត្តន៍យើងប្រាកដជានឹងត្រូវវិនាសហិនហោច រលំរលាយតាំងពីពេលនោះមកម្ល៉េះ ។

ឧទាហរណ៍មួយទៀត នៅពេលផ្ទុះរដ្ឋប្រហារ ១៨ មីនា ១៩៧០ភ្លាម បក្សបានដឹកនាំប្រជាជនកម្ពុជា ធ្វើសង្រ្គាមប្រជាជនវាយកម្ទេចសង្រ្គាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវារភ្លាមដែរ ដើម្បីស្រោចស្រង់ប្រទេសជាតិ ដណ្ដើមឯករាជ្យ និងអធិបតេយ្យភាពជាតិមកវិញដាច់ខាត ទោះបីយើងនៅខ្វះខាតសព្វគ្រប់បែបយ៉ាងណាក្តី ។ បើមិនដូច្នេះទេ នោះប្រាកដជាមាតុភូមិកម្ពុជា យើងនឹងធ្លាក់ទៅជាអាណានិគម និងជាមូលដ្ឋានយោធារបស់ចក្រពត្តិអាមេរិក នៅពេលនោះស្រេចទៅហើយ ។ ប្រជាជនកម្ពុជាយើងប្រាកដជានឹងធ្លាក់ខ្លួនទៅជាខ្ញុំកញ្ជះចក្រពត្តិបរទេសច្រើនជាន់ ច្រើនត្រួត គ្មានពេលណានឹងរើខ្លួនរួចវិញឡើយ ។

ឧទាហរណ៍មួយទៀត នៅដើមឆ្នាំ១៩៧៣ ដែលសកលលោកទាំងមូល ធ្វើការចរចាសម្រុះសម្រួលជាមួយចក្រពត្តិអាមេរិក ហើយសង្កត់យើងចរចាសម្រុះសម្រួលជាមួយចក្រពត្តិអាមេរិកដែរ នៅពេលដែលចក្រពត្តិអាមេរិក ប្រមូលយន្តហោះ យុទ្ធសាស្ត្រយុទ្ធវិធីគ្រប់ធុនរបស់វាទាំងអស់ ប៉ុនប៉ងមកវាយកម្ទេចប្រទេសជាតិយើង ប្រជាជនយើង និងចលនាបដិវត្តន៍កម្ពុជាយើង ក៏យើងទាំងអស់គ្នាបានឯកភាពគ្នាជាធ្លុងមួយ ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងភ្លឺស្វាង នៃបក្សកុម្មុយនីស្តកម្ពុជា យើងដាច់ខាតបន្តធ្វើការប្រយុទ្ធយ៉ាងអង់អាចក្លាហានតែម្នាក់ឯងតទៅទៀត ដោយគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទុកខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនពេញទី ។ ដូច្នេះហើយ បានជាយើងមិនស្លាប់ ។ យើងមិនត្រឹមតែមិនត្រូវរលំរលាយ តែយើងនៅបានវាយបំបាក់សង្រ្គាមអាកាសដ៏មហាឃោរឃៅរបស់ចក្រពត្តិអាមេរិក ដោយជោគជ័យទៀត ធ្វើឲ្យអត្តភាព និងកិត្យានុភាពនៃប្រទេសយើង នៃប្រជាជនកម្ពុជាយើង នៃចលនាបដិវត្តន៍កម្ពុជាយើង នៃបក្សកុម្មុយនីស្តកម្ពុជាយើង ដែលធ្លាប់តែត្រូវគេវាយពន្លិច បន្ទុះបន្ទាប់ ប្រមាថ មើលងាយយូរមកហើយនោះ លេចឡើងខ្ពស់ត្រដែតត្រដឹមល្បីរន្ទឺខ្ទរខ្ទារ ពេញទាំងសកលលោក ។ យើងរក្សាជំហរដាច់ខាតប្រយុទ្ធ ដាច់ខាតវាយកម្ទេចខ្មាំង សត្រូវណាដែលហ៊ានឈ្លានពានទឹកដីយើងជារៀងរហូត រហូតដល់សម្រេចបានមហាជ័យជម្នះ ១៧មេសាដ៏មហាអស្ចារ្យនេះបានជាស្ថាពរ ។

ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើងប្ដេជ្ញាបន្តប្រពៃណី ហើយពង្រឹងពង្រីកជំហរប្រយុទ្ធដាច់ខាតនេះ ឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លាតទៅទៀត ដើម្បីវាយសម្រុកសម្រេចភារកិច្ចបដិវត្តន៍ថ្មី រួមចំណែកធ្វើ បដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសឲ្យល្អប្រសើរខ្លាំងក្លា និងលឿនលោតផ្លោះតទៅទៀត ។ ក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម បច្ចុប្បន្ននិងតទៅអនាគតទៀត ទោះបីត្រូវជួបឧបសគ្គ តូច ធំ យ៉ាងណាក្តី ត្រូវឆ្លងកាត់ការលំបាកវេទនាយ៉ាងណាក្តី ខ្វះសព្វខ្វះគ្រប់យ៉ាងណាក្តី ឬសម្បូរធូរធារវិញយ៉ាងណាក្តី យុវជនយុវនារីបដិវត្តន៍យើង ក៏មិនភ្លេចនូវគោលជំហរប្រយុទ្ធដាច់ខាតនេះ ជារៀងរហូត ។ ឲ្យតែដាច់ខាតប្រយុទ្ធ ដាច់ខាតវាយ ដាច់ខាតធ្វើ យើងប្រាកដជាជម្នះអ្វីៗទាំងអស់បាន យើងប្រាកដជានឹងអាចធ្វើ អាចកសាងអ្វីៗទាំងអស់ដែលគ្មានឲ្យមាន ។ យើងនឹងអាចកសាងកម្ពុជាប្រជាធិបតេយ្យយើងឲ្យខ្លាំងពូកែ ថ្កុំថ្កើងរុងរឿង និងសម្បូរសប្បាយយ៉ាងពិតប្រាកដ ។

ទាំងអស់នេះហើយ ជាមូលហេតុសំខាន់ៗ ដែលជាកត្តាកំណត់នាំឲ្យយើងដណ្ដើមបានមហាជ័យជម្នះ ១៧មេសា ដ៏មហាអស្ចារ្យកន្លងទៅនេះ ។ មហាជ័យជម្នះជាប្រវត្តិសាស្ត្រនេះ មានអត្ថន័យ

ជ្រាលជ្រៅណាស់ ចំពោះប្រជាជនកម្ពុជា យុវជន យុវនារីកម្ពុជាយើង ដោយមយ៉ាង យើងបានវាយបណ្តេញចក្រពត្តិអាមេរិក និងចក្រពត្តិផ្សេងទៀតទាំងអស់ ដែលទន្ទ្រានឈ្លានពានកម្ពុជាយើងតាមគ្រប់រូបភាព ឲ្យវិនាសខ្ទាត់ខ្ទាយ ចេញអស់ពីទឹកដីកម្ពុជាយើងជាស្ថាពរ ហើយដណ្តើមបាននូវព្រលឹងជាតិ ដែលត្រូវបាត់បង់ខ្ទាត់ខ្ទាយ អស់រលីងរាប់សតវត្សរ៍មកហើយ ហើយប្រមូលផ្តុំបាននូវអត្តភាពជាតិ ទាំងមូលបានមកវិញ ។ ម្យ៉ាងទៀត តាមរយៈនៃមហាជ័យជម្នះ ១៧មេសា ឆ្នាំ១៩៧៥ កន្លងទៅនេះ យើងបានវាយរំលំវណ្ណៈសក្តិភូមិ ម្ចាស់ដី វាយរំលំវណ្ណៈនាយទុន និងវាយរំលំរបបឯកជន ដែលចាក់ឫសជ្រៅទៅក្នុងសង្គមជាតិយើង ជាង ២.០០០ឆ្នាំមកហើយ ឲ្យរលំរលាយអស់ជាមូលដ្ឋាន ។ នេះជាមហាជ័យជម្នះធំធេងណាស់របស់ប្រជាជនកម្ពុជា យុវជន យុវនារីកម្ពុជាយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា ដែលពុំធ្លាប់មានទេ ក្នុងប្រវត្តិសាស្ត្រកម្ពុជាជាង ២.០០០ឆ្នាំមកហើយ ។ ដូច្នេះហើយ បានជាយើងកំណត់ហៅថាជាមហាជ័យជម្នះក្រឡាប់ចាក់ ដែលធ្វើឲ្យប្រទេសកម្ពុជាយើង សង្គមជាតិកម្ពុជាយើងទាំងមូល មានការប្រែប្រួលក្រឡាប់ចាក់ ថ្មីសន្លាងទាំងអស់ ធ្វើឲ្យប្រជាជន កម្មករ កសិករក្រីក្រកម្ពុជាយើង ដែលធ្លាប់តែត្រូវគេជិះជាន់ មើលងាយ មើលថោក ដូចសត្វធាតុ បានឡើងមកជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ ម្ចាស់ស្រែចម្ការរបស់ខ្លួន និងម្ចាស់លើជោគវាសនារបស់ខ្លួនពេញទី មានសិទ្ធិគ្រប់គ្រង និងចាត់ចែងកិច្ចការតូច ធំ សព្វសារពើ ដើម្បីការពារប្រទេស និងកសាងប្រទេសរបស់ខ្លួនឲ្យចម្រើនលូតលាស់ លោតផ្លោះទៅមុខឥតឈប់ឈរ សមស្របទៅតាមផលប្រយោជន៍ និងសំណូមពរដ៏ពិសិដ្ឋរបស់ខ្លួន ។ ព្រមជាមួយនេះ មហាជ័យជម្នះ ១៧មេសា ដ៏មហាអស្ចារ្យនេះ មានអត្ថន័យជ្រាលជ្រៅណាស់ ចំពោះប្រជាជន សកលលោក ហើយជាពិសេស ចំពោះប្រជាជនដែលត្រូវចក្រពត្តិអាណានិគមចាស់ ថ្មី ជិះជាន់ សង្កត់សង្កិន ។ មហាជ័យជម្នះ ១៧មេសា របស់យើងនេះ ជាគំរូឲ្យដល់ប្រទេសនានាលើសកលលោក ឃើញថាប្រទេសតូចក្រីក្រដូចកម្ពុជាយើង ឲ្យតែពឹងផ្អែកលើកម្លាំងប្រជាជនខ្លួន ជឿជាក់លើប្រជាជនខ្លួន ហើយប្រមូលអស់នូវធនធានជាតិខ្លួន ក៏អាចវាយឈ្នះចក្រពត្តិអាមេរិក និងចក្រពត្តិផ្សេងទៀតបានដែរ ។ មហាជ័យជម្នះ ១៧មេសា របស់យើងនេះ ជាគំរូ ហើយក៏ជាការលើកទឹកចិត្តដល់ចលនាបដិវត្តន៍លើសកលលោក និងចលនារំដោះជាតិផ្សេងៗទៀត នៅលើសកលលោកដែរ ។ អាស្រ័យហេតុនេះហើយ បានជាប្រជាជនសកលលោក ដែលកំពុងធ្វើការតស៊ូប្រឆាំងទល់នឹងចក្រពត្តិនិយម អាណានិគមនិយមថ្មី ចាស់ ដណ្តើមឯករាជ្យជាតិ ចាត់ទុកមហាជ័យជម្នះ ១៧មេសា របស់យើងនេះ ថាជាជ័យជម្នះរបស់គេដែរ ។ ប្រជាជនសកលលោកដែលស្នេហាឯករាជ្យ យុត្តិធម៌ គោរពស្ញប់ស្ញែង ហើយរៀនសូត្រអំពីមហាជ័យជម្នះ ១៧មេសា របស់យើងនេះ ដោយយកចិត្តទុកដាក់ ។ នេះជា កិត្តិយសឧត្តុង្គឧត្តមរបស់យើងរាល់គ្នា ដែលយុវជន យុវនារីកម្ពុជាយើង មានមោទកភាពយ៉ាង សមរម្យ ចំពោះមហាជ័យជម្នះ ដ៏មហាអស្ចារ្យនេះ ។ យុវជន យុវនារីបដិវត្តន៍យើង ប្តេជ្ញាថែរក្សា ការពារកិត្តិយសរបស់យើងនេះ ឲ្យបានល្អគង់វង្សជារៀងរហូត ហើយនឹងកាន់តែល្បីរន្ទឺខ្ទរខ្ទារថែមទៀត ដោយខិតខំប្រយុទ្ធការពារប្រទេសឲ្យបានល្អប្រសើរ កសាងប្រទេសឲ្យចម្រើនលូតលាស់គ្រប់ វិស័យ ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ ។

ក្នុងឱកាសបុណ្យរំឭកខួបឆ្នាំទី២ នៃឯករាជ្យជាតិ ថ្ងៃ ១៧មេសា ដ៏មហាអស្ចារ្យនេះ យុវជន យុវនារីបដិវត្តន៍យើង ទូទាំងប្រទេស សូមលំឱនកាយ និងចិត្ត គោរពវិញ្ញាណក្ខន្ធដ៏រុងរឿងថ្លៃថ្លារបស់ វីរជន វីរនារីបដិវត្តន៍យើង របស់ប្រជាជន កម្មករ កសិករក្រយើង ដែលបានពលីយ៉ាងអង់អាច ក្លាហានបំផុត ក្នុងការតស៊ូបដិវត្តន៍ដ៏តឹងតែង ស្មុគស្មាញជាបន្តបន្ទាប់ ក្នុងរយៈកាលកន្លងទៅ ដោយក្តីរំភើប និងគោរពដឹងគុណជាទីបំផុត ដើម្បីជាកិច្ចតបស្នងសងគុណដល់វីរជន វីរនារី និងប្រជាជន កម្មករ កសិករក្រីក្រយើងទាំងនេះ យើងខ្ញុំយុវជន យុវនារីបដិវត្តន៍កម្ពុជាទាំងអស់ ប្តេជ្ញាប្រែក្លាយពលិកម្មឈាមស្រស់ និងពលិកម្មអាយុជីវិតដ៏ថ្លៃថ្លាបំផុតរបស់ពុកម៉ែ បងប្អូនយើងទាំងអស់នេះ ឲ្យទៅជាកម្លាំងប្រយុទ្ធខ្លាំងក្លាបំផុត ដែលមិនចេះរីងស្ងួត ដើម្បីសម្រុកសម្រេចភារកិច្ចបដិវត្តន៍ តូច ធំ គ្រប់បែបយ៉ាង ដណ្តើមមហាជ័យជម្នះធំៗថ្មីទៀតជានិច្ច រួមចំណែកយ៉ាងសកម្មក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារកម្ពុជាប្រជាធិបតេយ្យយើង ឲ្យបានល្អប្រសើរជារៀងរហូតទៅ ។ **ឆាយ សារៈមុនិន្ទ**

# អឿន ហៅ បឿន អតីតយុទ្ធជនក្រសួងភស្តុភារ កងពល១៧៤

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J០០១៦៩*

អឿន ហៅ បឿន អតីតយុទ្ធជនក្រសួងភស្តុភារ កងពល ១៧៤ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៧ ។ នៅក្នុងឯកសារចម្លើយសារភាពដែលមានកម្រាស់៥៣ទំព័ររបស់ អឿន ហៅ បឿន បានរៀបរាប់យ៉ាងលម្អិតអំពីសកម្មភាពក្បត់អង្គការបដិវត្តន៍ ក៏ដូចជាខ្សែសង្វាក់ ដែលចូលរួមធ្វើសកម្មភាពជាមួយគ្នា រហូតដល់ថ្ងៃអង្គការចាប់ខ្លួន ។ ខាងក្រោមនេះ ជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ អឿន ហៅ បឿនៈ

អឿន ឈ្មោះបដិវត្តន៍ បឿន មានអាយុ២៧ឆ្នាំ មានស្រុកកំណើតនៅភូមិវាលព្រីង សង្កាត់ឈើទាល ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

នៅឆ្នាំ១៩៦២ មានកើតខ្មែរក្រហមនៅក្នុងភូមិខ្ញុំ ពេលនោះចៅហ្វាយស្រុកឈ្មោះ ស៊ិន បាននាំជំទប់មេឃុំ ប៉ូលិស ទាហានមកព័ទ្ធភូមិរកចាប់ខ្មែរក្រហម ។ អ្នកទាំងនោះបានហៅប្រមូលប្រជាជនដែលដេកចាំស្រែចម្ការឲ្យត្រឡប់មកនៅភូមិវិញ ហើយចាត់តាំងឲ្យយាមល្បាតការពារភូមិ ។

នៅពេលនោះមនុស្សវ័យកណ្តាលឲ្យធ្វើកងអាសាស្ម័គ្រយាមភូមិទាំងយប់ទាំងថ្ងៃ ហើយបានឃោសនាអប់រំប្រជាជនថាខ្មែរក្រហមដើររកកាប់សម្លាប់ប្រជាជនស្លូតត្រង់ដែលដេកតាមស្រែចម្ការ និងលួចគោក្របី យកទៅកាប់ស៊ីផឹកសប្បាយក្នុងព្រៃ ។ ចំណែកយុវជនវិញ អប់រំឲ្យធ្វើគិញយកការឲ្យវាដើម្បីកម្ទេចចលនាតស៊ូរបស់ប្រជាជន ។ ដោយបានយកលេសហៅទៅឲ្យហូបបាយ ហូបទឹក ស៊ីផឹក ជប់លៀង លួងលោមដើម្បីទិញទឹកចិត្តឲ្យជាប្រាក់ខែមួយខែ២០០រៀលក្នុងម្នាក់ៗ អ្នកដែលវាចាត់តាំងឲ្យធ្វើគិញ មានចំនួន ១០នាក់គឺៈ រូបខ្ញុំផ្ទាល់, រ៉ូ, អូ, ឈឿន, លុន, ដុន, ឡេង, រ៉ែម, ហូ, ហួយ, ។ អ្នកដឹកនាំគិញគឺ សែបមុត ជាមេឃុំ ប៊ិន ជំទប់ និង អ៊ុំ ។ ក្រោយពីវាបានចាត់តាំងឲ្យធ្វើគិញហើយ មុត និង ប៊ិន បានឲ្យខ្ញុំ, អូ, រ៉ូ មកទាក់ទងជាមួយអាចារ្យ សុក ខាងឃុំផន ជាខ្សែគិញសម្ងាត់របស់ សែបមុត មានប្រាំនាក់គឺៈ សុក ធ្លាប់បានបួសរៀនបានប្រាំវស្សា និងជាអតីតប្រធានសហករណ៍ភូមិរនាម សង្កាត់មានជ័យ ស្រុកសណ្តាន់ ។ ផន ធ្លាប់បួសបានបីវស្សា ជាប្រធានកងអនុសេនាតូច ស្រុកសណ្តាន់, មឿន ធ្លាប់បួសបានបីវស្សា ជាយុទ្ធជនសហករណ៍ភូមិសោមខ្វា ស្រុកសណ្តាន់ ។ រ៉ែក ធ្លាប់បួសបានបីវស្សា នៅក្នុងសហករណ៍ភូមិសោមខ្វា សង្កាត់មានជ័យ ស្រុកសណ្តាន់ ។ អឿ ធ្លាប់បួសរៀនបានប្រាំវស្សា បានស្លាប់នៅសមរភូមិត្រពាំងវែងនៅឆ្នាំ១៩៧៤ ។ ក្រោយពីទាក់ទងគ្នារួចហើយ យើងបានធ្វើសកម្មភាពតាមដានរកឃើញអ្នកដែលឲ្យបាយខ្មែរក្រហមបានម្នាក់ឈ្មោះ ជី នៅខាងឃុំផន និងពីរនាក់ទៀតខាងឃុំឈើទាល ឈ្មោះ តួន ឈ្មោះ យុយ ។

មកដល់ខែមិថុនា ឆ្នាំ១៩៦៩ សែបមុត និងមេឃុំ ប៊ិន បានហៅឈ្មោះខ្ញុំ អូ, រ៉ូ ទៅជួបនៅសាលាឃុំឈើទាល លុះទៅដល់ ឈ្មោះ មុត និង ប៊ិន ហៅឲ្យទទួលយកផែនការ ទី១) គឺឲ្យកសាងកម្លាំងគិញថែមទៀត ទី២) ឲ្យតាមដានកម្ទេចកម្លាំងបដិវត្តន៍ ដែលបង្កប់នៅក្នុងភូមិឃុំ ។ លុះត្រឡប់មកវិញ ក៏អនុវត្តតាមការណែនាំរបស់ឈ្មោះ មុត និង ប៊ិន ។ ក្រោយមក ខ្ញុំ ក៏បានអប់រំឈ្មោះ ប៉ែន និង ហាក់ ឲ្យចូលធ្វើគិញ គឺដើម្បីកម្ទេចខ្មែរក្រហម ហើយបើធ្វើការងារល្អ យូរៗទៅនឹងបានធ្វើការធំៗ មានប្រាក់ខែក៏ច្រើន ។ ក្រោយមក សន និង មុត ហៅឈ្មោះ ខ្ញុំ, អូ និង រ៉ូ, ឲ្យមកជួបនៅសាលាស្រុកសណ្តាន់ ។ ក្នុងឆ្នាំ១៩៦៩ ខ្ញុំត្រូវបានចូលធ្វើ សេ.អ៊ី.អា ដោយមានអ្នកខ្ទេសនាមឈ្មោះ មុត អ្នកទទួលស្គាល់ឈ្មោះ សន បន្ទាប់មកខ្ញុំបានប្តេជ្ញាស្មោះត្រង់បម្រើបក្ស សេអ៊ីអា និងផឹកទឹកសម្បថ ។

នៅឆ្នាំ១៩៧០ មានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ប៊ិន និង មុត បានយកគ្នាខ្ញុំទាំង១២នាក់ មកចូលបង្កប់ក្នុងជួរបដិវត្តន៍ជាមួយឈ្មោះ ម៉េង ដែលជាគិញរបស់ឈ្មោះ ប៊ិន យូរឆ្នាំហើយ ។

ម៉េង បានចាត់តាំង ខ្ញុំ, អូ និង រ៉ូ ធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍ គឺបំពុលជ្រូកងាប់អស់១០ក្បាល និងទាអស់៣០ក្បាល ។ លើសពីនេះទៅទៀត យើងបានធ្វើឲ្យទឹកអង្ករអស់៥០បាវ អំបិលអស់៣០បាវ និងរលួយត្រីងៀតអស់១តោន និងបានបំផុសបំផុលទំនាស់នៅក្នុងសេដ្ឋកិច្ច ធ្វើឲ្យបែកបាក់សាមគ្គីជាបន្តបន្ទាប់ ។

មកដល់ខែមិថុនា ឆ្នាំ១៩៧១ អង្គការស្រុកសណ្ដាន់ បានបញ្ជូនទ័ពចុះមកសមរភូមិកំពង់ធំ ចំនួន៤២នាក់ ។ ពេលនោះ ម៉េង បានចាត់តាំងឲ្យខ្ញុំ, អូ និង រ៉ូ ឲ្យចុះទៅសមរភូមិកំពង់ធំ ដោយពេលនោះ ម៉េង បានសរសេរជាសំបុត្រប្រាប់ខ្សែរយៈទាក់ទងដែលជាខ្សែ សេ.អ៊ី.អា ឲ្យទៅឈ្មោះ ឈួន នៅយោធាវរសេនាតូច៧១០ កងពល១៧៤ដែរ ។ ឯកម្លាំងខាងខ្ញុំបីនាក់ ពេលចុះដល់សមរភូមិក៏ត្រូវបែកគ្នា ឈ្មោះ អូ និង រ៉ូ ត្រូវទៅនៅវរៈ៣០៨ សមរភូមិខាងត្បូងកំពង់ធំ ។ ចំណែក ខ្ញុំនៅសមរភូមិខាងជើងកំពង់ធំ ។

ក្រោយមក ឈ្មោះ ឈួន បានហៅកម្លាំង សេ.អ៊ី.អា ទាំងបីនាក់មកភ្ជាប់ខ្សែជាថ្មីឲ្យស្គាល់គ្នា ។ ឈ្មោះស៊ី អតីតសិស្សរៀនថ្នាក់ទី៣ ជាប្រធានកងអនុសេនាតូច (រត់ទៅផ្ទះនៅចុងឆ្នាំ១៩៧៣) នៅភូមិកោះប្រែង សង្កាត់ប្រែង ស្រុកក្រចេះ ខេត្តក្រចេះ ។ ឈ្មោះ ឆែ អតីតប្រធានកងតូច នៅមន្ទីរពេទ្យតំបន់៣២ កំពង់ធំ ។ ឈ្មោះ ឈួន បានចាត់តាំងដាក់ផែនការឲ្យឈ្មោះ ស៊ុម, ឆែ និង ខ្ញុំឲ្យកសាងកម្លាំង សេ អ៊ី អា ចំនួនប្រាំនាក់បានបំផ្លិចបំផ្លាញកម្លាំងបដិវត្តន៍ ។ ក្រោយមក យើងបានហៅកម្លាំង សេ អ៊ី អា ថ្មីទាំងប្រាំនាក់មកអប់រំ គឺមាន ឈ្មោះ ឡា អនុប្រធានក្រុម ស្រុកស្ទោង ខេត្តកំពង់ធំ ។ ឈ្មោះ ផល ជាសមាជិកកងតូច (ស្លាប់នៅសមរភូមិត្រពាំងវែង ឆ្នាំ១៩៧៤) ។ ឈ្មោះ ស្រេន ជា យុទ្ធជនពិការនៅមន្ទីរពេទ្យស្រុកស្ទោង តំបន់៤៣ ។ ឈ្មោះ កាំ អតីតធ្វើស្រែ អនុប្រធានកងតូច (ស្លាប់នៅសមរភូមិក្ដីដូង នៅដើមឆ្នាំ១៩៧៥) និងឈ្មោះ គុង អតីតពេទ្យប្រចាំកងអនុសេនាធំ (ស្លាប់នៅសមរភូមិអូរកន្ធរ) ។ ក្រោយពីបានអប់រំហើយ អ្នកទាំងប្រាំនាក់ ក្រោមការចាត់តាំងរបស់ឈ្មោះ ឈួន គឺបានធ្វើសកម្មភាពបំផុសបំផុលឲ្យយុទ្ធជនរត់ទៅផ្ទះម្ដងអស់១០នាក់ និងលើកក្រោយទៀតអស់២៥នាក់ និងនាំយុទ្ធជនរត់បោលទីតាំង ឲ្យខ្មាំងដណ្ដើមយកបានជាបន្តបន្ទាប់ ។

ដល់ឆ្នាំ១៩៧២ អង្គការបានដកទ័ពទៅប្រតិបត្តិការនៅសៀមរាប ហើយក្រោយពីប្រយុទ្ធគ្នារួចហើយ ពេលនោះខ្ញុំក៏ត្រូវរបួសសម្រាកព្យាបាលនៅពេទ្យអស់រយៈពេលមួយខែ ។ ចាប់ពីខែមិថុនា ដល់ខែកក្កដា អង្គការក៏ដកកងទ័ពត្រឡប់មកកំពង់ធំ និងកំពង់ចាមអស់ ។ ឈ្មោះ ឈួន បានប្រាប់ខ្ញុំថា “ដល់ជារបួសវិញមិនចាំបាច់ទៅតាមទ័ពទេ” នៅពេលដែលចេញពីពេទ្យទៅនៅជាមួយឈ្មោះ សួ ចុះ ព្រោះគាត់បានខទ្ទេសនាមប្រាប់ឈ្មោះ សួ រួចហើយពីរឿងខ្សែ សេ.អ៊ី.អា ហើយឲ្យ សួ ភ្ជាប់ខ្សែតទៅទៀតដើម្បីធ្វើសកម្មភាពប្រឆាំងបក្សបដិវត្តន៍ ។

ដល់ចេញពីពេទ្យមកវិញ ខ្ញុំមកនៅមន្ទីរភស្តុភារ ជាមួយ សួ ផ្ទាល់តែម្ដង ។ ក្រោយមក សួ បានហៅខ្សែ សេ អ៊ី អា ១០រូបមកប្រជុំដើម្បីភ្ជាប់ជាខ្សែសង្វាក់ គឺ ខ្ញុំ, នន ប្រធានផ្នែកខារក្រួស ក្រសួងខស្សរាហកម្ម, វ៉ាត ប្រធានកងអនុសេនាធំដឹកជញ្ជូន ជើងទឹកពាណិជ្ជកម្មរដ្ឋ, ថៃ អនុប្រធានមន្ទីរពេទ្យយោធា តំបន់១០៦ (សៀមរាប), ប្រាំ សមាជិកពេទ្យយោធា១០៦ (សៀមរាប), ឆោម សមាជិកមន្ទីរពេទ្យយោធា១០៦ (ឧត្ដរមានជ័យ), អ៊ុន ប្រធានមន្ទីរពិសោធថ្នាំរបស់យោធា១០៦ (ឧត្ដរមានជ័យ), ជី ប្រធានឃានដ្ឋានភស្តុភារយោធា១០៦, ថា ប្រធានឃានដ្ឋានភស្តុភារ កងពល១៧៤ និងឈ្មោះ ដែន ប្រធានសេដ្ឋកិច្ចភស្តុភារ



រូបថតជនរងគ្រោះនៅមន្ទីរសន្តិសុខ ស-២១

កងពល១៧៤ ។

ក្រោយពីប្រជុំភ្ជាប់ខ្សែសង្វាក់មកឈ្មោះ ស្ងួ បានចាត់ឲ្យខ្សែ សេអ៊ីអា បីរូប ធ្វើសកម្មភាពបំផ្លិចបំផ្លាញសម្ភារបដិវត្តន៍ រួមមានឈ្មោះ ជី, ថា និង ដែន ។ ក្រោយពីបានទទួលការចាត់តាំងរួចហើយ ក៏ចាប់ផ្តើមអនុវត្តផែនការក្លាមដោយលាយថ្នាំក្នុងទឹកធ្វើឲ្យកករប្រើប្រាស់លែងបាន ។ ក្រៅពីនេះគឺបំផ្លាញអង្ករឲ្យត្រូវទឹកផ្អូមផូរខូចជាបន្តបន្ទាប់ ។

នៅឆ្នាំ១៩៧៣ ស្ងួ បានហៅខ្សែ សេអ៊ីអា បួននាក់មកប្រជុំទៀតគឺមានឈ្មោះ ថា, ថៃ, ជី និង ខ្ញុំ ។ ស្ងួ ក៏ដាក់ផែនការឲ្យខ្ញុំទាំងបួននាក់ អនុវត្តផែនការកសាងកម្លាំង សេ.អ៊ី.អា ឲ្យបានពីរនាក់ទៀត ។ ក្រោយមក យើងបានអប់រំឈ្មោះ ទឹម អនុប្រធានយានដ្ឋានយោធា១០៦ និងណាន សមាជិកមន្ទីរយានដ្ឋានភ័ស្តុភារយោធា១០៦ ឲ្យចូល សេ.អ៊ី.អា ព្រោះនឹងបានធ្វើការធំៗ មានប្រាក់ក៏ច្រើនរបស់របរមិនខ្វះ ។ សកម្មភាពរបស់ ខ្ញុំ នៅពេលនោះក៏បានរៀបចំបំផ្លាញឡានសែងហ្សង់មួយគ្រឿង ដោយបើកមិនចាក់ទឹក មិនចាក់ប្រេងម៉ាស៊ីន ធ្វើឲ្យខ្ទោកម៉ាស៊ីន និងឆេះគ្រឿងបន្ទាស់ ។

នៅឆ្នាំ១៩៧៤ ឈ្មោះ ស្ងួ បានប្រមូលខ្សែ សេ.អ៊ី.អា ទាំងអស់ដើម្បីងាយស្រួល ទាក់ទងគ្នាធ្វើការ មាន ខ្ញុំ, ថា, ដែន, ថៃ, ប្រាំ, ឆោម, អ៊ុន, ជី, ទឹម ណាន, វិន និង វី ។ ក្រោយមកនៅខែកញ្ញាឆ្នាំដដែល ស្ងួ ត្រូវផ្លាស់ចេញពីក្រសួងភ័ស្តុភារ ទៅធ្វើគណៈស្រុកពួក ហើយ ឈ្មោះ លី មកទទួលក្រសួងភ័ស្តុភារជំនួស ។ ពេលនោះឈ្មោះ ស្ងួ បានខទ្មេសនាមខ្សែ សេអ៊ីអា ឲ្យឈ្មោះ លី បានដឹងដែរ ហើយ លី បានចាត់តាំងឲ្យ ខ្ញុំ, វិន, និង វី ឲ្យកសាងកម្លាំង សេ.អ៊ី.អា និងឲ្យធ្វើសកម្មភាពបំផ្លាញ ។ ពេលនោះខ្ញុំហៅឈ្មោះអ្នកដែលត្រូវកសាងឲ្យចូល សេ.អ៊ី.អា បន្ថែមគឺ ជឿន, ឡាញ់ និង រុន ។ ពេលនោះ ខ្ញុំបានបំផ្លាញអំបិលធ្វើឲ្យត្រូវទឹកភ្លៀងខូចអស់១០០បាវ ហើយបំផ្លាញស្រូវវស្សានៅស្វាយជ្រំអស់បីហិកតា ដោយបង្ហូរទឹកឲ្យស្រូវក្រៀមស្វិត និងបំផ្លាញគោអស់២ក្បាលទៀតដោយឈ្មោះ វិន និង វី ដេញឲ្យចូលតំបន់ខ្មាំង ។

នៅខែឧសភា ឆ្នាំ១៩៧៥ លី បានហៅខ្សែ សេ.អ៊ី.អា បីនាក់មកណែនាំមាន ខ្ញុំ, ថា, និង ដែន ។ លី បានណែនាំយើងទាំងបីនាក់ ឲ្យធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ទៀត ។ ក្រោយពីបានទទួលការណែនាំហើយ យើងទាំងបីក៏ចាប់ផ្តើមអនុវត្ត ដោយបំផ្លាញក្រណាត់ជាឌិបខ្មៅអស់១៥គី ទុកចោលឲ្យកណ្តៀរស៊ី និងបំផ្លាញសេរ៉ូមផ្អែមអស់២០ផ្កោក ដោយទុកចោលឲ្យស្រមោចបោះ និងសត្វកណ្តុរកាត់ ហើយថែមទាំងបានបំផ្លាញថ្នាំពេទ្យផ្សេងៗទៀត ដោយយកចាក់ យកលេប យកដឹក តាមចិត្តនឹកឃើញ ។ ចូលមកដល់ខែកក្កដា ឆ្នាំ១៩៧៥ លី បានហៅខ្ញុំទាំងបីមកណែនាំដាក់ផែនការថ្មី ។ ខ្ញុំទាំងបីក៏ចាប់ផ្តើមធ្វើសកម្មភាពបំផ្លាញម៉ាស៊ីនកិនស្រូវអស់មួយគ្រឿង ដោយកិនមិនចាក់ប្រេងម៉ាស៊ីន ធ្វើឲ្យខ្ទោកម៉ាស៊ីនប្រើលែងបាន ។ មកដល់ខែកញ្ញា ឆ្នាំ១៩៧៥ ឈ្មោះ លី បានចាត់តាំងឲ្យឈ្មោះ ថា, និង ដែន សម្ងាប់ក្របីពីរនឹមទៀត ដោយដាក់ថ្នាំបំពុលទៅក្នុងស្មៅ និងបំផ្លាញត្រីឆ្អើរអស់មួយតោន ដោយផ្អាប់ទុកឲ្យកើតដង្កូវ ដុះផ្សិតហូបលែងបាន ។

ខែតុលា ឆ្នាំ១៩៧៥ ខ្ញុំ, យឿន, ថា, និង ផា បានធ្វើសកម្មភាពបំផ្លាញ ស្រូវស្រែបឹងកុកអស់ចំនួនមួយហិកតា ដោយបិទទឹកឲ្យរលួយ និងបំផ្លាញឡាន សេ.អឹម.សេ អស់មួយគ្រឿង ដោយបើកបរមិនចាក់ទឹកចាក់ប្រេងម៉ាស៊ីន ។ រហូតដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៧ ខ្ញុំត្រូវអង្គការចាប់ខ្លួន ដោយសារលួចដុតឃ្លាំងអាវុធ ។ **ហូ ថុនា**



# ជំណើរជីវិត អ៊ឹង ស៊ីម៉ូណាទី : ភាពបែកបាក់ ភាពសោកសង្រេង និងភាពតក់ស្លុតក្នុងរបបខ្មែរក្រហម

អ៊ឹង ស៊ីម៉ូណាវី មានអាយុជាងដប់ឆ្នាំប៉ុណ្ណោះ នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែការបាក់បែកសមាជិកគ្រួសារជាទីស្រឡាញ់ ភាពសោកសង្រេង ភាពតក់ស្លុតនៅពេលយោធាខ្មែរក្រហមសម្លាប់សមាជិកគ្រួសារគាត់នៅផ្ទាល់នឹងភ្នែក នៅតែដិតដាមជាប់ក្នុងអារម្មណ៍របស់គាត់ជានិច្ច ។

## ប្រវត្តិផ្ទាល់ខ្លួន និងសាច់ញាតិ

ស៊ីម៉ូណាវី កើតនៅឆ្នាំ១៩៦៣ នៅសង្កាត់លេខ៥ (សង្កាត់ទួលទំពូង) ក្រុងភ្នំពេញ ។ ស៊ីម៉ូណាវី មានឪពុកឈ្មោះ អ៊ឹង ស៊ីម៉ូណា ធ្វើជាគ្រូបង្រៀននៅវិទ្យាល័យត្រពាំងក្រឡឹង ស្ថិតនៅក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ រហូតដល់ឆ្នាំ១៩៧២ ទើបឪពុកគាត់ផ្លាស់មកធ្វើទាហាននៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់ លន់ នល់វិញ ។ ចំណែកម្ដាយរបស់គាត់ឈ្មោះ ញ៉ែម យិន ជាមេផ្ទះ ។ ម្ដាយរបស់ ស៊ីម៉ូណាវី បានត្រឡប់ទៅរស់នៅស្រុកកំណើតនៅក្នុងស្រុករមាសហែក ខេត្តស្វាយរៀងវិញ ក្រោយពីបែកបាក់ជាមួយឪពុក ហើយឪពុករបស់គាត់យកប្រពន្ធថ្មីមានកូនទាំងអស់៤នាក់នៅខេត្តកំពង់ស្ពឺ ។

ចាប់តាំងពីពេលនោះមក ស៊ីម៉ូណាវី បានទៅរស់ជាមួយតាឈ្មោះ អ៊ឹង ទុន និងយាយដែលបានទិញដី និងសង់ផ្ទះនៅខេត្តកំពង់ស្ពឺ ព្រោះយាយតារបស់គាត់មានកូនប្រុសម្នាក់ដែលត្រូវជាអ៊ំរបស់ ស៊ីម៉ូណាវី ឈ្មោះ អ៊ឹង ម៉ឹង ធ្វើជាតំណាងរាស្ត្រនៅមណ្ឌល



ដើមអំពិលបារាំងដែលគ្រួសារ ស៊ីម៉ូណាវី ធ្លាប់ជ្រក ពេលដែលខ្មែរក្រហមជម្លៀសមកដល់វត្តផ្លូវមាន់ដំបូង

កំពង់ស្ពឺ ។ នៅទីនោះ ជីតារបស់ ស៊ីម៉ូណារី បានយក ស៊ីម៉ូណារី ទៅចុះឈ្មោះ ចូលរៀននៅសាលាបឋមសិក្សាអគ្គសិរីដែលគាត់ធ្លាប់បានជួយកសាង ។ នៅរៀងរាល់ពេលសម្រាកពីរៀនសូត្រនៅចុងសប្តាហ៍ ស៊ីម៉ូណារី បានមកលេងផ្ទះយាយតា នៅមុំឃ្លាំងរំសេវ ក្នុងក្រុងភ្នំពេញមួយកន្លែងទៀត ដោយមានតែកុងបើកជូនទៅមក ព្រោះពេលនោះ គ្រួសារគាត់មានជីវភាពធូរធារ ដោយ




អ៊ំប្រុសទី១) អ៊ឹង ម៉ឹង ធ្វើជាតំណាងរាស្ត្រ, អ៊ំប្រុសទី២) អ៊ឹង ង៉ូវ ធ្វើជាមន្ត្រីស្ថានទូត, អ៊ំប្រុសទី៣) អ៊ឹង បាន ធ្វើការខាងផ្នែកដែនទីក្នុងក្រសួងសុរិយោដី, ទី៤) អ៊ឹងស៊ីម៉ូណា (ត្រូវជាឪពុក) ធ្វើគ្រូបង្រៀន ក្រោយរដ្ឋប្រហារធ្វើជាទាហានពាក់សក្តិ៥, ពូទី៥) អ៊ឹង ស៊ីម៉ូន្នី ធ្វើជាមន្ត្រីគយ និងមីងទី៦) អ៊ឹង សុខា មានប្តីធ្វើជាប៉េអឹមពាក់សក្តិពីរ នៅខេត្តកំពង់ស្ពឺ ។ អ៊ំពូមីងរបស់ ស៊ីម៉ូណារី មានផ្ទះនៅភ្នំពេញរៀងៗខ្លួន ។

ស៊ីម៉ូណារី រៀននៅកំពង់ស្ពឺរហូតដល់ថ្នាក់ទី៨ ទើបគាត់ផ្លាស់មករៀននៅវិទ្យាល័យទួលទំពូង ក្រុងភ្នំពេញវិញ ដោយស្នាក់នៅជាមួយយាយ និងគ្រួសារមីង អ៊ឹង សុខា រួមជាមួយកូនស្រីគាត់ពីរនាក់ទៀត ។

## ខ្មែរក្រហមមកដល់

ស៊ីម៉ូណារី រៀនរហូតដល់ឆ្នាំ១៩៧៥ ទើបយោធាខ្មែរចូលមករំដោះបានក្រុងភ្នំពេញ ដោយមានប្រជាជននៅតាមដងវិថី និងតាមផ្ទះលើកទង់ជ័យអបអរ ។ ពេលនោះ យាយរបស់ ស៊ីម៉ូណារី ត្រេកអរយ៉ាងខ្លាំង ព្រោះគិតថា ពេលស្រុកទទួលបានសន្តិភាព គាត់នឹងនាំគ្រួសារទៅលេងស្រុកកំណើត នៅខេត្តស្វាយរៀងម្តង ។ ក្រុមគ្រួសាររបស់ ស៊ីម៉ូណារី សប្បាយរីករាយគ្រប់ៗគ្នា ។ ប៉ុន្តែមួយសន្ទុះក្រោយមក អ៊ំប្រុសរបស់ ស៊ីម៉ូណារី អ៊ឹង ម៉ឹង បានឲ្យមនុស្សម្នាក់មកប្រាប់យាយ និង ពូមីងរបស់ ស៊ីម៉ូណារី ថា "គាត់ចេញមកជួបមិនបានទេ (តែមិនបានបញ្ជាក់ពីមូលហេតុទេ) ហើយជ័យជម្នះនេះ! មិនមែនជារឿងសន្តិភាពនោះទេ" ។ នៅថ្ងៃនោះដែរ ឪពុករបស់ ស៊ីម៉ូណារី ក៏បានសរសេរសំបុត្រមួយច្បាប់ ដែលនិយាយពីហេតុការណ៍ដែលកងទ័ពខ្មែរក្រហមចូលមកផ្ញើមកឲ្យយាយរបស់គាត់ដែរ ។ ពេលទទួលបានដំណឹងនោះយាយរបស់ ស៊ីម៉ូណារី បានប្រែពីសប្បាយរីករាយ ទៅជាភ័យព្រួយពីសុខទុក្ខរបស់កូនៗភ្លាមៗ រហូតដល់គាត់យំ ។

## ថ្ងៃចាកចេញ

នៅវេលាម៉ោងប្រមាណ១១ព្រឹក យាយ និងមីងរបស់ ស៊ីម៉ូណារី បានចម្អិនម្ហូបអាហារ និងរៀបចំដាក់លើតុរួចជាស្រេច ដើម្បីរង់ចាំកូនៗឲ្យមកហូបជុំគ្នា ។ អ៊ំពូមីងរបស់ ស៊ីម៉ូណារី ចំនួនប្រាំគ្រួសារ រួមទាំងឡានចំនួន៥គ្រឿង បានបើកមកជុំគ្នានៅផ្ទះយាយរបស់គាត់នៅឃ្លាំងរំសេវ លើកលែងតែឪពុក និងជីតារបស់គាត់ ។ តែក្រុមគ្រួសាររបស់គាត់មិនទាន់បានហូបបាយផង ក៏យោធាខ្មែរក្រហមចូលមកប្រាប់ថា សូមចាកចេញបីថ្ងៃសិន! ព្រោះយន្តហោះមកទម្លាក់គ្រាប់បែក ។ នៅពេលនោះ អ៊ំ ពូ មីង របស់ ស៊ីម៉ូណារី មិនបានយកខោអាវ និងសម្ភារមកជាប់ជាមួយខ្លួនទេ គឺមានតែនំប័ុង និងម្ហូបបន្តិចបន្តួចដែលសេសសល់ពីសែនចូលឆ្នាំខ្មែរ ក្នុងខែមេសា ឆ្នាំ១៩៧៥ ។ ម្យ៉ាងទៀត អ៊ំ ពូ មីង ស៊ីម៉ូណារី មិនបានដឹងថា ខ្មែរក្រហមនឹងជម្លៀសក្រុមគ្រួសារគាត់ចេញពីផ្ទះទេ ។ ភ្លាមនោះ យាយរបស់គាត់បាននិយាយថា "បើគេ (ខ្មែរក្រហម) មិនឲ្យយករបស់របរតាមខ្លួនទេ! យើងយកតែត្រីខកំប៉ុង និងសារុងថ្មីៗដាក់ទៅតាមខ្លួនឲ្យច្រើនទៅ" ព្រោះពេលនោះ មានពូរបស់គាត់ម្នាក់ឈ្មោះ អ៊ឹង ស៊ីម៉ូន្នី ជាមន្ត្រីគយ តែងតែយកសារុងថ្មីៗមកទុកនៅផ្ទះ ។

យាយរបស់ ស៊ីម៉ូណារី បានយកត្រីខ និងសារុងមួយបាវដាក់ឃ្លុបឡានខាងក្រោយ រួមជាមួយលុយមួយចំនួនទៀត រួចធ្វើដំណើរតាមបណ្តោយផ្លូវជាតិលេខ៤ សំដៅទៅខេត្តកំពង់ស្ពឺ ។ ប៉ុន្តែ ពេលមកដល់កំពង់ត្រាំ ក្នុងស្រុកអង្គស្នួល អ៊ំប្រុស និងពូរបស់ ស៊ីម៉ូណារី មួយចំនួនបានសុំបែកទៅរស់នៅខាងប្រពន្ធវិញ នៅសល់តែ យាយ, អ៊ំប្រុស អ៊ឹង ម៉ឹង រួមជាមួយតៃកុងឡាន និងអ្នកនៅជាមួយគាត់ម្នាក់ទៀត, មីងសុខា និងប្តីគាត់ ព្រមជាមួយកូនស្រី

របស់គាត់ពីរនាក់ ។ នៅពេលកំពុងធ្វើដំណើរនោះ ស៊ីម៉ូណារី បានឃើញមនុស្សម្នាចាកចេញទៅជាមួយគាត់យ៉ាងច្រើនណែនណាន់តាន់តាប់ ក្នុងនោះមានទាំងអ្នកជំងឺទើបចេញពីមន្ទីរពេទ្យ អ្នកសម្រាលកូនតាមផ្លូវ និងមានមនុស្សដេករណ្ដូករណែលក្រោមម្លប់ឈើ ហើយឃើញមានក្រវាត់លុយចោលពាសវាលពាសកាល រួមទាំងគ្រួសារ ស៊ីម៉ូណារី ដែរ ព្រោះខ្មែរក្រហមប្រាប់ឲ្យបោះចោលដោយអង្គការប្រាប់ថា នឹងផ្ដល់ស្បៀងអាហារ ។

## បាត់ខ្លួនរហូត

បន្ទាប់ពីកូនៗចាកចេញអស់ហើយ យាយរបស់ ស៊ីម៉ូណារី បានធ្វើដំណើរសំដៅចុះទៅរោងចក្រផលិតស្ករស ហើយបានសម្រាកនៅទីនោះមួយយប់ ។

លុះព្រឹកឡើង មានមនុស្សប្រុសម្នាក់កាន់កាំភ្លើង ដែល ស៊ីម៉ូណារី មិនទាំងដឹងថា មកពីខាងណាផង ព្រោះគាត់នៅក្មេង មកសួរគ្រួសារគាត់ថា មួយណាឈ្មោះ អ៊ុង ម៉ុង? ពេលឮសំណួរនោះ តែកុងឡានអ៊ំប្រុសរបស់គាត់មិនហ៊ានឆ្លើយទេ តែអ៊ំរបស់គាត់បានឆ្លើយប្រាប់ឈ្មោះខ្លួនឯង ។ យោធានោះនិយាយបន្ថែមថា អង្គការស្នើមិត្ត! ឲ្យទៅជួយធ្វើការងារនៅទីក្រុងភ្នំពេញ ។ អ៊ំប្រុសរបស់ ស៊ីម៉ូណារី និងតៃកុងឡាន រួមជាមួយអ្នកនៅជាមួយគាត់ម្នាក់ទៀត បានបើកឡានចាកចេញទៅជាមួយយោធានោះ ។ ដោយឡែក ប្រពន្ធអ៊ំប្រុសរបស់គាត់ និងកូនៗបួននាក់បានចាកចេញទៅរស់នៅប្រទេសបារាំងតាំងពីមុនពេលខ្មែរក្រហមចូលមកភ្នំពេញម្ល៉េះ ។

យាយ មីង ពូថ្លៃរបស់ ស៊ីម៉ូណារី បានរង់ចាំអ៊ំប្រុសរបស់គាត់រយៈពេលមួយអាទិត្យដោយគ្មានដំណឹង ។ យោធាខ្មែរក្រហមបានមកដេញយាយរបស់គាត់ឲ្យធ្វើដំណើរបន្តទៅមុខទៀត និងបានដកយកឡានរបស់គាត់ដោយបានប្រាប់ថា "មកដល់ត្រឹមនេះអង្គការឈប់ឲ្យប្រើប្រាស់ឡានហើយ" រួចដកយកឡានគាត់ទុក ហើយយកស៊ីក្លូមកឲ្យគាត់ដាក់អីវ៉ាន់ជំនួសវិញ" ។ យាយរបស់ ស៊ីម៉ូណារី បានចេញទៅបោះតង់ជ្រកនៅកន្លែងផ្សេង ដើម្បីបន្តរង់ចាំកូនត្រឡប់មកវិញ ។ នៅខែនោះ ថ្ងៃក្ដៅខ្លាំងណាស់ ព្រោះត្រូវនឹងខែចែត្រ ហើយដែលធ្វើឲ្យ ស៊ីម៉ូណារី នៅចងចាំរហូតមកដល់សព្វថ្ងៃនេះ ។

នៅល្ងាចមួយ មានឈ្លបខ្មែរក្រហមម្នាក់មកប្រាប់គ្រួសារ ស៊ីម៉ូណារី ថា "មិនបាច់រង់ចាំទៀតទេ! ព្រោះ អ៊ុង ម៉ុង ដែលគេ (យោធា) យកទៅ ត្រូវសម្លាប់បាត់ហើយ!" ។ យាយរបស់ ស៊ីម៉ូណារី ក៏បានសួរឈ្លបនោះថា តើគេយកទៅសម្លាប់នៅណា? ឈ្លបបានប្រាប់ថា នៅជិតភ្នំស្រង់ ។ ពេលឮសម្ដីនេះ យាយរបស់គាត់ចាប់ផ្ដើមធ្លាក់ទឹកចិត្ត និងអស់សង្ឃឹមយ៉ាងខ្លាំង រហូតធ្វើឲ្យគាត់ដើរលែងរួច ហើយពេលគាត់ចង់ដើរទៅណាមកណាម្ដងៗ ទាល់តែមានអ្នកជួយគ្រាហ៍ទើបអាចដើររួច ។

គ្រួសាររបស់ ស៊ីម៉ូណារី បានសម្រេចចិត្តទៅភ្នំស្រង់ដើម្បីតាមស៊ើបសួររកដំណឹងអ៊ំប្រុសរបស់គាត់តទៅទៀត និងដើម្បីបន្តលាក់ខ្លួននៅទីនោះ ដោយគាត់គិតថា នៅទីនោះគេស្គាល់ច្រើន ហើយរំពឹងថា គេនឹងជួយ ព្រោះអ្នកនៅតំបន់ភ្នំស្រង់នេះធ្លាប់ត្រូវបានតាយាយរបស់ ស៊ីម៉ូណារី ជួយកាលពីអំឡុងពេលសង្គ្រាមរវាងកងទ័ព លន់ នល់ និងខ្មែរក្រហម ដែលកាលនោះយាយតារបស់គាត់ដឹកលេណដ្ឋានយ៉ាងធំនៅចម្ការអង្គសិរីសម្រាប់ឲ្យអ្នកទាំងនោះចូលមកលាក់ខ្លួននៅពេលមានគ្រាប់ផ្លោង ឬការទម្លាក់បែក ព្រមទាំងជួយឧបត្ថម្ភបាយ ទឹក និងថ្នាំសង្កូវទៀតផង ។

## អ្នកភូមិរាយការណ៍

គ្រួសាររបស់ ស៊ីម៉ូណារី បានទៅរស់នៅជិតភ្នំស្រង់ ក្នុងស្រុកគងពិសី ដោយពេលទៅដល់ដំបូង អង្គការបានដកយកនាឡិកា, មាស, ពេជ្រ និងប្រាក់ទាំងអស់ដែលនៅសល់ ។ បន្ទាប់មក អង្គការបានចាត់តាំង ស៊ីម៉ូណារី ឲ្យទៅលើកទំនប់មួយ ហើយដោយគ្មានខោអាវខ្មៅស្លៀកពាក់ ទើបគាត់យកសារុងថ្មីទៅដូរបានខោអាវខ្មៅពីអ្នកមូលដ្ឋានមកពាក់ធ្វើការ ។ ស៊ីម៉ូណារី នៅកងលើកទំនប់រយៈពេលមួយខែ ទើបអង្គការហៅគាត់ត្រឡប់មកភូមិវិញ ។ ប៉ុន្តែដោយមានការងឿងឆ្ងល់ គាត់បានសួរទៅវិញថា មកភូមិធ្វើអ្វី? ទើបអង្គការប្រាប់ថា ឲ្យត្រៀមទៅរស់នៅពោធិ៍សាត់ ។ ឮដូច្នេះ ទើប ស៊ីម៉ូណារី ដឹងថា មានអ្នកភូមិដែលធ្លាប់ដឹងប្រវត្តិគ្រួសារគាត់រាយការណ៍ប្រាប់ទៅថ្នាក់លើហើយ ព្រោះមានអ្នកនៅលើកទំនប់ជាមួយគ្នាមកខ្សឹបប្រាប់ពីរឿងនេះ ។ ដូច្នេះ ការរំពឹងទុកថា គេនឹងជួយ បែរជាត្រូវបានគេរាយការណ៍ថា ក្រុមគ្រួសាររបស់ ស៊ីម៉ូណារី ជាក្រុមនាយទុន រួមជាមួយគ្រួសារដទៃទៀតដែលជា

មន្ត្រីធំជាន់នោះ ទើបអង្គការបញ្ជូនទៅខេត្តពោធិ៍សាត់ដែលជាកន្លែងលត់ដំខ្លាំង ។

ពេលមកដល់ភូមិ ស៊ីម៉ូណារី ឃើញយាយរបស់គាត់ដើរលែងរួចទៅហើយ គឺគាត់បានត្រឹមតែរំកិលចុះឡើងប៉ុណ្ណោះ ។ មានថ្ងៃមួយ ស៊ីម៉ូណារី បានជួបជីតារបស់គាត់ដោយចៃដន្យ ពេលជីតា របស់គាត់កំពុងដើរជាមួយអ្នកភូមិ ព្រោះគ្រួសារគាត់បែកពីជីតាគាត់តាំងពីថ្ងៃជម្លៀសម្ល៉េះ ។ ឃើញដូច្នេះ ស៊ីម៉ូណារី ក៏បានស្រែកហៅជីតារបស់គាត់ រួចនាំជីតាគាត់ឲ្យមករស់នៅជុំគ្នាវិញ ។

រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៥ ទើបអង្គការបញ្ជូនក្រុមគ្រួសារ ស៊ីម៉ូណារី តាមឡានយោធាម៉ាក ជី.អឹម.សេ (G.M.C) ជាមួយប្រជាជនរាប់ពាន់គ្រួសារផ្សេងទៀតឲ្យទៅរស់នៅខេត្តពោធិ៍សាត់ ។ តែក្នុងពេលធ្វើដំណើរនោះ យាយរបស់គាត់មានការលំបាកខ្លាំងព្រោះគាត់ត្រូវអង្គុយផ្ទាល់ក្នុងឃ្លុបឡានខាងក្រោយលាយឡំជាមួយហ្វូងមនុស្សឈរប្រជ្រៀតគ្នា និងទ្រោបពីលើគាត់ ។ អ្នកបើកឡានបានទៅឈប់នៅមុខខ្លោងទ្វារវត្តសុវណ្ណសត្ថារាម



ខ្លោងទ្វារវត្តដូវមាន់

ហៅវត្តដូវមាន់ ក្នុងស្រុកបាកាន នៅពេលរសៀល និងជាថ្ងៃដំបូងដែល ស៊ីម៉ូណារី បានស្គាល់ខេត្តពោធិ៍សាត់ ។ អង្គការបានឲ្យគ្រួសារគាត់ចុះពីលើឡានរួចហើយឲ្យធ្វើដំណើរថ្មើរជើងចុះទៅដូវលំ ។

## ជម្រកថ្មី



ទួលដែលក្រុមគ្រួសារ ស៊ីម៉ូណារី បោះតង់រស់នៅក្នុងរបបខ្មែរក្រហម

ពូថ្លៃរបស់ ស៊ីម៉ូណារី ឈ្មោះ ផាត ប្តីមីង (សុខា) ទៅរកបានឆាងត្នោតមួយ មកអូសយាយរបស់គាត់ ព្រោះគ្រួសារគាត់មិនមានរទេះសម្រាប់ដឹកជញ្ជូន ។ មកដល់ទីនោះ គ្រួសារ ស៊ីម៉ូណារី មិនមានរបស់របរសំខាន់ទេ គឺនៅសេសសល់តែសារុងបន្តិចបន្តួចប៉ុណ្ណោះ ។ ក្រុមគ្រួសាររបស់ ស៊ីម៉ូណារី ដើរចម្ងាយពាគីឡូម៉ែត្រ ទើបទៅដល់វត្តដូវមាន់ ។ គាត់បានដេកនៅក្នុងវត្តនោះមួយយប់ជាមួយប្រជាជនថ្មីរាប់រយគ្រួសារទៀត ។ ព្រឹកឡើង ស៊ីម៉ូណារី ពូ និង មីង ព្រមទាំងកូនគាត់ បានចេញទៅរកកន្លែងដែលមានដីទួល ឬដំបូកសម្រាប់សង់ខ្ទមស្នាក់នៅមុន ដោយទុកឲ្យយាយតារង់ចាំនៅវត្ត ។ ដោយសាររដូវនោះ ជារដូវវស្សាទឹកឡើង ទើបមិនសូវមានដីទួល ដូច្នេះហើយទើប ស៊ីម៉ូណារី ត្រូវដើរកាត់ទឹកជ្រៅៗ ។ ពូរបស់ ស៊ីម៉ូណារី ទៅរកឃើញទួលធំល្មមមួយ រួចហើយកាប់ឆ្ការកូនឈើ និងរៀបចំប្រក់តង់កៅស៊ូ ។ ពូរបស់គាត់បានកាប់ស្លឹកឈើគ្របលើតង់បន្ថែមដើម្បីកុំឲ្យក្តៅ និងការពារខ្យល់ ព្រោះគាត់មានកូនតូចៗពីរនាក់ស្នាក់នៅជាមួយ ដែលពេលនោះកូនស្រីច្បង ទើបតែអាយុ៧ឆ្នាំ និងកូនស្រីពៅអាយុ៥ឆ្នាំប៉ុណ្ណោះ ។

## យាយស្លាប់

រយៈពេលមួយអាទិត្យក្រោយមក យាយរបស់ ស៊ីម៉ូណារី ដែលស្នាក់នៅវត្តដូវមាន់ ចាប់ផ្តើមធ្លាក់ខ្លួនឈឺដោយសារអត់



កន្លែងកប់សាកសពរបស់យាយ ស៊ីម៉ូណារី នៅក្បែរដើមក្រសាំង

អាហារ និងដោយសារជំងឺ ។ យាយរបស់ ស៊ីម៉ូណារី បានស្លាប់នៅក្នុងវត្ត មុនពេលដែល ស៊ីម៉ូណារី ទៅដល់ ។ ស៊ីម៉ូណារី និង តា បានយកយាយរបស់គាត់ទៅកប់នៅក្នុងបរិវេណជាប់របងវត្តប៉ែកខាងលិច រួចហើយយកតារបស់គាត់ទៅរស់នៅខ្ទមវិញ ។ គ្រួសាររបស់ ស៊ីម៉ូណារី មិនមានអ្វីហូបទេ ព្រោះរយៈពេលមួយខែអង្គការចែកអង្ករឲ្យតែមួយកំប៉ុងប៉ុណ្ណោះក្នុងមួយគ្រួសារ ។ដូច្នេះហើយ ទើបពូរបស់គាត់បានចេញដើររកអាហារផ្សេងៗដែលអាចហូបបាន យកមកឲ្យគ្រួសារ ។ ចំណែក ស៊ីម៉ូណារី ដែលមានចរិតដូចក្មេងប្រុស និងរបិលរប៉ូចតាំងពីកំណើត បានដើរទៅកន្លែងយោធា រួចហើយសុំគាស់យកគល់ចេក និងដើរបេះដើមក្រសាំងទាប និងផ្កាកំប្លោក យកមកបបរហូប ។ ក្រោយមក ទើបអង្គការដើរចែកបបរឲ្យហូបតាមគ្រួសារវិញ ។

## អ្នកបន្ទាប់

គ្រួសាររបស់ ស៊ីម៉ូណារី ស្នាក់នៅលើទួលបានរយៈពេលបីខែ តារបស់ ស៊ីម៉ូណារី ចាប់ផ្តើមធ្លាក់ខ្លួនឈឺធ្ងន់ ហើយបានស្លាប់នៅពេលនោះទៅ ។ ប៉ុន្តែនៅមុនពេលស្លាប់ ជីតារបស់គាត់បានរៀបរាប់ឈ្មោះកូនគ្រប់គ្នា ។ ពេលនោះ ស៊ីម៉ូណារី ដែលមានអាយុទើបតែ១៣ឆ្នាំប៉ុណ្ណោះ បានដើរសំពះប្រជាជនរស់នៅក្បែរគ្នាឲ្យជួយ និងសុំបានក្តារពីរសន្លឹកមកដាក់សពជីតារបស់គាត់ ។ អ្នកភូមិមួយចំនួន បានមកជួយលើកសពជីតារបស់គាត់ទៅកប់នៅទួលមួយនៅជិតកន្លែងគ្រួសារគាត់រស់នៅដែលមានចម្ងាយប្រហែលពីរស្រែ នៅខាងលិចវត្តដូវមាន់ ។

បន្ទាប់ពីជីតារបស់គាត់ស្លាប់បានរយៈពេលមួយអាទិត្យ មានប្រជាជនដែលជម្លៀសទៅពីផ្សារកំពង់ស្ពឺ និងរស់នៅក្បែរគាត់រាយការណ៍ទៅយោធាខ្មែរក្រហមថា ពូថ្លៃរបស់គាត់ត្រូវជាប្អូនរបស់ អ៊ឹង ម៉ឹង ។ ពីរថ្ងៃក្រោយមក យោធាបានមកហៅពូរបស់គាត់ទៅភ្នំពេញ ប៉ុន្តែពេលនោះ មីងរបស់គាត់បានសួរបញ្ជាក់វិញថា ទៅភ្នំពេញធ្វើអ្វី? ទើបយោធានោះប្រាប់ថា អង្គការហៅឲ្យទៅធ្វើការ ។ ចាប់តាំងពីពេលនោះមក ពូរបស់គាត់បានបាត់ខ្លួនរហូត ។

មកដល់ដើមខែមករា ឆ្នាំ១៩៧៦ អង្គការបានឲ្យគ្រួសាររបស់ ស៊ីម៉ូណារី ដែលនៅសល់មនុស្សតែប្អូននាក់ប៉ុណ្ណោះ គឺ



កន្លែងកប់សាកសពរបស់តា ស៊ីម៉ូណារី



*សាលាឆាន់ វត្តផ្លូវមាន់ ស្ថិតក្នុងឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់*

*ស៊ីម៉ូណារី មីងរបស់គាត់ និងកូនពីរនាក់ (ប្អូនជីដូនមួយ) ឲ្យចេញពីខ្ទមមករស់នៅជាមួយប្រជាជនថ្មី ក្នុងរោងបណ្ដោយប្រមាណ ៤០ម៉ែត្រ ក្នុងភូមិអារ៉ែនជើងភ្លើង ឃុំស្នាមព្រះ វិញ ។ រយៈពេលបួនខែក្រោយមក អង្គការបំបែក ស៊ីម៉ូណារី ឲ្យទៅនៅក្នុងកងចល័ត មីងរបស់គាត់នៅកងវ័យកណ្ដាល ចំណែកប្អូនជីដូនមួយគាត់ពីរនាក់ទៀតនៅក្នុងកងកុមារ ។ តែប្អូនជីដូនមួយគាត់នៅក្នុងកងកុមារមិនបានពីរខែផង ក៏ធ្លាក់ខ្លួនឈឺហើម ទើបអង្គការបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យភូមិ ។*

*នៅរៀងរាល់ល្ងាច ពេលត្រឡប់មកពីធ្វើការ ស៊ីម៉ូណារី តែងឃើញប្អូនជីដូនមួយគាត់ដែលហើមលិចពេញខ្លួនស្ទើរមើលមិនស្គាល់នៅក្នុងបរិវេណពេទ្យ ។ ប៉ុន្តែបីថ្ងៃក្រោយ ស្រាប់តែបាត់ប្អូនជីដូនមួយគាត់ ទើបគាត់ទៅសួរមនុស្សនៅក្បែរពេទ្យនោះ ទើបដឹងថា ប្អូនជីដូនរបស់គាត់ទាំងពីរនាក់ស្លាប់អស់ហើយ ។ មីងរបស់ ស៊ីម៉ូណារី បានខូចចិត្តយ៉ាងខ្លាំង រហូតដល់គាត់លែងចង់ធ្វើការងារដែលអង្គការដាក់ឲ្យពេលដឹងថាកូនគាត់ស្លាប់ ។*

## **អ្នកចុងក្រោយ**

*នៅវេលាថ្ងៃមួយ ពេលសម្រាកថ្ងៃត្រង់ ស៊ីម៉ូណារី បានទៅលួចមើលរបៀបចងសំណាប ដែលកងចល័តចងទុករួចជាស្រេច ។ ស្រាប់តែនៅពេលរសៀលប្រធានកងបានប្រើឲ្យគាត់ទៅដកសំណាប ។ ស៊ីម៉ូណារី មិនស្ទាត់ជំនាញក្នុងការដកសំណាបទេ ដូច្នេះហើយទើបពេលគាត់បោកសំណាបម្ដងៗខ្ទាតប្រឡាក់ពេញខ្លួនគាត់វិញ តែគាត់អាចចងកណ្ដាប់បាន ។ ឃើញដូច្នេះ ឈ្លបខ្មែរក្រហមដែលតាមដានគ្រួសារគាត់យូរហើយ បាននិយាយមកកាន់គាត់ថា មិត្ត! មិត្តនារីឯង! ជាកូននាយទុន និងសក្ដិភូមិមែន? ស៊ីម៉ូណារី បានឆ្លើយតបវិញថា នាយទុនម៉េច! សក្ដិភូមិម៉េច! បើខ្ញុំមិនដែលស្គាល់ផង ។ ស៊ីម៉ូណារី បាននិយាយបន្តដោយកុហកថា និយាយអីចឹងខុសហើយ មិត្តបង! ខ្ញុំអ្នកក្រ ទើបខ្ញុំមកស៊ីឈ្នួលអ៊ុង ម៉ុង ហ៊្វុង ដើម្បីយកលុយរៀន ។*

*នៅក្នុងអំឡុងរដូវវស្សា ឆ្នាំ១៩៧៧ មីងរបស់ ស៊ីម៉ូណារី ត្រូវបានអង្គការចាត់តាំងឲ្យទៅស្ទូង ដោយនៅរាល់ពេលស្ទូងម្ដងៗ មីងរបស់គាត់តែងស្ទូងបត់គល់សំណាបធ្វើឲ្យអណ្ដែតពេញស្រែ ។ ស៊ីម៉ូណារី ដឹងថាពីមុនមីងរបស់គាត់មិនធ្វើដូច្នោះទេ តែ*

ដោយសារគាត់អស់សង្ឃឹមដោយសារតែបាត់បង់កូន ប្តី បងប្អូន និងឪពុកម្តាយ ។ ថ្ងៃមួយ ពេលមីងរបស់គាត់កំពុងស្ទូង យោធាខ្មែរក្រហមបីនាក់បានចាប់មីងរបស់គាត់ រួចហើយវាយគាត់នឹងដំបងដើមសង្កែរហូតដល់ស្លាប់នៅក្នុងស្រែតែម្តង ដោយចោទគាត់ថា ជាខ្មាំង បន្ទាប់មកហៅកងចល័តដកស្ទូងក្បែរនោះឲ្យមកមើលខ្មាំងប្រឆាំងនឹងអង្គការផ្ទាល់នឹងភ្នែកទៀត ។ ប៉ុន្តែ គ្មានប្រជាជនណាម្នាក់ចង់មកមើលមីងរបស់គាត់ទេ ព្រោះតក់ស្លុត និងអាណោចអាធ័មជាពន់ពេក ។ ស៊ីម៉ូណារី ដែលកំពុងតែរែកកណ្តាប់ បានមើលហេតុការណ៍យោធាវាយមីងរបស់គាត់រហូតធ្វើឲ្យគាត់តក់ស្លុតនិយាយស្តី និងដើរទៅមុខលែងរួច ។ ភ្លាមនោះ ឈ្លបខ្មែរក្រហមម្នាក់បានចង្អុលមកកាន់គាត់ រួចហើយស្រែកថា នេះហើយគំរូ! អ្នកប្រឆាំងនឹងអង្គការ! រហូតដល់អង្គការវាយជួងឲ្យកងចល័តឡើងហូបបបរ ទើប ស៊ីម៉ូណារី ហ៊ានដើរទៅលើកសពមីងរបស់គាត់ពីក្នុងទឹកយកទៅកប់នៅជិតកន្លែងកូនរបស់គាត់ស្លាប់ជិតមន្ទីរពេទ្យនៅភូមិអាវ៉ែនដើងភ្នឹង ដោយមានប្រុសៗក្នុងកងចល័តបួននាក់ជួយផង ។

## ជីវិតតែលតោល



រូបរាប់ពីឆ្វេង ៖ ម្តាយបង្កើតរបស់ ស៊ីម៉ូណារី ញ៉ែម យិន , ស៊ីម៉ូណារី និងប្តី អឿ អ៊ីល ក្នុងពេលធ្វើបុណ្យឧទ្ទិសកុសលជូនយាយតា និងសាច់ញាតិ នៅវត្តដូវមាន ឆ្នាំ២០០៧

ចាប់តាំងពីមីងស្លាប់ទៅ ស៊ីម៉ូណារី ត្រូវរស់នៅតែម្នាក់ឯង ។ ក្រោយមក អង្គការបានបញ្ជូនគាត់ឲ្យទៅនៅក្នុងកងពិសេសទាំងគាត់មិនទាន់គ្រប់អាយុផង ដែលខុសពីក្មេងផ្សេងទៀតធ្វើការនៅក្នុងកងកុមារ ។ អង្គការបានកំណត់ឲ្យ ស៊ីម៉ូណារី ដកសំណាបឲ្យបានមួយស្ទឹក (៨០០កណ្តាប់) ក្នុងមួយថ្ងៃ និងត្រូវធ្វើកិច្ចការផ្សេងទៀតតាមការចាត់តាំង ។ ប៉ុន្តែ ដោយសារមានការអាណិតអាសូរគាត់ ទើបអ្នកធ្វើការក្នុងកងពិសេសដែលមានវ័យចំណាស់ហើយដកសំណាបលឿនបានលួចយកកណ្តាប់ខ្លះមកឲ្យគាត់ដើម្បីបង្គ្រប់ចំនួន ។ ទន្ទឹមនឹងនោះ ក៏មានអ្នកដើររាប់កណ្តាប់ខ្លះជួយលាក់បាំងការខ្វះខាតរបស់គាត់ដែរ ។

ស៊ីម៉ូណារី ធ្វើការនៅក្នុងភូមិបានមួយរយៈ អង្គការបានបញ្ជូនគាត់ឲ្យទៅកាប់ឆ្ការព្រៃនៅរំលេច ដើម្បីដាំអំពៅ ។ នៅទីនោះអង្គការមិនចែកបាយឲ្យហូបទេ តែគាត់អាចបេះផ្លែគុយ ផ្លែភ្ញៀវ និងផ្លែឈើផ្សេងទៀត ដែលដុះនៅក្នុងព្រៃយកមកហូបបាន ។ ចាប់តាំងពីពេលនោះមកទើប ស៊ីម៉ូណារី ស្គាល់ផ្លែឈើព្រៃ ។ ស៊ីម៉ូណារី នៅរំលេចបានប្រាំមួយខែ គឺរហូតមកដល់ខែវស្សាទើបអង្គការបញ្ជូនគាត់ឲ្យមកធ្វើស្រែនៅក្នុងភូមិអាវ៉ែន ក្នុងឃុំស្នាមព្រះវិញ ។ ប៉ុន្តែមុននឹងចាត់តាំងឲ្យចុះទៅស្រែ អង្គការឲ្យគាត់នៅជួយវាល់បបរយកទៅចែកឲ្យចាស់ៗនៅតាមផ្ទះមួយរយៈសិន ។ ស៊ីម៉ូណារី បានឃើញមនុស្សជាច្រើននាក់ដេកស្តូកស្តឹងនៅក្នុងខ្ទម និងមួយចំនួនបានស្លាប់ មុនពេលគាត់យកបបរទៅដល់ទៅទៀត ។ ប៉ុន្តែ គាត់ត្រូវតែឡើងទៅដាស់អ្នកទាំងនោះដើម្បីឲ្យដឹងថា នៅរស់ ឬស្លាប់ ។

## គុកយោធា

កន្លះខែក្រោយមក ស៊ីម៉ូណារី បានទៅធ្វើការនៅកងដកស្ទូងវិញ ដោយគាត់ទទួលបានតែបបររាវប៉ុណ្ណោះ ។ ដូច្នេះពេលឡើងពីស្ទូង ស៊ីម៉ូណារី និងកងចល័តជាច្រើននាក់ទៀតបានទៅគាស់កំណាត់ដំឡូងដែលសេសសល់នៅក្នុងចម្ការ ។ ពេលនោះ ស៊ីម៉ូណារី ក៏បាននិយាយឡើងថា «មិនដែលមកគាស់ដំឡូងប៉ុណ្ណោះ យកទៅដាក់គុកទេ ។ កាលពីដើមជីតាខ្ញុំដាំនៅចម្ការអង្គសិរី ហើយដឹកទាំងឡានៗ មិនមែនមកខ្វះដំឡូងមួយដុំទេ» ។ ស្រាប់តែក្រោយមកឈ្លបខ្មែរក្រហមដឹង និងបានហៅកងចល័តទាំងអស់មកសួររកមុខអ្នកគាស់ដំឡូង ។ ក្នុងចំណោមអ្នកគាស់ទាំងអស់ មិនមាននរណាម្នាក់ហ៊ានលើកដៃទេ គឺមានតែស្ត្រីម្នាក់អាយុជាង៥០ឆ្នាំ និងកុមារ

ម្នាក់មានឪពុកធ្វើទាហានពាក់សក្តិ៥ រួមទាំង ស៊ីម៉ូណារី លើកដៃបង្ហាញ ព្រោះគាត់គិតថា បើគាត់សម្តែងការស្មោះត្រង់ អង្គការនឹងអនុគ្រោះគាត់ និងឲ្យគាត់ហូបឆ្អែតមិនខាន ។

បន្ទាប់មកឈ្លបបានបញ្ចប់ការប្រជុំ ដោយប្រាប់ថា អ្នកមិនស្មោះត្រង់នឹងអង្គការ! អ្នកមិន (លើកដៃ) ត្រូវចុះទៅសួនវិញ ចំណែកអ្នកស្មោះ! ទៅហូបបាយ ។ ឈ្លបបាននាំ ស៊ីម៉ូណារី និងកងចល័តពីរនាក់ទៀតទៅហូបបបរនៅរោងបាយ ។ ពេលហូបរួច ឈ្លបខ្មែរក្រហមបានយក ស៊ីម៉ូណារី និងអ្នកទាំងពីរនាក់ទៀតទៅដាក់ខ្នោះជើងនៅកន្លែងយោធាដែលស្ថិតនៅជិតផ្លូវរទេះភ្លើងរយៈពេលបីម៉ោងទើបដោះលែង តែឲ្យរស់នៅក្នុងបរិវេណគុកដដែល (បច្ចុប្បន្ន ស្លាកស្នាមគុកនោះស្ថិតនៅចម្ងាយប្រហែល១០០ម៉ែត្រ ខាងកើតសាលាឃុំស្នាមព្រះ ស្រុកបាកាន) ។ បន្ទាប់មក យោធាខ្មែរក្រហមដែលមានសប្បុរស ខ្ពស់ បានឲ្យ ស៊ីម៉ូណារី រួមជាមួយអ្នកទោសប្រុសស្រី ដែលជាប់ឃុំនៅទីនោះស្រាប់ជាច្រើននាក់ទៀតទៅឈរតម្រៀបជួរ រួចហើយយករំពាត់វាយអ្នកទាំងនោះម្នាក់ម្តងៗ ។ ពេលមកដល់វេន ស៊ីម៉ូណារី ស៊ីម៉ូណារី បានលើកដៃសំពះយោធានោះរួច ហើយយំអង្វរថា "ខ្ញុំខ្លាចរំពាត់ណាស់! កុំវាយខ្ញុំ!" ទើបយោធានោះព្រមអនុគ្រោះ ។ បន្ទាប់ពីវាយរួច យោធាខ្មែរក្រហម បានឲ្យអ្នកទោសទាំងអស់ចេញទៅដកស្រះ និងកាប់ដីដំបូក ដោយចែករបបបបរតែមួយវែកប៉ុណ្ណោះក្នុងមួយពេល ។ ដូច្នេះ រាល់ពេលចេញទៅធ្វើការម្តងៗ យោធាខ្មែរក្រហមដែលបានអនុគ្រោះដល់ ស៊ីម៉ូណារី តែងតែមកលួចខ្សឹបប្រាប់ ស៊ីម៉ូណារី ឲ្យលួចបេះស្លឹកថ្នឹង និងផ្លែអំពិលខ្ចីហូបថែមទៀត ។ ថ្ងៃមួយ យោធាម្នាក់នោះបាននិយាយមកកាន់ ស៊ីម៉ូណារី ថា ខ្ញុំដឹងហើយមិត្តនារីឯង! មិនមែនជាកូនអ្នកក្រទេពីមុនមក ប៉ុន្តែមិត្តនារីឯងទ្រាំទៅ ស្រុកយើងមិនមែននៅអឺចឹងរហូតទេ ។

## ខ្លាំងអង្គការ

នៅយប់មួយ ពេល ស៊ីម៉ូណារី កំពុងដេកស្រាប់តែឈ្លបខ្មែរក្រហមចូលមកយកកុមារីម្នាក់ (លួចគាស់ដំឡូងជាមួយគាត់) ទៅបាត់ ។ លុះព្រឹកឡើង យោធាខ្មែរក្រហមដែលយាមនៅមន្ទីរឃុំឃាំងនោះប្រាប់ ស៊ីម៉ូណារី ឲ្យយកខោអាវកុមារីនោះទុកស្លៀកពាក់វិញ ព្រោះអង្គការយកទៅហើយ ។ ស៊ីម៉ូណារី ភិតភ័យយ៉ាងខ្លាំងពេលឮពាក្យនេះ ។ មានថ្ងៃមួយ ពេលមេឃភ្លៀងខ្លាំង អង្គការបានប្តូរកង ស៊ីម៉ូណារី ពីដកស្រះយ៉ាងជ្រៅ ឲ្យចេញទៅលើកភ្លឺស្រែវិញ ។ ឆ្លៀតពេលដែលឈ្លបខ្មែរក្រហម ដែលអត់ងងុយ និងយាមនៅឆ្ងាយពីកង ទើបយុវជនម្នាក់នៅក្នុងក្រុមជាមួយគ្នាដែលស្រេកឃ្លានខ្លាំង បានឡើងបេះផ្លែអំពិលហូប និងបេះផ្លែមួយចំនួនទម្លាក់មកឲ្យ ស៊ីម៉ូណារី និងអ្នកផ្សេងទៀតដែលនៅខាងក្រោមដើម ។ ស្រាប់តែរំពេចនោះ យោធាខ្មែរក្រហមក្រឡេកឃើញ ក៏ស្ទុះរត់យ៉ាងលឿនឡើងទៅចាប់យុវជននោះ ។ ដោយភិតភ័យខ្លាំងពេក យុវជននោះ បានលោតចុះពីលើដើមអំពិលតែម្តង តែត្រូវយោធាខ្មែរក្រហមចាប់បាន រួចហើយយកកាំបិតចាក់និងពុះទ្រូងយុវជននោះក្រោមដើមអំពិលស្លាប់ភ្លាម ។ បន្ទាប់មកយោធានោះឲ្យកងចល័តប្រុសៗ អូសយុវជនយកទៅកប់ចោល ។ ស៊ីម៉ូណារី រន្ធត់ និងតក់ស្លុតយ៉ាងខ្លាំងពេលឃើញការសម្លាប់ដ៏សាហាវនោះ ។

## ការងារថែមម៉ោង

ក្រៅពីដកស្រះ និងកាប់ដីដំបូក យោធាខ្មែរក្រហមបានដឹកត្រីពីបឹងទន្លេសាបទាំងឡានៗមកឲ្យ ស៊ីម៉ូណារី និងអ្នកទោសទាំងអស់វះធ្វើជាងៀត ។ មានថ្ងៃខ្លះ ខ្មែរក្រហមដឹកត្រីមកច្រើន ដូច្នេះ ស៊ីម៉ូណារី ត្រូវធ្វើរហូតដល់ជិតភ្លឺក៏មាន ហើយពេលព្រឹកគាត់ត្រូវចេញទៅធ្វើការទៀត ។ ពេលខ្លះគាត់ វែកដីទាំងបិទភ្នែកដោយសារតែគាត់មិនបានដេកនៅពេលយប់ ។

នៅចុងឆ្នាំ១៩៧៨ អង្គការបានបញ្ជូន ស៊ីម៉ូណារី ឲ្យទៅធ្វើស្រែពង្រោះនៅជិតបឹងទន្លេសាប ។ ប៉ុន្តែនៅទីនោះបានមួយរយៈ គាត់បានធ្លាក់ខ្លួនឈឺជំងឺគ្រុនចាញ់ ទើបអង្គការបញ្ជូនគាត់ឲ្យមកព្យាបាលនៅមន្ទីរពេទ្យស្រុកបាកាន ។ ក្រោយពី ស៊ីម៉ូណារី បានធូរស្បើយបន្តិចហើយ អង្គការបានចាត់តាំងគាត់ទៅនៅកងឃ្វាលគោនៅភូមិស្វាយអាត់វិញ ។ ក្រៅពីឃ្វាលគោ អង្គការឲ្យគាត់ជួយធ្វើចម្ការ និងដីកប្រឡាយ ។

## សភាពការណ៍ការប្រែប្រួល

នៅថ្ងៃមួយ ស៊ីម៉ូណារី បានឮស្នូរគ្រាប់កាំភ្លើងល្វើយៗ ស្រាប់តែពេលនោះ ខ្មែរក្រហមបានកៀរគាត់ឲ្យទៅបឹងទន្លេសាបវិញ ។ រៀងរាល់យប់ អង្គការបានចាត់តាំង ស៊ីម៉ូណារី ឲ្យយាម

ដោយឲ្យគាត់កាន់កាំបិតផ្គាក់មួយ ព្រោះមានសភាពការណ៍ប្របូកប្របល់ ។ ប៉ុន្តែពេលយាមម្តងៗ គាត់តែងតែលួចដេកដោយសារតែអត់ងងុយខ្លាំង ។ នៅទីនោះ ស៊ីម៉ូណាវី បានស្គាល់ក្មេងប្រុសម្នាក់ឈ្មោះ ប៉ែត ដែលម៉ែឪត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលអស់ ។ ក្មេងប្រុសនោះរស់នៅក្នុងកងកុមារ ហើយមានអាហារហូបច្រើនជាង ស៊ីម៉ូណាវី ។ លុះបានឃើញ ស៊ីម៉ូណាវី ក្មេងប្រុសនោះមានចិត្តអាណិត ស៊ីម៉ូណាវី ដោយតែងតែលួចពួតបាយប៉ុនកដៃយកមកឲ្យគាត់ហូបរាល់ល្ងាច ។ ស៊ីម៉ូណាវី បានសួរទៅ ប៉ែត ថា ម៉ែអ៊ូ⁺ង នៅស្រុកណា? ប៉ែត ប្រាប់ថា នៅភ្នំពេញ ទើប ស៊ីម៉ូណាវី រាប់អានគ្នា ហើយយក ប៉ែត មកនៅជាមួយមុនពេលរត់ប្រសេចប្រសាច ។

ក្រោយមក ស៊ីម៉ូណាវី ពុស្ទូរកាំភ្លើងលាន់ព្ញកាន់តែខ្លាំង គាត់ និង ប៉ែត បានរត់ទៅតាមមនុស្សប្រុសស្រីគ្រប់ទិសទី យកតែរួចខ្លួន ។ ទីបំផុត ស៊ីម៉ូណាវី និង ប៉ែត បានទៅដល់បាត់ដំបង តែមិនស្គាល់បាត់ដំបងទេ រហូតទាល់តែគេប្រាប់ ។ នៅទីនោះមិនធ្វើការងាររអ៊ីទេ គឺនាំគ្នាដាំបាយហូបតែរៀងៗខ្លួន ដោយនាំគ្នាយកអង្ករពីឃ្លាំងក្បែរនោះ ។ នៅទីនោះ ស៊ីម៉ូណាវី និង ប៉ែត បានរស់នៅតាមផ្លូវក្រោមម្លប់ដើមឈើប្រហែលមួយសប្តាហ៍ រួចធ្វើដំណើរតាមថ្មើរជើងត្រឡប់មកខេត្តពោធិ៍សាត់ជាមួយគេឯងដោយមិនដឹងទិសដៅ (នៅពេលនោះមានក្រុមខ្មែរក្រហមរស់នៅឡូកឡំគ្នានៅឡើយ) ។

នៅពេលមកដល់ខេត្តពោធិ៍សាត់ ស៊ីម៉ូណាវី និង ប៉ែត បានស្នាក់នៅពីរយប់នៅឃ្លាំងអង្ករ ម្តុំត្រើយខាងកើតនៃស្ពានពោធិ៍សាត់ ទើបបានជួបនិយាយជាមួយមនុស្សប្រុសស្រីពីរនាក់ដែលត្រូវជាបងប្អូននឹងគ្នា ។ គាត់ទាំងពីរនាក់ បានស្រែកសួរ ស៊ីម៉ូណាវី ថា មិត្តវី! ស្រុកកំណើតមិត្តវី អ្នែងនៅណា? ស៊ីម៉ូណាវី ឆ្លើយថា ស្រុកកំណើតខ្ញុំនៅកើត ព្រោះគាត់ខ្លាចខ្មែរក្រហមមិនហ៊ានឆ្លើយត្រង់ ។ បងប្អូនពីរនាក់បានប្រាប់ ស៊ីម៉ូណាវី ថា វៀតណាមចូលមកហើយ ។ ឮដូច្នេះ ស៊ីម៉ូណាវី តបទៅវិញថា កុំនិយាយផ្តេសផ្តាស់ ប្រយ័ត្នអង្គការយកទៅដាក់ឡ ព្រោះខ្មែរក្រហមបានបង្កើតឡមួយឡើងសម្រាប់ដុតអ្នកទោសដែលអង្គការចោទថា ក្បត់ដែលប្រជាជនទូទៅហៅថា “ឡដុតមនុស្ស” ។ ដោយសារយើងមានទិសដៅរួមគ្នាពីរនាក់បងប្អូននោះបានបបួល ស៊ីម៉ូណាវី និង ប៉ែត ឲ្យរួមដំណើរជាមួយ ហើយឲ្យយកអង្ករក្នុងទៃមកដាក់លើរទេះរបស់គាត់រួចហើយធ្វើដំណើររួមគ្នាមកភ្នំពេញ ។

## ឃើញតែស្លាក

ស៊ីម៉ូណាវី ធ្វើដំណើររយៈពេលពីរខែទើបមកដល់ភ្នំពេញ ។ ស៊ីម៉ូណាវី បានដើរទៅរកផ្ទះដែលគាត់ធ្លាប់រស់នៅ និងផ្ទះអ៊ំពូមីងរបស់គាត់អស់រយៈពេលមួយថ្ងៃ ។ តែគាត់ឃើញតែស្លាកដែលមានសរសេរអក្សរសម្គាល់ព្យួរនៅខាងមុខផ្ទះថា “ស្លាប់” ប៉ុណ្ណោះ ។ ចំណែកអ្នករួមដំណើរជាមួយគាត់ពីរនាក់បងប្អូនបានជួបជុំបងប្អូនរបស់គេ នៅពោធិ៍ចិនតុងវិញ ។ ទន្ទឹមនោះ មានស្ត្រីម្នាក់ (ដែលមិនដែលស្គាល់គ្នា) មកសុំយក ប៉ែត ពី ស៊ីម៉ូណាវី ទៅចិញ្ចឹមវិញ ដោយប្រាប់ថា គាត់គ្មានបងប្អូន កូនចៅរស់នៅជាមួយទេ ។ ដោយរកបងប្អូនមិនឃើញ និងគ្មាននរណាអាចពឹងពាក់បាន ស៊ីម៉ូណាវី ក៏សម្រេចចិត្តឲ្យ ប៉ែត ទៅនៅជាមួយស្ត្រីនោះដោយគិតថា គាត់អាចរកអនាគតឲ្យ ប៉ែត បានព្រោះឃើញគាត់មានស្ថានភាពធូរធា ដែលធ្វើឲ្យ ស៊ីម៉ូណាវី នៅតែសោកស្តាយរហូតមកដល់សព្វថ្ងៃនេះ ។

## ជីវិតថ្មី

រយៈពេលពីរខែក្រោយពីមកដល់ក្រុងភ្នំពេញ ស៊ីម៉ូណាវី បានជួបនឹងអ៊ំស្រីថៃ (ប្រពន្ធរបស់ អ៊ុង ធូរ៉ង) ធ្វើជាបុគ្គលិកពេទ្យនៅមន្ទីរពេទ្យទឹកល្អក់ ។ ស៊ីម៉ូណាវី បានរស់នៅជាមួយអ៊ំ ដោយពេលនោះគាត់បានចូលធ្វើការនៅក្នុងមន្ទីរពេទ្យនោះដែរ ។ ក្រោយមក ម្តាយចុងរបស់ ស៊ីម៉ូណាវី និងកូនៗ (ប្អូនៗ ស៊ីម៉ូណាវី) ដែលរស់នៅកំពង់ស្ពឺ ក៏បានតាមរក ស៊ីម៉ូណាវី ហើយបានជួបគ្នានៅភ្នំពេញ ។ នៅពេលនោះហើយទើប ស៊ីម៉ូណាវី ដឹងតាមប្អូនប្រាប់ថា ឪពុកគាត់ត្រូវបានខ្មែរក្រហមបញ្ជូនទៅលើកទំនប់អាងត្រពាំងថ្ម ក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ហើយឈ្លបខ្មែរក្រហមយកគាត់ទៅសម្លាប់នៅគុម្ពជ្រឹស្លូង មុនពេលខ្មែរក្រហមដួលរលំបន្តិច ។

នៅឆ្នាំ១៩៨២ ស៊ីម៉ូណាវី បានចេញទៅរស់នៅជំរំសាយធូ ក្នុងគោលបំណងទៅរកបងជីដូនមួយដែលត្រូវជាកូនរបស់ អ៊ុង ម៉ុង នៅស្រុកបារាំង ។ ប៉ុន្តែពេលទៅដល់ជំរំ ការគ្រប់គ្រងនៅទីនោះ

មានការតឹងតែង ហើយស្ត្រីភៀសខ្លួនខ្លះក៏ត្រូវទាហានថៃចាប់រំលោភ និងខ្លះទៀត ត្រូវបានសម្លាប់យកមាស, ពេជ្រ និង ទ្រព្យសម្បត្តិ ។ ក្នុងស្ថានភាពបែបនេះ ស៊ីម៉ូណារី ពុំដឹងរកទំនាក់ទំនងរកបងប្អូនជីដូនមួយយ៉ាងណានោះទេ ហើយមិនយូរប៉ុន្មាន ទើបគាត់បានចូលធ្វើការជាមួយអង្គការសមាគមនារីផ្នែកសង្គមសង្គ្រោះ ដែលមានការសហការជិតស្និទ្ធជាមួយអង្គការ យូ.អិន.ប្រូ (*UNBRO* ឬ ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន) នៅជំរំបុទ្ធិសែន ។

ស៊ីម៉ូណារី ធ្វើការនៅជំរំ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៩១ ហើយនៅពេលនោះជាពេលរៀបចំធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួនតាមព្រំដែន ទើបគាត់ដាក់ពាក្យសម្ភាសដើម្បីមកធ្វើការនៅក្នុងប្រទេសកម្ពុជាដោយមកធ្វើការជាមួយអង្គការ ហូលត៍ (*HOLT*) នៅមណ្ឌលទទួលជនភៀសខ្លួនកប់ស្រូវ នៅភ្នំពេញ ដើម្បីចូលរួមចំណែកជួយជនពិការ ជនចាស់ជរា និងជនគ្មានទីពឹងក្នុងដំណើរមាតុភូមិនិវត្តន៍បានទៅជួបជុំគ្រួសារ សាច់ញាតិនៅស្រុកកំណើតរៀងៗខ្លួនវិញ ។ ក្រោយមក ស៊ីម៉ូណារី ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀត រហូតដល់ឆ្នាំ២០១២ ទើបគាត់ផ្លាស់មកធ្វើការនៅក្នុងក្រុមហ៊ុនឯកជនមួយដែលប្រធានក្រុមហ៊ុននោះត្រូវជាបងជីដូនមួយខាងម្តាយគាត់ ។

នៅឆ្នាំ២០០៧ ស៊ីម៉ូណារី បានត្រឡប់ទៅរកកន្លែងដែលគាត់ធ្លាប់រស់នៅ និងផ្ទះយាយ តា មីង និងប្អូនជីដូនមួយរបស់គាត់ ប៉ុន្តែ ទោះបីគាត់ខិតប្រឹងប្រែងយ៉ាងណា ក៏គាត់មិនអាចចំណាំទីតាំងផ្ទះឲ្យបានច្បាស់លាស់ដែរ ។ ដូច្នេះហើយ ទើបគ្រួសារ ស៊ីម៉ូណារី បានសម្រេចធ្វើបុណ្យនៅវត្តដូវមាន់ដោយមានពុទ្ធបរិស័ទចំណុះជើងវត្តមកចូលរួម ដើម្បីឧទ្ទិសកុសលជូនសាច់ញាតិទាំងអស់ដែលបានស្លាប់នៅទីនោះ ។

ស៊ីម៉ូណារី តែងតែនិយាយរៀបរាប់ពីប្រវត្តិរបស់គាត់ និងក្រុមគ្រួសារប្រាប់ទៅកូនៗ ព្រោះគាត់ចង់ឲ្យកូនរបស់គាត់ស្គាល់និងចងចាំពីប្រវត្តិរបស់ខ្លួនផ្ទាល់ និងប្រវត្តិ អ៊ឹ ពូ មីង និងយាយតាដែលបានស្លាប់យ៉ាងអាណោចអាធ័ម និងដោយអយុត្តិធម៌នៅក្នុងរបបខ្មែរក្រហម ។

**សោម ប៊ុនថន**



រូបទីពីរាប់ពីឆ្វេង ៖ អ៊ីង គិញ (បងប្អូនជីដូនមួយ), ស៊ីម៉ូណារី, អឿ អ៊ីល, អ៊ីង ចយ (អ៊ឹ) និង ញ៉ែម យិន ក្នុងពិធីបុណ្យកឋិន នៅវត្តដូវមាន់

# នៅតែចង់ដឹងឮពីរបបខ្មែរក្រហម


ជ័រ ដារិទ្ធិ

ជ័រ ដារិទ្ធិ ជាគ្រូបង្រៀនផ្នែកភាសាអង់គ្លេស និងគណិតវិទ្យា ។ រៀងរាល់ថ្ងៃ ដារិទ្ធិ បានជូនប្រពន្ធរបស់គាត់ ធ្វើជាគ្រូបង្រៀនផ្នែកប្រវត្តិវិទ្យា ពីផ្ទះស្ថិតនៅក្នុងឃុំរាំងចាស់ ស្រុកខត្តុគ្គ ខេត្តកំពង់ស្ពឺ មកចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពី "ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពី (ឆ្នាំ១៩៧៥ - ១៩៧៩) ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា នៅសាលាគរុកោសល្យភូមិភាគខេត្តកណ្តាល (ក្រុងតាខ្មៅ) ពីថ្ងៃទី៥ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ ។ ដារិទ្ធិ ធ្វើការនៅក្នុងកងលើកទំនប់ និងជីកប្រឡាយនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែប្រពន្ធរបស់គាត់មិនឆ្លងកាត់ការវេទនាដូចគាត់ទេ ។ ដារិទ្ធិ រៀបរាប់ថា "ក្នុងចម្ងាយផ្លូវប្រមាណ៦០គីឡូម៉ែត្រ ពីផ្ទះរបស់គាត់មកកន្លែងបណ្តុះបណ្តាលមានចម្ងាយឆ្ងាយ ប៉ុន្តែគាត់ចង់ឲ្យប្រពន្ធរបស់គាត់ដែលកំព្រាឪពុកម្តាយតាំងពីនៅតូច ហើយត្រូវបានយាយយកមកចិញ្ចឹម យល់ដឹងឲ្យកាន់តែច្បាស់ពីរបបខ្មែរក្រហម" ។

ដារិទ្ធិ មានអាយុ៥១ឆ្នាំ មានស្រុកកំណើតនៅឃុំព្រះស្រែ ស្រុកខត្តុគ្គ ខេត្តកំពង់ស្ពឺ ។ ដារិទ្ធិមានបងប្អូនចំនួន៨នាក់ ដោយមានម្តាយជាមេផ្ទះ និងឪពុកធ្វើជាប៉ូលិសនៅក្នុងសម័យសង្គមរាស្ត្រនិយម ។ ប៉ុន្តែឪពុករបស់គាត់បានផ្លាស់ពីប៉ូលិស មកនៅខាងទាហានវិញ ក្រោយពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីអំណាច ។ ក្រោយមក ដោយសារកងយោធាខ្មែរក្រហមវាយលុកចូលមកកាន់តែខ្លាំង ហើយទឹកដីស្ទើរតែទាំងស្រុងនៃស្រុកខត្តុគ្គត្រូវកងទ័ពខ្មែរក្រហមរំដោះបាន ទើបគ្រួសាររបស់ដារិទ្ធផ្លាស់ទីលំនៅ ពីឃុំព្រះស្រែ មកនៅឃុំរាំងចាស់ (បច្ចុប្បន្នទីប្រជុំជនស្រុកខត្តុគ្គ) វិញ ។

នៅឆ្នាំ១៩៧២ ឪពុករបស់ ដារិទ្ធ បាននាំក្រុមគ្រួសារទាំងអស់មកនៅបន្ទាយ ដែលរដ្ឋាភិបាល លន់ នល់ បែងចែកសម្រាប់ឲ្យគ្រួសាកងទ័ពរស់នៅ ដែលមានទីតាំងស្ថិតនៅខាងត្បូងវត្តលង្កា (បច្ចុប្បន្ន និវេសនដ្ឋានសម្រាប់មន្ត្រីទូតបរទេសស្នាក់នៅ) ក្រុងភ្នំពេញ ។ ក្នុងអំឡុងពេលនោះ ឪពុករបស់ ដារិទ្ធិ ត្រូវបានមេបញ្ជាការបញ្ជូនឲ្យទៅវាយជាមួយខ្មែរក្រហមនៅសមរភូមិគិរីរម្យ និងពេជ្រនិល ហើយក្រោយមក ទើបគាត់សុំផ្លាស់មកធ្វើការនៅខាងការិយាល័យដែលមានបន្ទាយនៅជិតវត្តស្រះចក ក្រុងភ្នំពេញវិញ ។ ឪពុករបស់ ដារិទ្ធិ ក៏បាននាំគាត់ឲ្យទៅស្នាក់នៅរៀនសូត្រជាមួយព្រះធម្មកវីវង្ស តុង ឈួន (គណៈកម្មាធិការកែសម្រួលភាសាបាលី) ស្នាក់នៅកុដិលេខ២២ ក្នុងវត្តខណ្ណា ឡោម ដែលត្រូវជាឪពុកធំ ។ ព្រះអង្គបានបង្រៀនដារិទ្ធិអំពីលេខនព្វន្តអក្សរសាស្ត្រ និងបាលី ។ ស្នាក់នៅជាមួយ ព្រះអង្គបានមួយរយៈ ដារិទ្ធិ បានចុះឈ្មោះចូលរៀនថ្នាក់ទី១២ (សង្គមចាស់) ។ ប៉ុន្តែ ដោយសារគាត់ធ្លាប់បានរៀនសូត្រពីមុនមក ទើបគ្រូបង្រៀនឲ្យគាត់រៀនផ្លោះថ្នាក់ ។

ដារិទ្ធិ បានមកលេងឪពុកម្តាយ និងបងប្អូននៅបន្ទាយក្នុងមួយអាទិត្យម្តង ។ ពេលនោះ កង យោធាខ្មែរក្រហមក៏ចាប់ផ្តើមផ្លោងគ្រាប់ចូលក្រុងភ្នំពេញស្ទើរជារៀងរាល់ថ្ងៃ ហើយគ្រួសារដារិទ្ធិ តែងនាំគ្នាចូលទៅដេកនៅក្នុងលេណដ្ឋានដែលឪពុករបស់គាត់ជីកទុកសម្រាប់ការពារគ្រាប់ផ្លោង ។ ថ្ងៃមួយ ឪពុករបស់ដារិទ្ធិ បានយកកង់ឌុបគាត់ត្រឡប់ទៅវត្តវិញ ប៉ុន្តែពេលជិះចេញផុតពីវិមានឯករាជ្យបន្តិច ស្រាប់តែខ្មែរក្រហមផ្លោងគ្រាប់ចូលមកយ៉ាងច្រើន ។ ឃើញដូច្នេះ ឪពុករបស់គាត់បានផ្តួលកង់ចោល ហើយឱបគាត់ក្រាបទៅនឹងដីរហូតដល់ស្ងប់ស្ងាត់ទើបធ្វើដំណើរបន្តទៀត ។

ដារិទ្ធិ បានរៀនរហូតដល់ថ្នាក់ទី៨ ទើបគាត់ឈប់រៀន ហើយមកនៅជាមួយឪពុកម្តាយវិញ ព្រោះសភាពការណ៍ ច្របូកច្របល់ ហើយមានប្រជាជនភៀសពីសង្គ្រាមជាច្រើនបានចូលមករស់នៅក្នុងវត្តខណ្ឌលោម រួមទាំងបងប្អូន និងប្រជាជននៅភូមិកំណើតរបស់គាត់នៅខត្តុក្កដែរ ។

នៅព្រឹក ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដារិទ្ធិ បានចេញពីផ្ទះមកឈរមើលរថក្រោះជាច្រើនគ្រឿងដែលមានចងក្រណាត់ស បើកពីស្ពានព្រះមុនីវង្សសំដៅមកវិមានឯករាជ្យ និងបានឃើញប្រជាជនជាច្រើនទះដៃអបអរ និងស្រែកហ៊ោកញ្ជ្រៀវ ។ រហូតដល់ថ្ងៃរសៀល ទើបកងយោធាខ្មែរក្រហមមកប្រាប់ឲ្យគ្រួសារគាត់ចាកចេញពីផ្ទះរយៈពេលបីថ្ងៃ ។ ឪពុកម្តាយរបស់ ដារិទ្ធិ មិនបានយករបស់របរជាប់ជាមួយខ្លួនច្រើនទេ គឺទុកនៅក្នុងផ្ទះហើយចាក់សោ រួចធ្វើដំណើរទៅជួបព្រះធម្មកវីវង្ស តុង ឈួន នៅវត្តខណ្ឌឡោម ។ គ្រួសាររបស់ ដារិទ្ធិ បានស្នាក់នៅវត្តខណ្ឌលោមបានមួយយប់ ។ ព្រឹកឡើង កងយោធាខ្មែរក្រហមបានចូលមកភ្ជង់បង្ខំឲ្យគ្រួសារគាត់ចាកចេញទៀត ដូចនេះហើយ ឪពុក ដារិទ្ធ បានទៅពិភាក្សាជាមួយព្រះអង្គ តុង ឈួន ក្នុងគោលបំណងធ្វើដំណើរតាមផ្លូវជាតិលេខ៥ (កាត់តាមក្រោមស្ពានជ្រោយចង្វារ) ត្រឡប់ទៅស្រុកកំណើតវិញ ។ ប៉ុន្តែខ្មែរក្រហមបានហាមឃាត់ ដោយបង្វែរ គ្រួសារគាត់ឲ្យដើរសំដៅទៅស្ពានព្រះមុន្នីវង្សទៅតាមផ្លូវជាតិលេខ១វិញ ។ នៅមុនពេលចាកចេញពីវត្តព្រះអង្គ តុង ឈួន បានហែកសំពត់ពណ៌លឿងរបស់ព្រះអង្គចែកឲ្យបងប្អូនរបស់ដារិទ្ធិចងជាប់នឹងក្បាលដើម្បីងាយស្រួលចំណាំ ហើយម្យ៉ាងទៀតដើម្បីការពារកុំឲ្យដើរវង្វេងគ្នា ។

នៅតាមផ្លូវ ដារិទ្ធិ ត្រូវរង់ចាំរយៈពេលបីម៉ោងទើបគាត់អាចរំកិលបានពីរម៉ែត្រ ព្រោះមានមនុស្សប្រជ្រៀតគ្នាច្រើន ។ នៅពេលនោះ ដារិទ្ធិ ឃើញមានមនុស្សស្លាប់ ដែលភាគច្រើនអ្នកមានវ័យចាស់ជរា ដែលទ្រាំទ្រនឹងការប្រជ្រៀតគ្នា និងកម្តៅថ្ងៃមិនបានកើតខ្យល់គរដួលនៅលើផ្លូវ ហើយត្រូវអ្នកដំណើរជាន់បន្ថែម ។ សាកសពមួយចំនួនត្រូវបានបងប្អូនអូសយកមកទុកចោលនៅចិញ្ចើមផ្លូវនិងសាកសពមួយចំនួនទៀតបានស្លាប់នៅក្នុងរបងផ្ទះ (ប្រហែលជាយោធាខ្មែរក្រហមបាញ់សម្លាប់) ។ ឃើញដូច្នេះ ឪពុករបស់ ដារិទ្ធិ បានបោះកាតសម្គាល់ខ្លួន ខោអាវ និងសម្ភារ ទាហានចោលទាំងអស់ ។

ដារិទ្ធិ ដើររហូតដល់ព្រលប់ទើបឆ្លងផុតស្ពានព្រះមុន្នីវង្ស ហើយធ្វើដំណើរបន្តទៅស្នាក់នៅវត្តវាលស្បូវ ។ នៅទីនោះ ឈ្លបខ្មែរក្រហមបានមកនិយាយលួងលោមអ្នកជម្លៀសទាំងអស់ដែលធ្លាប់ធ្វើជាមន្ត្រីរដ្ឋការ ប៉ូលិស ទាហាន ឲ្យទៅចុះឈ្មោះដើម្បីទៅធ្វើការនៅកន្លែងដើមវិញ ។ អ៊ំប្រុសខាងឪពុករបស់ ដារិទ្ធិ ម្នាក់ដែលធ្វើទាហានពាក់សក្តិ៣បានមកបបួលឪពុករបស់ ដារិទ្ធិ ទៅចុះជាមួយគ្នា ប៉ុន្តែត្រូវម្តាយគាត់ហាមឃាត់មិនឲ្យទៅ ។ ចាប់តាំងពីចុះឈ្មោះរួច អ៊ំប្រុសរបស់ ដារិទ្ធិ បានបាត់ខ្លួនរហូត ។ ក្រោយមក គ្រួសារ ដារិទ្ធិ បានជួលទូកប្រជាជនក្នុងតម្លៃអង្ករមួយតៅ ដើម្បីឆ្លងមកកោះប្រាក់ ដើម្បីរកផ្លូវវាងត្រឡប់ទៅស្រុកកំណើតវិញ ។ នៅពេលនោះ ដារិទ្ធិ ឃើញមានសាកសពជាច្រើនដែលដៃនៅជាប់ចំណង



ប្រពន្ធរបស់ ដារិទ្ធិ ឡើងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យសាកល្បង

អណ្តែតមកប៉ះទូករបស់គាត់ដែលធ្វើឲ្យគាត់ភ័យខ្លាចយ៉ាងខ្លាំង ។ បន្ទាប់ពីឆ្លងទឹករួច ដារិទ្ធិ ឃើញមានកងឈ្លបខ្មែរក្រហមនៅក្នុងភូមិចាំចែកអង្ករឲ្យអ្នកជម្លៀស ប៉ុន្តែមុននឹងចែក ឈ្លបទាំងនោះបាន សាកសួរពីប្រវត្តិរូប និងឆែកមើលរបស់របរជាមុនសិន ។

គ្រួសារ ដារិទ្ធិ ធ្វើដំណើររយៈពេលបីខែដោយត្រូវឆ្លងទន្លេជាច្រើន ទើបទៅដល់ស្រុកកំណើត ។ ប៉ុន្តែឈ្លបខ្មែរក្រហមមិនអនុញ្ញាតឲ្យគាត់ទៅផ្ទះនៅវាំងចាស់ទេ ព្រោះខ្មែរក្រហមទុកទីនោះធ្វើជាមន្ទីរតំបន់ ហើយឲ្យគាត់ទៅនៅភូមិអង្គរវឹង ឃុំព្រះស្រែ ស្រុកខដុង្គវិញ ។ ពេលទៅដល់ភូមិភ្លាម ឪពុករបស់គាត់បាននិយាយណែនាំឲ្យកូនៗត្រូវចេះលាក់ប្រវត្តិរូប ពេលមានអ្នកផ្សេងមកសួរនាំពីឪពុកម្តាយ ដោយប្រាប់ថា ឪពុកជាកម្មករ និងម្តាយជាអ្នកលក់បន្លែ ។ ប៉ុន្តែ ដារិទ្ធិ មិនដែលឃើញកងឈ្លប មកសួរនាំគ្រួសារគាត់ទេ ។ នៅពេលនោះ ខ្មែរក្រហម ចាត់តាំងឪពុកម្តាយរបស់ដារិទ្ធិឲ្យនៅខាងដាំបន្លែ និងផ្សាំដើមក្រូច (កងបង្កបង្កើនផល) ហើយ ដារិទ្ធិ នៅខាងឃ្វាល ចំណែកប្អូនៗរបស់គាត់ដែលនៅតូច ខ្មែរក្រហមឲ្យដើររើសអាចម៍គោ និងកាប់ទន្រ្ទានខែត្រ ។

រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានប្រមូលកុមារទាំងអស់ចូលកង ដែលមានរួមទាំង ដារិទ្ធិ ដែរ រួចហើយឲ្យទៅស្នាក់នៅវត្តអង្គសណ្តាន់ ដែលជាកន្លែងឪពុកធំរបស់គាត់ (ព្រះធម្មកវីវង្សតុង ឈួន) ស្នាក់នៅបន្ទាប់ពីជម្លៀសមកពីភ្នំពេញ ។ ឪពុកធំរបស់ដារិទ្ធិ ត្រូវខ្មែរក្រហមផ្សឹក ប៉ុន្តែគាត់នៅស្លៀកពាក់ស ហើយសូត្រធម៌នៅឡើយ ។ ខ្មែរក្រហមបានឲ្យឪពុកធំរបស់គាត់ចាកចេញពីវត្ត រួចហើយឲ្យកងកុមារឃុំព្រះស្រែ ដែលមានចំនួនប្រមាណ ៤០០នាក់ មករស់នៅវិញ ។

នៅរដូវប្រាំង ឆ្នាំ១៩៧៧ ប្រធានកងបានដឹកនាំ ដារិទ្ធិ និងកងកុមារទាំងអស់ឲ្យទៅលើកទំនប់ក្រពើទ្រោម ស្ថិតនៅឃុំវាលពង្ស ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ជាមួយកងមនុស្សចាស់ ។ ក្រុមរបស់គាត់ដែលមានសមាជិកប្រមាណជិត១០នាក់បានបែកចេញទៅដេកនៅផ្ទាល់នឹងដីនៅមាត់អូរ ព្រោះនៅក្នុងកងមានមនុស្សច្រើន ។ នៅទីនោះដារិទ្ធិ ត្រូវលើកទំនប់ដែលមានជើងទេកម្ពស់៤ម៉ែត្រ និងពុំមានម្លប់សម្រាប់ជ្រកទេ ។ ដោយក្តៅខ្លាំងពេក ទើបគាត់យកភួយដែលអង្គការចែកឲ្យដណ្តប់មកទទូរ ចំណែកទឹក គាត់ពុំមានទឹកស្អាតផឹកទេ គឺគាត់ផឹកតែទឹកដែលដក់នៅតាមដានជើងក្របី និងទឹកអូរដែលល្អក់ ។

ក្រោយពីលើកទំនប់ក្រពើទ្រោមរួច កងកុមាររបស់ ដារិទ្ធិ បានផ្លាស់មកនៅឃ្លាំង៥វិញ ដែលមានចម្ងាយប្រមាណប្រាំគីឡូម៉ែត្រពីផ្ទះរបស់គាត់ ។ នៅទីនោះ ដារិទ្ធិ មានភារកិច្ចលើកភ្លឺស្រែថ្មីដែលប្រធានកងបែងចែកឲ្យលើកក្នុងស្រែមួយទំហំមួយរយម៉ែត្របួនជ្រុង (មួយហិកតា) រួចហើយរំលាយ ភ្លឺស្រែចាស់ចោល (ភ្លឺស្រែតូចដែលបន្សល់ពីសម័យមុន) ។ ដារិទ្ធិ មានការលំបាកយ៉ាងខ្លាំងពេលគាត់លើកប៉ះចំដំបូក ឬដើមព្រៃឈើ ព្រោះប្រធានកងមិនអនុញ្ញាតឲ្យគាត់លើកភ្លឺស្រែវាងទេ គឺគាត់ត្រូវកាប់រំលាយដំបូកចាក់ចូលក្នុងស្រែ រួចហើយត្រូវគាស់រំលើងដើមឈើទៀត ។ បន្ទាប់ពីលើកភ្លឺស្រែ ប្រធានកងឲ្យគាត់កាប់ដី ពីកន្លែងដែលមានដីទួលមកចាក់នៅកន្លែងទំនាបដើម្បីងាយធ្វើស្រែ ចំណែករបបអាហារ គឺគាត់ទទួលបានតែបបរបីវែកប៉ុណ្ណោះក្នុងមួយពេល ។ ដោយសារហូបមិនគ្រប់ ដារិទ្ធិ និងកុមារនៅក្នុងកងជាមួយគ្នាបានលួចចេញទៅរើសខ្យងពេលម៉ោងធ្វើការយកមកស្ងោរក្នុងមួកទាហានដើម្បីហូបថែមទៀត ។ លើសពីនោះ នៅពេលចេញពីធ្វើការម្តងៗ ដារិទ្ធិ និងកុមារផ្សេងទៀតតែងតែ ដើរទៅរើសត្នោតទុំយកទៅឲ្យចាស់ៗដុតឲ្យហូបថែមទៀត រហូតដឹងឮដល់ប្រធានកងធំ ។

ថ្ងៃមួយ កុមារនៅក្នុងកងម្នាក់ឈ្មោះ សុខ ដែលជាកូនអ្នកមូលដ្ឋាន បានដើរនាំផ្លូវកុមារនៅក្នុងកងទាំងអស់វាងទៅរើសត្នោតទុំ រួចហើយហុចបណ្តាក់គ្នាទៅឲ្យអ្នកខាងក្រោយកាន់ដើម្បីយកទៅឲ្យចាស់ៗដុតហូប ។ ប៉ុន្តែពេលនោះ ប្រធានកងតូចដែលមិនបានហូបត្នោតនោះ ក៏បានរាយការណ៍ទៅប្រធានកងធំ ។ នៅពេលប្រជុំប្រធានកងធំបានហៅ សុខ មកសួរនាំ និងធ្វើទារុណកម្មដោយវាយជាច្រើនដំបង ចំណែក ដារិទ្ធិ ក៏ត្រូវប្រធានកងវាយដែរ ។

នៅឆ្នាំ១៩៧៨ ដារិទ្ធិ បានផ្លាស់ទៅលើកទំនប់អកពង ស្ថិតនៅក្នុងស្រុកពញាឮ ខេត្តកណ្តាល ដោយគាត់ត្រូវធ្វើដំណើរថ្មើរជើងក្នុងចម្ងាយផ្លូវប្រវែងជាង១០គីឡូម៉ែត្រ ។ ដារិទ្ធិ មានការលំបាកក្នុងការរែកដីឡើងលើទំនប់ ព្រោះទំនប់មានកម្ពស់រហូតដល់

ជិត១០ម៉ែត្រ ។ ចំណែករបបអាហារគាត់មិន បានហូបគ្រប់គ្រាន់ទេ ។ ដូច្នេះពេលទំនេរ គាត់និងមិត្តភក្តិដែលពូកែចាប់កណ្តុរបាន លួចចេញទៅជីករន្ធកណ្តុរនៅតាមវាលស្រែ រួចហើយលួចរះយកទៅហាលនៅលើដើមឈើដែលដុះក្នុងបឹង ។ ពេលខ្លះ ដារិទ្ធិ បានដើរទៅរកពស់ព្រលិត និងអណ្តើកនៅតាមវាលបឹងដែលឆេះឆ្អិន ដោយសារប្រជាជនដុតព្រៃនាម ។ នៅទីនោះ ដារិទ្ធិ បានជួបនឹងបងប្រុសរបស់គាត់ដែលកំពុងធ្វើដំណើរមកពីដកមើមឈូកពីក្នុងបឹងដែលបានបែកគ្នាតាំងពីគាត់ចូលកងកុមារ នៅដើមឆ្នាំ១៩៧៧ ។ នៅពេលនោះបងប្រុសរបស់ដារិទ្ធិ បានប្រាប់ដារិទ្ធិថា គាត់ធ្វើការនៅកងដុតធ្យូង និងបានសួរ ដារិទ្ធិ ពីសុខទុក្ខឪពុកម្តាយនៅភូមិ រួចហើយបានឲ្យមើមឈូកមួយចំនួនមក ដារិទ្ធិ ទើបបែកគ្នា ។

មួយរយៈក្រោយមក មានអ្នកនៅក្នុងកងម្នាក់បានមកប្រាប់ ដារិទ្ធិ ថា ឪពុករបស់គាត់ត្រូវអង្គការផ្លាស់ពីកងបង្កបង្កើនផល នៅក្នុងភូមិឲ្យមកធាក់រហាត់ទឹកបញ្ចូលស្រែប្រាំង ។ ព្ធដូច្នេះ គាត់បានទៅតាមរកឪពុកគាត់រហូតដល់វាលស្រែប្រាំង នៅបឹងស្រួយ ។ ដារិទ្ធិ ឃើញឪពុកមានរូបរាងស្គមស្គាំង ហើយដោយសារអាណិតឪពុកខ្លាំងពេក ទើបក្រោយមកគាត់លួចយករបបរបស់គាត់ទៅចែកឲ្យឪពុកហូប ។

នៅចុងឆ្នាំ១៩៧៨ កងរបស់ ដារិទ្ធិ បានផ្លាស់មកនៅខត្តុង្កវិញ នៅពេលខ្មែរក្រហមចាត់តាំង គណៈតំបន់ថ្មីមកដឹកនាំ ។ ស្របពេលនោះ ដារិទ្ធិ ឃើញការរស់នៅចាប់ផ្តើមផ្លាស់ប្តូរដែរ ព្រោះខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជននៅតាមភូមិអាចដាំបន្លែដំឡូង និងពោតហូបខ្លួនឯងបាន ។ នៅថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ពេល ដារិទ្ធិ កំពុងធ្វើការនៅវាលស្រែ ស្រាប់តែឮសំឡេងគ្រាប់ផ្លោង ប៉ុន្តែមេកងរបស់គាត់ស្រែកបញ្ឈារទៅសមាជិកទាំងអស់មិនឲ្យចេញពីកង ។ ទោះបីហាមឃាត់យ៉ាងណា ក៏ដារិទ្ធិ បានលួចទៅខ្សិបប្រាប់ប្អូនប្រុសរបស់គាត់ ដែលធ្វើការនៅក្នុងកងជាមួយគ្នារត់ទៅរកឪពុកម្តាយនៅភូមិដែរ ។ ស្អែកឡើង ប្រធានកងក៏រត់គេចខ្លួនបាត់ ហើយ ដារិទ្ធិ ក៏ត្រឡប់ទៅដល់ផ្ទះវិញនៅពេលព្រលប់ ប៉ុន្តែពេលនោះឪពុកម្តាយរបស់គាត់ភៀសខ្លួនចេញអស់ហើយ ។ ដារិទ្ធិ ភិតភ័យយ៉ាងខ្លាំង តែជាសំណាងល្អ អ្នកភូមិមួយគ្រួសារបានឲ្យបាយគាត់ហូប និងនាំគាត់ទៅរកឪពុកម្តាយ ។ ដារិទ្ធិ ជួបជុំឪពុកម្តាយ និងបងប្អូននៅបឹងខ្យាង ស្រុកខត្តុង្ក ។ ក្រោយមក ខ្មែរក្រហមបានកៀរគ្រួសារគាត់ទៅស្រុកថ្ពង តែត្រូវកងទ័ពវៀតណាមវាយស្ទាក់ រួចឲ្យគ្រួសារគាត់ត្រឡប់មករស់នៅក្នុងរស់ភូមិវិញ ។ ដារិទ្ធិ បានចុះឈ្មោះចូលរៀនឡើងវិញ ហើយនៅឆ្នាំ១៩៨៧ គាត់បានប្រលងជាប់គ្រូមធ្យមសិក្សា ។

នៅឆ្នាំ១៩៨៨ ដារិទ្ធិ បានចេញទៅបង្រៀននៅអនុវិទ្យាល័យសំរោង ស្ថិតនៅក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ នៅពេលនោះ ដារិទ្ធិ ត្រូវជិះកង់ទៅបង្រៀន ប៉ុន្តែដោយសារផ្លូវឆ្ងាយ ហើយលំបាក គាត់ក៏សុំព្រះចៅអធិការវត្តស្នាក់នៅជាមួយ ។ ព្រះអង្គក៏បានអនុញ្ញាត តែឲ្យ ដារិទ្ធិ ទៅស្នាក់នៅផ្ទះមួយដែលនៅឆ្ងាយពីកុដិ ដែលផ្ទះនោះជាផ្ទះរបស់ស្ត្រីមេម៉ាយម្នាក់ចងកសម្លាប់ខ្លួន ហើយដោយលង់អ្នកភូមិ ទើបអ្នកភូមិសែងយកមកប្រគល់ឲ្យវត្ត ។ ប៉ុន្តែក្រោយមកដោយព្រះអង្គអាណិតស្រឡាញ់ ដារិទ្ធិ ទើបហៅ ដារិទ្ធិ មកស្នាក់នៅកុដិក្បែរព្រះអង្គវិញ ។ ទោះបីយ៉ាងណា នៅទីនោះ ដារិទ្ធិ ក៏នៅមានការភ័យខ្លាចដែរ ព្រោះខាងកងយោធាខ្មែរក្រហម (កាលនោះដឹកនាំដោយ កែវ ពង្ស) តែងតែផ្លោងគ្រាប់ដាក់ និងចូលមកព័ទ្ធប្រជាជននៅក្នុងភូមិ ។

ថ្ងៃមួយពេល ដារិទ្ធិ កំពុងបង្រៀន ព្រះគ្រូចៅអធិការវត្តបានឲ្យសិស្សរបស់ព្រះអង្គមកហៅ ដារិទ្ធិ ឲ្យត្រឡប់ទៅកុដិវិញ ហើយប្រាប់យាយជីម្នាក់នាំផ្លូវ ដារិទ្ធិ ទៅលាក់ខ្លួនក្នុងផ្ទះប្រជាជននៅក្នុងភូមិ ព្រោះយោធាខ្មែរក្រហមចូលមកកៀកហើយ ។ ពេលនោះ ដារិទ្ធិ បានរត់ចូលទៅពួននៅពំនូកចំបើង ព្រោះខ្លាចខ្មែរក្រហមចាប់ខ្លួនបាន ។

រហូតដល់ឆ្នាំ១៩៩៤ ទើប ដារិទ្ធិ សុំក្រសួងផ្លាស់មកបង្រៀននៅវិទ្យាល័យខត្តុង្កវិញ រួចហើយបានរៀបការប្រពន្ធ ។ បច្ចុប្បន្នដារិទ្ធិមានកូនស្រីពីរនាក់កំពុងសិក្សានៅសាកលវិទ្យាល័យមួយនៅក្នុងក្រុងភ្នំពេញ ។ ចុងក្រោយ ដារិទ្ធិ បាននិយាយថា "ទោះបីគាត់មិនមែនជាគ្រូប្រវត្តិសាស្ត្រខ្មែរក្រហមក៏ដោយ ក៏គាត់នៅតែពេញចិត្តមុខវិជ្ជានេះ ហើយនៅតែចង់ដឹង និងចង់ឮថែមទៀតពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ព្រោះជារបបដែលគាត់ធ្លាប់បានឆ្លងកាត់ផ្ទាល់" ។

**សោម ប៊ុនថន**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthpechet@dccam.org ។

**◆ ទីកន្លែង ៖ អាគារ "ក" ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។























# ខែមេសា





# ឆ្នាំ១៩៧៥



# ខែមេសា











# ឆ្នាំ២០១៤











# ការរត់គេចពីអំពើយង់ឃ្នងរបស់ខ្មែរក្រហម សាច់រឿងរបស់ជនភៀសខ្លួនកម្ពុជារត់ទៅប្រទេសលាវ

## *សេចក្តីផ្តើម*

*នៅពេលដែលទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា-ឡាវ ត្រូវបានពង្រឹង ហើយត្រូវបានរក្សាក្នុងរបបគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជនភៀសខ្លួនកម្ពុជានៅតាមព្រំដែនប្រទេសឡាវត្រូវបានស្វាគមន៍ ហើយការរត់គេចរបស់ប្រជាជននៅតាមព្រំដែនប្រទេសកម្ពុជា មិនត្រូវបានយកចិត្តទុកដាក់ហើយមិនអាចធ្វើការពន្យល់បកស្រាយបាន ។ ក្នុងអំឡុងពេលនៃវេទិកាអប់រំសាធារណៈតាមភូមិដែលរៀបចំឡើងដោយគម្រោងឃ្លាំមើលយុត្តិធម៌របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៤ អ្នកភូមិប្រមាណ២០០នាក់មកពីឃុំព្រះរំកិល ខេត្តស្ទឹងត្រែង បានរាយការណ៍ថា ការប្រព្រឹត្តយ៉ាងឃោរឃៅរបស់ខ្មែរក្រហមមកលើប្រជាជនបានបង្ខំមនុស្សជាច្រើនឲ្យរត់គេចទៅប្រទេសឡាវ ។ រឿងហេតុនេះបានកើតឡើងនៅពាក់កណ្តាលនៃទសវត្សរ៍៧០ ហើយបន្តរហូតដល់ដើមសម័យខ្មែរក្រហម ។ សាច់រឿងរបស់ជនភៀសខ្លួនទាំងនោះ បានក្លាយជាការបញ្ជាក់យ៉ាងច្បាស់អំពីអំពើឃោរឃៅរបស់ខ្មែរក្រហម ។ ជនភៀសខ្លួនទាំងនោះ មិនមានជម្រើសនោះទេ ប៉ុន្តែត្រូវស្វែងរកជម្រកនៅកន្លែងផ្សេងដើម្បីរស់រានមានជីវិត ។ ការ*



*សាលាឆាន់ វត្តជីរស ស្ថិតនៅឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង កន្លែងរៀបចំវេទិកាសាធារណៈស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ*

ពិតជាប្រវត្តិសាស្ត្រនៃតំបន់នេះមិនត្រូវបានកត់សម្គាល់សម្រាប់ផ្នែកជាច្រើន ។ កុមារជាច្រើន ដែលកើតក្រោយរបបខ្មែរក្រហម បានកត់សម្គាល់តិចតួច ឬគ្មានយល់ទាល់តែសោះ អំពីប្រវត្តិសាស្ត្រនៃតំបន់នេះ ។ ដោយសារក្រុមនៃគម្រោងវេទិកាអប់រំសាធារណៈតាមភូមិ បានចុះទៅឃុំរយៈពេលបីថ្ងៃ ក្រុមការងារនៃគម្រោងនេះបានសម្របសម្រួលឲ្យមានវាគ្មិនប្រាំនាក់ ដែលបានជួបប្រទះការធ្វើចំណាកស្រុកដែលប្រថុយប្រថានដល់ជីវិតដើម្បីពិភាក្សាជាមួយសិស្សជាច្រើនអំពីប្រវត្តិសាស្ត្រ និងដំណើរនីតិវិធីជំនុំជម្រះនៅតុលាការខ្មែរក្រហម ។ ក្រុមការងារនៃគម្រោងនេះ ព្យាយាមស្វែងរកជនភៀសខ្លួនមួយចំនួនមកពីភូមិនីមួយៗក្នុងចំណោមភូមិទាំង៨របស់ឃុំ ។ ក្នុងរបាយការណ៍នេះ មានការសួរដេញដោលអំពីប្រវត្តិរបស់ជនភៀសខ្លួនទាំងនោះ ។ ហើយបន្ទាប់មកមានការធ្វើចំណាប់អារម្មណ៍ពីអ្នកភូមិនិងសិស្ស ។

## *វេទិកា ៖ ស្ថានភាពរបស់ជនភៀសខ្លួនកម្ពុជាក្នុងប្រទេសឡាវ*

*នៅព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៤ ប្រជាជន សិស្ស គ្រូ និងចាស់ព្រឹទ្ធាចារ្យ បានប្រមូលផ្តុំគ្នានៅវត្តដើម្បីចូលរួមក្នុងកិច្ចពិភាក្សាសាធារណៈ ។ នៅពេលដែលប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានពិភាក្សាជាទូទៅ ការគេចខ្លួនរបស់ជនភៀសខ្លួនកម្ពុជាចូលប្រទេសឡាវត្រូវបានយកចិត្តទុកដាក់ ដោយសារឃុំព្រះរំកិលនៅជិតទឹកដីប្រទេសឡាវ ។ អាជ្ញាធរប្រទេសឡាវបានជួយ និងផ្តល់ជំនួយដើម្បីផ្តល់ជម្រកជនភៀសខ្លួន ដោយសារប្រទេសឡាវបានរក្សាទំនាក់ទំនងល្អរបស់ខ្លួនជាមួយរបបកម្ពុជាប្រជាធិបតេយ្យ ។ យោងតាមសៀវភៅរបស់ ណាយ៉ាន់ ចិនដា មានចំណងជើងថា “សត្រូវបងប្អូនឯង ៖ សង្គ្រាមបន្តបន្ទាប់គ្នា” អគ្គរាជទូតឡាវ កាមដាន វីឡាចឹត និងសហសេវិក៦នាក់របស់គាត់ បានស្នាក់នៅក្នុងបរិវេណស្ថានទូត ហើយមិនបានដឹងអ្វីអំពីសង្គ្រាមដែលនឹងមកដល់ ហើយក្រោយមក ត្រូវបានស្គាល់ថា ជាកងកម្លាំងវៀតណាម ។ ទន្ទឹមពេលដែល កិច្ចការងារការទូតគឺជានិមិត្តរូបនោះ ប្រទេសឡាវមិនទំនងជាចាត់វិធានការមនុស្សធម៌សម្រាប់ជនភៀសខ្លួនកម្ពុជានោះទេ ។*

*ភាពជោគជ័យរបស់របបខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រូវបានមើលឃើញថាជាចំណុចចាប់ផ្តើមសម្រាប់ផលវិបាករបស់ប្រជាជនកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ មនុស្សភាគច្រើននៅតាមទីជនបទប្រទេសកម្ពុជា កំពុងទទួលរងការឈឺចាប់ចាប់តាំងពីរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ ខ្មែរក្រហមពង្រីកកងកម្លាំងរបស់ខ្លួន ហើយបានត្រួតត្រាផ្នែកជាច្រើននៃតំបន់ជនបទ ដោយបណ្តាលឲ្យមានការជម្លៀសនៅដើមទសវត្សរ៍៧០ ។ ឃុំព្រះរំកិលក៏មិនមានសភាពខុសគ្នាដែរ ។ អ្នកចូលរួមក្នុងវេទិកានេះ បានគូសបញ្ជាក់អំពីកត្តាជាច្រើនស្តីពីការធ្វើចំណាកស្រុក ។*

*ទី១) ខ្មែរក្រហមបានចាប់ផ្តើមគាំទ្រឲ្យមានការធ្វើកសិកម្មសមូហភាពនិងទ្រព្យសម្បត្តិរួម បានធ្វើឲ្យប្រជាជនយ៉ាងច្រើនខឹងសម្បា ទន្ទឹមពេលដែលភាពអសន្តិសុខបានធ្វើឲ្យប្រជាជនទាំងនោះរត់គេចខ្លួន ។ ឧទាហរណ៍ លោក យ៉ាន់ ស៊ុនតាក ដែលជាជំទប់ឃុំ បានចងចាំអំពីការប្រយុទ្ធគ្នារវាងខ្មែរក្រហម និងទាហានលន់ នល់ និងការដកហូតសិទ្ធិប្រជាជនកាន់កាប់ទ្រព្យសម្បត្តិ ។*

*ទី២) ខ្មែរក្រហមបានបង្កើតភាពភ័យខ្លាច និងការគំរាមកំហែងនៅដើមពាក់កណ្តាលទសវត្សរ៍៧០ ។ ក្នុងសម្លៀកបំពាក់ស្អាតបាត លោកស្រី លាង ជៀង មានអាយុ៦៥ឆ្នាំ មកពីឃុំ*



លាង ជៀង

*ព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង បាននិយាយថា គាត់រត់គេចទៅប្រទេសឡាវនៅក្នុងខែមីនា និងខែមេសា ក្នុងឆ្នាំ១៩៧២ ពីព្រោះការរត់គេចទៅប្រទេសឡាវរបស់ឪពុកគាត់ទំនងជាធ្វើឲ្យសមាជិកគ្រួសារទាំងអស់ស្ថិតក្នុងគ្រោះថ្នាក់នៃការសម្លាប់ ។ ជៀង មានការភិតភ័យ ហើយសម្រេចចិត្តចាកចេញទៅប្រទេសលាវ ។ សម្រាប់ហេតុផលនេះ ជៀង បានប្រាប់អ្នកចូល*

រួមក្នុងវេទិកានេះថា ខ្លួនបានសម្រេចចិត្តដើរអស់រយៈពេលពីរម៉ោងពីឃុំព្រះរំកិលដល់ចំណុចព្រំដែន ។ ដៀង និងបីក្រុមគ្រួសារផ្សេងទៀត បានឆ្លងកាត់ព្រំដែនហើយហែលឆ្លងកាត់ទន្លេមេគង្គនៅលើកោះសណ្តែតនៅម៉ោង៧យប់ ហើយបានចូលក្នុងដែនដីប្រទេសឡាវនៅម៉ោង១១យប់ ។ បន្ទាប់ពីបានជួបអ្នកនេសាទជនជាតិលាវមួយចំនួន ដៀង ត្រូវបាននាំទៅភូមិ ។ ដំបូង ដៀង មិនអាចស្វែងរកព័ត៌មានណាមួយអំពីសាច់រឿងរបស់ខ្លួននៅតាមព្រំដែននោះទេ ។ ប៉ុន្តែ ដៀង ក្រោយមកបានយល់ដឹងថា មានមនុស្សជាច្រើនបានឆ្លងកាត់ព្រំដែន ។ ដៀង មានការភ័យខ្លាចដែលថា អ្នកភូមិផ្សេងដែលរត់គេចពីកន្លែងដូចគ្នានោះអាចធ្វើបាបគ្រួសាររបស់ខ្លួន ដោយសារមានមនុស្សជាច្រើនអាចជាប់ពាក់ព័ន្ធចាប់ខ្លួន និងត្រូវគេធ្វើឲ្យបាត់ខ្លួន ។

ទី៣) ខ្មែរក្រហមបានធ្វើការសម្លាប់រង្គាលក្នុងសហគមន៍របស់ខ្លួន ទន្ទឹមពេលដែលការបង្អត់អាហារមានការរាលដាល ។ ដៀង បានចងចាំអំពីស្ថានភាពដ៏ល្អនៅពេលដែលគាត់នៅប្រទេសឡាវ ។ ជនភៀសខ្លួនទាំងអស់ត្រូវបានស្វាគមន៍ និងបានផ្តល់អាហារនិងសិទ្ធិដើម្បីជ្រកកោនបណ្តោះអាសន្ន ។ ដៀង បានស្នាក់នៅជាមួយមិត្តភក្តិរបស់គាត់ឈ្មោះថា យាយ កុង ។ ដៀង ចិញ្ចឹមជីវិតតាមរយៈការនេសាទនៅដងទន្លេប្រទេសឡាវ នៅពេលដែលគាត់សម្លឹងមើលភូមិរបស់គាត់ពីចម្ងាយ ។ ជារឿយៗ ដៀង បានឃើញមនុស្សពាក់សម្លៀកបំពាក់ខ្មៅនៅតាមភ្នំនៅខាងប្រទេសកម្ពុជា ។ នៅក្នុងវេទិកានោះ ដៀង បានបង្ហាញពីការទោមនស្សចំពោះការដែលថា រយៈពេល៦ខែបន្ទាប់ពីការរត់គេច អ្វីៗគ្រប់យ៉ាងមានសភាពស្ងប់ស្ងាត់នៅក្នុងប្រទេសកម្ពុជា ។ គ្មាននរណាម្នាក់បានដឹងអំពីអ្វីដែលបានកើតឡើងនោះទេ ។ អ្នករត់ភៀសខ្លួនទាំងនោះត្រូវបានដឹងថា បានរត់គេចខ្លួនទៅប្រទេសឡាវ ។ ប៉ុន្តែគាត់ឆ្ងល់ថា តើហេតុអ្វីបានជាខ្មែរក្រហមមិនយកគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ ។ ត្រង់ចំណុចនេះ អាជ្ញាធរប្រទេសឡាវ អាចជួយលាក់កំបាំងជនភៀសខ្លួនកម្ពុជាពីការសម្លាប់របស់កម្មាភិបាលខ្មែរក្រហមដែលជាជនជាតិលាវ ។ នៅក្នុងប្រទេស លាវ ដៀង



ឃុំកំពង់ស្រឡៅ១ ស្រុកឆែប ខេត្តព្រះវិហារ ជាប់ទៅនឹងខេត្តចម្ប៉ាសាក់ ប្រទេសឡាវ

មានអារម្មណ៍ថា មានការកាប់សម្លាប់បានកើតឡើងនៅក្នុងទឹកដីកំណើតរបស់ខ្លួន ។ ជាអកុសល ជៀង មិនអាចជួបជាមួយឪពុករបស់ខ្លួន ។ ជាច្រើនខែ ក្រោយមក គាត់បានទទួលដំណឹងថា មានការធ្វើបាបមនុស្សនៅក្នុងតំបន់របស់ខ្លួនក្នុងប្រទេសកម្ពុជា ។ អាជ្ញាធរប្រទេសឡាវ បានព្រមានមនុស្សគ្រប់គ្នាមិនឲ្យឆ្លងកាត់ចូលក្នុងប្រទេសកម្ពុជា ។ ប្រធានភូមិជនជាតិលាវ ជារឿយៗបានទៅសួរសុខទុក្ខជនភៀសខ្លួន ។ ឃឹម ផុន មានអាយុ៨១ឆ្នាំ មកពីឃុំព្រះរំកិល បានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីកម្មាភិបាលជនជាតិលាវ ឈ្មោះ ឡាង អូលូយ ។

ទន្ទឹមពេលដែលជនភៀសខ្លួនជាច្រើននៅក្នុងប្រទេសឡាវ មានការសង្ស័យចំពោះការកាប់សម្លាប់ប្រជាជននៅក្នុងរបបខ្មែរក្រហម ជនភៀសខ្លួនជាច្រើនបានយល់ឃើញថា អ្នកទាំងអស់គ្នាពិបាកក្នុងការរត់គេច ដោយសារតែមានការការពារព្រំដែនយ៉ាងមុតមាំរបស់ខ្មែរក្រហម ។ យោងតាម ហួន អ៊ឹម អាយុ៧១ឆ្នាំ រស់នៅឃុំព្រះរំកិល បាននិយាយថា ប្រជាជនដែលរស់នៅក្បែរព្រំដែន ដែលអាចនិយាយភាសាលាវ ត្រូវបានជម្លៀសទៅកន្លែងដទៃ ស្របពេលដែលប្រជាជន ដែលមិនចេះភាសាលាវត្រូវបានយកចេញ ។ ទោះបីជាយ៉ាងនេះក៏ដោយ សំ ឃីត កើតក្នុងឆ្នាំ១៩៥៣ ក្នុងឃុំព្រះរំកិល បានធ្វើដំណើរដោយផ្សងគ្រោះថ្នាក់ពីភ្នំពេញមកប្រទេសឡាវ ។

នៅក្នុងវេទិកានោះ ឃីត បាននិយាយថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់បានចូលក្នុងស្ថានទូតបារាំង ដោយសារគាត់ស្គាល់មន្ត្រីមួយចំនួននៅក្នុងស្ថានទូតនោះ ។ គាត់បានឃើញជនបរទេសជាច្រើននៅទីនោះ ។ បន្ទាប់មក ខ្មែរក្រហមបានចូលក្នុងស្ថានទូត ហើយបញ្ជាឲ្យប្រជាជនខ្មែរចាកចេញទៅផ្សារថ្មី ។ មានឡានធំចំនួន៣ដឹកប្រជាជនកម្ពុជាចាកចេញពីស្ថានទូត ។ នៅពេលរសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៥ ឃីត ជាមួយនឹងអ្នកដទៃដែលមានដៃជាប់ចំណងបត់ទៅក្រោយ ត្រូវបានដឹកតាមឡានចេញក្រៅ ។ ឃីត ចងចាំថា មនុស្សនៅក្នុងឡាន២ ខាងដើមត្រូវបានបាញ់សម្លាប់ ។ ប៉ុន្តែ មនុស្សក្នុងឡានរបស់គាត់ត្រូវវាយសម្លាប់ ហើយរុញទម្លាក់ចូលក្នុងអណ្តូងទឹក ។ មនុស្សគ្រប់គ្នាត្រូវបានបញ្ជាឲ្យលុតជង្គង់នៅមុខអណ្តូងទឹក ។ ឃីត ជាមនុស្សម្នាក់ក្នុងចំណោមជនរងគ្រោះទាំង២ ចុងក្រោយដែលត្រូវសម្លាប់ ។ គាត់ត្រូវវាយចំក្បាលដោយដំបងដែក ។ បន្ទាប់មក ជនរងគ្រោះទាំងអស់ត្រូវបានបាញ់សម្លាប់ដើម្បីធ្វើឲ្យប្រាកដថា ពួកគេទាំងអស់បានស្លាប់ ។ ជាសំណាងល្អ ឃីត បានរស់រានមានជីវិត ប៉ុន្តែខ្មែរក្រហមបានយកគម្របដែកទៅគ្របលើអណ្តូង ។ ឃីត បានព្យាយាមជាច្រើនដងដើម្បីឡើងចេញពីអណ្តូង ។ នៅពាក់កណ្តាលយប់ ខ្មែរក្រហមមួយចំនួនបានមកត្រួតពិនិត្យម្តងទៀត ។ ឃីត បានវារឡើងចេញពីអណ្តូងដោយជោគជ័យ បន្ទាប់ពីខ្មែរក្រហមត្រួតពិនិត្យរួច ។ បន្ទាប់មក គាត់បានលាក់ខ្លួននៅក្នុងផ្ទះ ដោយសារប្រជាជនត្រូវបានជម្លៀសចេញ ។

ឃីត បានប្រាប់អ្នកចូលរួមថា នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានមកហើយសួរថាតើមានមនុស្សនៅក្នុងផ្ទះថ្មដែលគាត់កំពុងលាក់ខ្លួននោះទេ ។ ឃីត ឆ្លើយថា “បាទ” ។ បន្ទាប់មក គាត់បានចេញពីផ្ទះហើយដើរតាមអ្នកដទៃនៅថ្ងៃនោះ ។ គាត់បន្តដើរទៅមុខ ។ ក្រោយមកគាត់បានធ្វើដំណើររួមជាមួយនឹងប្តីប្រពន្ធចំណាស់មួយគូ ហើយបានមកដល់គីឡូម៉ែត្រលេខ៦នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ។

ឃីត បានបន្តនិយាយថា នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥



សំ ឃីត

គាត់បានឆ្ពោះទៅកាន់ព្រែកក្តាម ហើយក្រោយមកខ្មែរក្រហមត្រឡប់ក្រោយ ។ ខ្មែរក្រហមបានបញ្ជាអ្នកជម្លៀសទាំងអស់ជិះស្រឡាង ហើយបន្តដើរទៅខេត្តកំពង់ចាម ។ គាត់បានចំណាយពេលជាច្រើនខែដើម្បីទៅដល់ខេត្តស្ទឹងត្រែង ហើយបានទៅដល់ទីនោះនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៥ ។ គាត់ត្រូវបានជម្លៀស

*ទៅកោះស្នាមចិយ ប៉ុន្តែគាត់បានរត់គេចពីស្នាមចិយជាមួយមនុស្សប្អូននាក់ផ្សេងទៀត ។ មនុស្សទាំង៤នាក់បានសម្រេចចិត្តទៅរស់នៅជាមួយសាច់ញាតិរបស់ខ្លួនក្នុងឃុំព្រះរំកិល ខណៈដែល ឃីត សម្រេចចិត្តដកថយទៅចូលក្នុងព្រៃវិញ ។ ក្រោយមក គាត់បានយល់ឃើញថា អ្នកទាំងនោះត្រូវបានសម្លាប់ ។ គាត់ត្រូវចំណាយពេលអស់បីយប់ ហើយបានឆ្លងកាត់ទន្លេមេគង្គ និងបានមកដល់ប្រទេសឡាវ ។*

*ពេលដែលគាត់បានចូលទឹកដីប្រទេសឡាវ នៅខែមេសា ឆ្នាំ១៩៧៥ អាជ្ញាធរក្នុងតំបន់បានសួរ ថាតើគាត់គឺជាកម្មាភិបាល ឬទេ ។ បន្ទាប់មកគាត់ត្រូវបានបញ្ជូនឲ្យទៅរស់នៅជាមួយប្រជាជនក្នុងតំបន់ ហើយប្រទេសឡាវទទួលបានសេរីភាពនៅខែធ្នូ ឆ្នាំ ១៩៧៥ ។ កម្មាភិបាលលាវ ផា សាយ បានប្រាប់ ឃីត ថានៅពេលដែលប្រទេសទាំង២មានសន្តិភាព ជនភៀសខ្លួនទាំងអស់ត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសកម្ពុជាវិញ ។*

*ទោះបីជាយ៉ាងណាក៏ដោយ ឃីត បានជំទាស់ហើយបាននិយាយថា ប្រសិនបើគាត់ត្រូវបានបញ្ជូនត្រឡប់វិញ គាត់នឹងត្រូវសម្លាប់ ។ បន្ទាប់មក សាយ បានបញ្ជូនកម្មាភិបាលមួយក្នុងចំណោមកម្មាភិបាលរបស់គាត់ទៅប្រទេសកម្ពុជា ហើយក៏ត្រូវបានសម្លាប់ ។ បន្ទាប់មក សាយ ជឿជាក់លើការអះអាងរបស់ ឃីត ។ អាជ្ញាធរជនជាតិលាវ បានអនុញ្ញាតឲ្យ ឃីត រស់នៅបណ្តោះអាសន្ន ហើយបានផ្តល់សម្លៀកបំពាក់ និងបានចាត់តាំងឲ្យគាត់រស់នៅជាមួយគ្រួសារជនជាតិលាវ ។ ប្រទេសឡាវ ពិបាកជួយសង្គ្រោះប្រជាជនកម្ពុជាផ្សេងៗ នៅក្នុងប្រទេស ដោយសារខ្មែរក្រហមបន្តបាញ់អ្នកដែលចូលមកជិតព្រំដែន ។*

*មានប្រជាជនកម្ពុជាជាច្រើនដែលបានរត់គេចចូលក្នុងប្រទេសឡាវ ។ ជនភៀសខ្លួនទាំងអស់បានរាយការណ៍អំពីការសម្លាប់និងការបង្អត់អាហារនៅក្នុងប្រទេសកម្ពុជា ។ ឃីត បានជឿជាក់ចំពោះ ការពោលអះអាងនោះ ។ គាត់ធ្លាប់ជួបបងប្អូនប្រុសរបស់គាត់នៅប្រទេសឡាវ ។ គាត់បានរត់គេចខ្លួនកាត់តាមស្រុកសៀមប៉ាង ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាជនលាវ ពិបាកជឿទុកចិត្តចំពោះការនិយាយរបស់ជនភៀសខ្លួន ដោយសារប្រជាជនលាវបានរស់នៅដោយសុខស្រួលក្រោមការគ្រប់គ្រងរបស់ជនកុម្មុយនីស្តដោយមិនមានការកាប់សម្លាប់ បន្ទាប់ពីទទួលបានសេរីភាព ។ ជានិច្ចជាកាល គាត់បាននិយាយអំពីការកាប់សម្លាប់នៅក្នុងប្រទេសកម្ពុជាកាលគ្រានោះ ប៉ុន្តែគាត់មិនបានដឹងថាតើប្រជាជនលាវ និងអាជ្ញាធរលាវជឿជាក់លើគាត់ឬទេ ។ មិនមានបណ្តាញសារព័ត៌មានណាមួយសួរគាត់នោះទេ ។ ឃីត ជឿជាក់ថា ដោយសាររដ្ឋាភិបាលខ្មែរក្រហម និងរដ្ឋាភិបាលលាវ គឺជាជនកុម្មុយនីស្ត ហើយមិនមានគោលជំហរជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់គ្នានោះទេ ។ វាហាក់បីដូចជាផ្ទះ៣ខ្នងផ្សេងគ្នាផ្ទះកម្ពុជា ផ្ទះលាវ និងផ្ទះវៀតណាម ។ ស្ថានភាពខុសគ្នាត្រង់ថា ខ្មែរក្រហមសម្លាប់ប្រជាជន ខណៈដែលកម្មាភិបាលក្នុងរបបចាស់ក្នុងប្រទេសឡាវ ត្រូវបានយកទៅអប់រំបណ្តុះបណ្តាល និងដោះលែងហើយ បានធ្វើសមាហរណកម្មចូលក្នុងសង្គម ។ ឃីត បានប៉ាន់ប្រមាណថា ជនភៀសខ្លួនមានចំនួនរាប់ពាន់នាក់ ។ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម ជនភៀសខ្លួនជាច្រើនបានសម្រេចចិត្តត្រឡប់មកវិញ បន្ទាប់ពីប្រជាជនទាំងនោះយល់ឃើញថាខ្លួនអាចឆ្លងកាត់ព្រំដែនទៅមកជាថ្មីម្តងទៀត ។*

## ចំណាប់អារម្មណ៍ចំពោះវេទិកា

*បន្ទាប់ពីបញ្ចប់វេទិកានេះ អ្នកចូលរួមបានបញ្ចេញមតិស្នើយោបល់ និងបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោមៈ*

*ប៊ុន លីន អាយុ៧៥ឆ្នាំ មកពីភូមិកណ្តាល ឃុំព្រះរំកិល បាននិយាយថា វាជាការប្រសើរដែលយើងមានការពិពណ៌នាលម្អិតអំពីប្រវត្តិសាស្ត្រដល់ក្មេងៗជំនាន់ក្រោយ ។ វាជាការប្រសើរដែលយើងធ្វើសកម្មភាពទាំងអស់នេះ ។ ប្រជាជននៅក្នុងឃុំមិនអាចរត់គេចចូលក្នុងប្រទេសឡាវនៅដើមទសវត្សរ៍៧០នោះទេ ហើយស្ទើរតែមិនអាចរត់គេចបានក្នុងសម័យខ្មែរក្រហមនោះ ។ អ្នកដែលអាចរត់គេចបានគឺជាមនុស្សសំណាង ។ នៅពេលដែលឃើញក្មេងៗដដែកអំពីរឿងនេះ លីន សប្បាយចិត្តយ៉ាងខ្លាំង ។ លីន បានទទួលដំណឹងអំពីសវនាការតាមរយៈវិទ្យុ ហើយបាននិយាយថា “វាមានសារសំខាន់សម្រាប់ប្រជាជន” ។*

*លាង ជៀង អាយុ៦៥ឆ្នាំ មកពីឃុំព្រះរំកិល បាននិយាយថា ជាធម្មតា គាត់បានប្រាប់សាច់រឿងទៅកាន់ក្មេងៗ ។ ក្មេងៗបានជឿលើសាច់រឿងរបស់គាត់ ។ ប៉ុន្តែ ជៀង មិនបានយល់ដឹងអំពី*

*សវនាការនៅក្នុងទីក្រុងភ្នំពេញនោះទេ ។ គាត់យល់ឃើញថា វាមានសារសំខាន់សម្រាប់កូនចៅដែលរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។*

*ខាន់ រដ្ឋា អាយុ១៦ឆ្នាំ ជាសិស្សថ្នាក់ទី៩នៃវិទ្យាល័យព្រះរំកិល ក្នុងខេត្តស្ទឹងត្រែង បាននិយាយថា វេទិកានេះមានសារសំខាន់ដើម្បីរៀនសូត្រអំពីការកាប់សម្លាប់របស់ខ្មែរក្រហម និងយល់ដឹងអំពីមនុស្សមួយចំនួនអាចរត់គេចចូលក្នុងប្រទេសឡាវយ៉ាងដូចម្តេច ។ រដ្ឋា បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនចំពោះការរត់គេចរបស់ លាង ដៀង ដែលបានរត់គេចចូលក្នុងប្រទេសឡាវ ដោយការភ័យខ្លាចចំពោះការសម្លាប់ ។ រដ្ឋា បានស្នើសុំឲ្យមានកិច្ចខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់ការ កើតឡើងសាជាថ្មីនៃអំពើប្រល័យពូជសាសន៍នាពេលអនាគត ។ រដ្ឋា បានសួរថា មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់សម្ភារបន្ថែមទៅឲ្យសិស្សនៅទីនោះដែរឬទេ ។ មុនពេលមកវេទិកានេះ រដ្ឋា មានការយល់ដឹងតិចតួចអំពីប្រវត្តិសាស្ត្រ និងរបបខ្មែរក្រហម ។ រដ្ឋា បានអរគុណចំពោះក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចំពោះការជ្រើសរើសឃុំព្រះរំកិលសម្រាប់ធ្វើវេទិកា ។*

*យ៉ាន់ ស៊ុនតាក់ ជំទប់ទីមួយនៃឃុំព្រះរំកិល បាននិយាយថា វេទិកានេះគឺជាឱកាសដ៏ល្អប្រសើរសម្រាប់គាត់ចែករំលែកបទពិសោធផ្ទាល់ខ្លួនក្នុងសម័យខ្មែរក្រហមជាមួយអ្នកដទៃ ។ ការនិទានអំពីប្រវត្តិសាស្ត្រទៅកាន់មនុស្សជំនាន់ក្រោយ អាចឲ្យគាត់មានអារម្មណ៍ធូរស្រាល ។ វាជាការនិយាយអំពីរឿងពិតក្នុងរបបខ្មែរក្រហម ។ ស៊ុនតាក់ បានឲ្យតម្លៃដល់វេទិកានោះថា ជាកន្លែងដែលគាត់អាចថ្លែងអំពីទុក្ខវេទនា និងប្រាប់យុវជនអំពីសាច់រឿងពិតអំពីអំពើឃោរឃៅ ។ គាត់មានសេចក្តីសោមនស្សរីករាយចំពោះវេទិកានេះ ហើយចង់មានវេទិកានេះច្រើនជាងមុននាពេលអនាគត ។ ស៊ុនតាក់ បានស្នើជាយោបល់ថា វេទិកាបន្ទាប់គួរតែផ្តោតលើថាតើខ្មែរក្រហមចូលកាន់កាប់ប្រទេសកម្ពុជាដោយរបៀបណា ។ ពីព្រោះគាត់យល់ឃើញថា មនុស្សមួយចំនួនដែលកើតក្រោយរបបខ្មែរក្រហម មានមន្ទិលសង្ស័យចំពោះការកកើតឡើងនៃរបបនោះ ។ ស៊ុនតាក់ ជឿជាក់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងស្វែងរកយុត្តិធម៌ដល់ប្រជាជនកម្ពុជា ។*

*នី ថៃ អាយុ៧០ឆ្នាំ មកពីឃុំព្រះរំកិល បាននិយាយថា វាជាការប្រសើរដែលនាំយកប្រធានបទស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហមមកពិភាក្សា ជាពិសេសស្ថានភាពរបស់ជនភៀសខ្លួនកម្ពុជាក្នុងប្រទេសឡាវកាលនោះ ។ ថៃ តាមដានសវនាការជំនុំជម្រះមេដឹកនាំខ្មែរក្រហមដែលរស់រានមានជីវិត ។ ថៃ ចង់ឲ្យមានការបន្តការងារឆ្ពោះទៅរកការទប់ស្កាត់របបនោះដោយប្រសិទ្ធភាព ។*

*យុន វុទ្ធី អាយុ១៧ឆ្នាំ និងជាសិស្សថ្នាក់ទី៨នៃវិទ្យាល័យព្រះរំកិល បាននិយាយថា វេទិកានោះបានផ្សារភ្ជាប់រវាងការនិទានរបស់អ្នកភូមិនិងសៀវភៅដែលគាត់អាន ។ ទាំងនេះបានបញ្ជាក់សាជាថ្មីអំពីការពិតនៃរបបមួយដែលបានបណ្តាលឲ្យមនុស្សស្លាប់ជាច្រើន ។ ទោះបីជាយ៉ាងណាក៏ដោយ វុទ្ធី បានបង្ហាញការសោកស្តាយចំពោះការមិនបានតាមដានសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយខ្លួនត្រូវយកចិត្តទុកដាក់លើការរៀនសូត្រ ។*

## *សេចក្តីសន្និដ្ឋាន*

*ទោះបីជាមានស្ថានទូតប្រទេសឡាវនៅក្នុងទីក្រុងភ្នំពេញក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ - ១៩៧៩) ដែលត្រូវបានថ្កោលទោសចំពោះការស្លាប់មនុស្សជិតពីរលាននាក់ ស្ថានទូតនោះមានសភាពស្ងប់ស្ងាត់ ហើយមិនចូលពាក់ព័ន្ធក្នុងកិច្ចការងារផ្ទៃក្នុងរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាយ៉ាងណាក៏ដោយ វាបានបង្ហាញអំពីកាយវិការមួយចំពោះជនភៀសខ្លួន ដែលបានរត់គេចពីប្រទេសកម្ពុជាដើម្បីរស់រានមានជីវិត ។ ទង្វើសប្បុរស ត្រូវបានទទួលស្គាល់ដោយជនភៀសខ្លួននៅក្នុងឃុំព្រះរំកិល ។ ជនភៀសខ្លួនទាំងនោះត្រូវស្នាក់នៅជាមួយប្រជាជនលាវ ហើយបានរស់នៅផុតពីការធ្វើបាប ។ ទោះបីជាយ៉ាងណាក៏ដោយ សាច់រឿងដ៏សោកសៅដែលជនភៀសខ្លួនបានបង្ហាញនោះ គ្រាន់តែត្រូវបានស្តាប់ឮ តែមិនទទួលបានការចាត់វិធានការអន្តរាគមន៍នោះទេ ។ ដោយសារតែ មានរយៈពេលខ្លី ហើយមានមនុស្សតិចតួចចូលរួមនោះ វេទិកាសាធារណៈ អាចបង្ហាញនូវតួលេខប៉ាន់ស្មានអំពីចំនួននៃជនភៀសខ្លួនដែលរត់គេចចូលក្នុងប្រទេសឡាវ តាមរយៈប្រជាជនក្នុងតំបន់ និងអាជ្ញាធរ ។*

**លី សុខឃាង**

# ស្ថានភាពរបស់ប្រជាជនក្នុងឃុំព្រះរំកិល នៅពេលចលនាបដិវត្តន៍ចូលមកដល់ដំបូង

ការរត់ភៀសខ្លួនពីភូមិកំណើតរបស់ប្រជាជនឃុំព្រះរំកិល ទៅក្នុងទឹកដីរបស់ប្រទេសឡាវ បានចាប់ផ្ដើមតាំងពីឆ្នាំ១៩៧០ ម៉្លេះ ស្របពេលដែលថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រូវបានចងចាំជាទូទៅថាជាថ្ងៃជម្លៀសនៅទូទាំងប្រទេសដំបូងបង្អស់ ។ ដោយសារតែមានការសិក្សាស្រាវជ្រាវតិចតួចអំពីមូលហេតុផលវិបាក និងបញ្ហាប្រឈមនៃការរត់ភៀសខ្លួននេះ ទើបក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានជ្រើសរើសយកទីតាំងឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ធ្វើវេទិកាសាធារណៈមួយស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

លោក លី សុខឃាង ដែលដឹកនាំក្រុមការងារនេះ បានប្រាប់ទៅកាន់អ្នកចូលរួមទាំងអស់ឲ្យដឹងថា គោលបំណងនៃការធ្វើវេទិកានេះ គឺដើម្បីចែករំលែកនូវបទពិសោធជីវិតឆ្លងកាត់ជំនាន់ខ្មែរក្រហម និងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ នេះជាវេទិកាមួយដែលបង្កើតឱកាសសម្រាប់ការផ្សះផ្សាផ្លូវចិត្តដល់ជនរងគ្រោះដែលរស់រានជីវិតពីរបបខ្មែរក្រហម និងធ្វើការស្វែងយល់ទាំងអស់គ្នាដើម្បីឲ្យមានការអត់ឱនអធ្យាស្រ័យ និងទប់ស្កាត់កុំឲ្យរបបនេះកើតមានឡើងម្ដងទៀត ។

ឃុំព្រះរំកិល មានព្រំប្រទល់ជាប់នឹងព្រំដែនប្រទេសឡាវ ។ ប្រជាជនខ្មែរ ក៏ដូចជាប្រជាជនលាវដែលរស់ក្បែរគ្នាតាមបន្ទាត់ព្រំដែនប្រទេសទាំងពីរ គឺមានការប្រាស្រ័យទាក់ទងគ្នាល្អ រួមទាំងការធ្វើជំនួញទៀតផង ។ ប៉ុន្តែ នៅអំឡុងឆ្នាំ១៩៧០ ក្រោយរដ្ឋ



ល្បាក់ខោន ស្ថិតនៅឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

ប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ខ្មែរក្រហម បានចូលមកកាន់កាប់ឃុំនេះទាំងស្រុង ចំណែកអ្នកភូមិមួយចំនួនដែលភ័យខ្លាចខ្មែរក្រហមក៏បានរត់ភៀសខ្លួនទៅនៅប្រទេសឡាវ ។ ដោយសារតែទំនាក់ទំនងល្អជាមួយគ្នាតាំងពីមុនមក ទើបអាជ្ញាធរលាវបានអនុញ្ញាតឲ្យអ្នកភៀសខ្លួនពីខ្មែរខ្ចីដីស្នាក់អាស្រ័យបណ្តោះអាសន្នសិន ។

ចែករំលែកបទពិសោធទៅកាន់យុវជនជំនាន់ក្រោយដែលបានចូលរួម លាង ដៀង អាយុ ៦៥ឆ្នាំបានរំឭកឡើងថា គាត់បានភៀសខ្លួនចូលទៅប្រទេសឡាវនៅឆ្នាំ១៩៧៤ ក្រោយពេលដែលខ្មែរក្រហមស៊ើបដឹងថា ឪពុករបស់គាត់បានលួចរត់ទៅនៅប្រទេសឡាវតាំងពីពេលដែលខ្មែរក្រហមគ្រប់គ្រងភូមិនេះដំបូង ។ ហេតុនេះ ទើបគ្រួសាររបស់គាត់ត្រូវខ្មែរក្រហមចាត់ទុកថាជាគ្រួសារខ្មាំង និងត្រូវតែកម្ទេច ។ ដោយបានដឹងដំណឹងនោះមុន ដៀង និងប្តី ព្រមទាំងអ្នកភូមិចំនួនប្រាំគ្រួសារទៀត បានលួចរត់ចេញពីផ្ទះទាំងយប់ ។ ដៀង និងប្រជាជនក្នុងភូមិមួយចំនួនទៀតបានដើរតាមព្រៃ សំដៅទៅភ្នំកន្ទុំចេក រួចហើយឆ្លងទឹកចូលទឹកដីលាវ ។ ដោយសារតែប្រជាជនខ្មែរ និងលាវពីមុនធ្លាប់ចេញចូល និង រាប់អានគ្នាល្អ ទើបអ្នកដែលភៀសខ្លួនទៅទឹកដីលាវមិនត្រូវបានប្រជាជនលាវធ្វើទុក្ខបុកម្នេញអ្វីទេ ។ តែការទំនាក់ទំនងរវាងប្រជាជនទាំងពីរនោះ ត្រូវកាត់ផ្តាច់ក្រោយពេល ដែលខ្មែរក្រហមចូលមកគ្រប់គ្រង នៅឆ្នាំ១៩៧៥ ។ នៅពេលដែល ដៀង និងប្រជាជនខ្មែរចូលទៅដល់ទឹកដីលាវ មិត្តភក្តិរបស់ ដៀង ដែលជាជនជាតិលាវ បាននាំ ដៀង និងអ្នកទាំងអស់នោះ ទៅជួបមេភូមិលាវ ។ ក្រោយពីមេភូមិបានសួរពីដំណើររឿងនៃការរត់ភៀសខ្លួនរួចហើយ ទើបអនុញ្ញាត ប្រជាជនខ្មែរទាំងអស់រស់នៅបណ្តោះអាសន្នសិន ។

ចំណែក ឃឹម ផុន សព្វថ្ងៃមានអាយុ៨១ឆ្នាំ ក៏មិនខុសពី លាង ដៀង ដែរ ។ គាត់បានរៀបរាប់ប្រាប់ទៅសិស្សានុសិស្សថា នៅក្នុងឆ្នាំ១៩៧១ ផុន បានភៀសខ្លួនទៅទឹកដីលាវ ដោយសារតែមានការទម្លាក់គ្រាប់បែកតាមស្រុកភូមិដែលគាត់រស់នៅ ។ ផុន អាចរត់បានដោយសារទាហានខ្មែរក្រហមដែលយាមនៅតាមមាត់ទន្លេនឹកស្មានថាគាត់ជិះទូកទៅរកត្រី ហើយថែមទាំងស្រែកផ្តាំផ្ញើ


ឃឹម ផុន នៅក្នុងវេទិកាសាធារណៈ

ផុន ថា «ទៅរកត្រីឲ្យអញស៊ីផង» ។ ពេលនោះក៏មានអ្នកឯទៀតរត់ទៅតាមក្រោយច្រើន មានទាំងទាហានសង្គមចាស់ ប៉ុន្តែយើងមិនបានសួរនាំគ្នាទេ គឺយើងរស់នៅរៀងៗខ្លួន ។ ផុន បន្ថែម ទៀតថា នៅចន្លោះឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៥ មានប្រជាជនខ្មែររស់នៅជិតគាត់ប្រមាណ៣០គ្រួសារ ។ នៅឆ្នាំ១៩៧៥ គាត់ក៏មករស់នៅ និងធ្វើស្រែជាមួយសមាគមសង្គ្រោះជាតិ ។ ដោយមានគ្រួសារខ្មែរដទៃ១០គ្រួសារ លាវចែកដីឲ្យសង់ផ្ទះល្មមរស់នៅ ហើយរកស៊ីតាមធម្មតា ។ អាជ្ញាធរលាវផ្តល់សិទ្ធិសេរីភាពដល់ជនភៀសខ្លួនខ្មែរក្នុងការប្រកបរបរនេសាទត្រី ។ ក្រោយរបប ខ្មែរក្រហមដួលរលំ និងមានសុខសន្តិភាពទើប ផុន ក៏ដូចជាបងប្អូនខ្មែរយើងបានស្នើសុំអាជ្ញាធរលាវមករស់នៅទឹកដីកំណើតវិញ ។

ជាទូទៅ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញថា ប្រជាជនដែលរស់នៅក្នុងឃុំព្រះរំកិល មានបំណងរត់ភៀសខ្លួនទៅកាន់ទឹកដីលាវទាំងអស់គ្នា ។ ប៉ុន្តែដោយសារចំនួនសមាជិកគ្រួសារច្រើនពិបាកក្នុងការរត់គេច ទើបធ្វើឲ្យអ្នកទាំងអស់



*ញ៉ែម ឡេង រៀបរាប់រឿងរ៉ាវក្នុងរបបខ្មែរក្រហមប្រាប់ដល់សិស្ស នៅក្នុងវេទិកាសាធារណៈ*

គស៊ូរស់ឆ្លងកាត់ក្នុងរបបប្រល័យពូជសាសន៍នេះ ។ ជាឧទាហរណ៍ កាលពីឆ្នាំ១៩៧២ ញ៉ែម ឡេង បានរៀបរាប់នៅក្នុងវេទិកាសាធារណៈនេះថា ដោយសារគាត់ចេះនិយាយភាសាលាវ ទើបកម្មាភិបាលខ្មែរក្រហមចាត់តាំងឲ្យធ្វើពាណិជ្ជកម្មដូរទំនិញជាមួយជនជាតិលាវ ។ ការដូរញដូរនៅពេល នោះមានដូចជា អំបិល ស្ករ ប្រេងសាំង ក្រណាត់ ជាពិសេសថ្នាំពេទ្យ ។ ឡេង បន្ថែមថា អ្នកដែលមកពីឡាវ មិនមែនមានឋានៈតូចតាចនោះទេ សុទ្ធតែពាក់សក្តិ៥ និងខ្សែរាជវង្សស្តេចលាវ ។ មុននឹងចូលធ្វើពាណិជ្ជកម្មជាមួយលាវ ឡេង ត្រូវបានកម្មាភិបាលខ្មែរក្រហមគំរាម និងហាមមិនឲ្យនិយាយរឿងនយោបាយប្រទេសជាតិ ឬមានបំណងចង់រត់គេចខ្លួនទៅរស់នៅលើទឹកដីលាវឲ្យសោះ បើពុំដូច្នោះទេនឹងសម្លាប់សាច់ញាតិនៅភូមិទាំងអស់ ។ ឡេង បន្តថា នៅពេលនោះ គាត់អាចរត់គេចខ្លួន ប៉ុន្តែមិនដាច់ចិត្តពីបងប្អូននៅផ្ទះ ។ ក្នុងខណៈកំពុងដូរញដូរ មានទាហានសក្តិប្រាំលាវនិយាយមកកាន់ ឡេង ថាហេតុអ្វីបានជាទាហានខាងអ្នកឯងបាញ់ សម្លាប់ប្រជាជនលាវដែលនេសាទត្រីលើទឹកដីលាវ ។ តែទោះយ៉ាងណា លាវនៅតែខិតខំលាក់កំបាំង និងជួយយកអាសាប្រជាជនខ្មែរក្រហមដែលរស់នៅទីនោះ ។ ទាំងនេះ គឺជាបទពិសោធដែលប្រជាជនឃុំព្រះរំកិលធ្លាប់បានឆ្លងកាត់ និងជួបប្រទះ មុនពេលដែលខ្មែរក្រហមចូលកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ទៅទៀត ។ ការចែករំលែករឿងរ៉ាវទាំងនេះដល់យុវជនជំនាន់ក្រោយដើម្បីធ្វើការស្វែងយល់ និងត្រិះរិះពិចារណា ហើយជាព័ត៌មានដ៏មានតម្លៃសម្រាប់ការចងចាំ ជាពិសេសព័ត៌មានទាក់ទងនឹងប្រវត្តិនៃភូមិស្រុកដែលខ្លួនរស់នៅ ។

**មីន សាណាស់**

- ◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- ◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ដំណើរវិវឌ្ឍន៍ប្រកបដោយភាពស្មុគស្មាញ នៃសំណុំរឿង០០៣ និង០០៤

## *សេចក្តីសង្ខេប*

បន្ទាប់ពីការបិទបញ្ចប់ទាំងស្រុងសំណុំរឿង០០១ ករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច និងការបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១ មានចម្ងល់ជាច្រើនបានឡើងទាក់ទងនឹងដំណើរវិវឌ្ឍន៍នៃសំណុំរឿង០០៣ និង០០៤ ថាតើសំណុំរឿងទាំងពីរនេះអាចនឹងត្រូវបានលើកយកមកជំនុំជម្រះសេចក្តី ដូចជាសំណុំរឿង០០១ និង០០២ ដែរឬយ៉ាងណា?

ចាប់តាំងពីមានការបើកការស៊ើបអង្កេតជាផ្លូវការពីសំណាក់សហព្រះរាជអាជ្ញាក្នុងឆ្នាំ២០០៨ ជនសង្ស័យចំនួន៥រូប ត្រូវបានបង្ហាញថា មានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលត្រូវចោទប្រកាន់ក្នុងសំណុំរឿង០០៣ និង០០៤ ។ សំណុំរឿងទាំងពីរនេះកំពុងតែស្ថិតនៅក្រោមការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ពុំទាន់មានជនសង្ស័យណាម្នាក់ត្រូវបានចោទប្រកាន់ជាផ្លូវការនៅឡើយ ហើយអត្តសញ្ញាណរបស់ជនសង្ស័យទាំង៥រូប ក៏កំពុងស្ថិតនៅជាការសម្ងាត់ ។ ទោះបីជាយ៉ាងណាក្តី មានសារព័ត៌មានជាតិ និងអន្តរជាតិជាច្រើនបានផ្សព្វផ្សាយជាបន្តបន្ទាប់ពីឈ្មោះរបស់ជនសង្ស័យទាំង៥រូប បន្ទាប់ពីមានការលេចធ្លាយនូវឯកសារសម្ងាត់របស់តុលាការ នៅអំឡុងខែមិថុនា ឆ្នាំ២០១១ ។ អ្នកទាំង៥រូបត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិអះអាងថា ជាបុគ្គលដែលស្ថិតនៅក្រោមដែនយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាអ្នកដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ។

ទោះបីជានៅពេលបច្ចុប្បន្នសំណុំរឿង០០៣ និង០០៤ បានឈានទៅដល់ដំណាក់កាលបង្ហាញអំពីទីតាំងឧក្រិដ្ឋកម្ម ទទួលយកសំណើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមានការអនុញ្ញាតឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចចូលពិនិត្យមើលឯកសារក្នុងសំណុំរឿងក៏ដោយ ក៏ដំណើរវិវឌ្ឍន៍នៃសំណុំរឿងនេះនាពេលកន្លងទៅ បានជួបប្រទះនឹងឧបសគ្គជាច្រើន ។ នៅអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីមូន នៅក្នុងប្រទេសកម្ពុជា កាលពីឆ្នាំ២០១០ ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានបង្ហាញអំពីជំហរពុំចង់ឲ្យមានសំណុំរឿងបន្ថែម ក្រៅពីសំណុំរឿង០០១ និង០០២ ដោយលើកឡើងពីហេតុផលអស្ថិរភាព និងអាចបង្កឲ្យមានចលាចលសង្គម ហើយប៉ះពាល់ដល់គោលនយោបាយផ្សះផ្សាជាតិរបស់កម្ពុជា ។ រីឯភាគីជាតិនៃតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម រាប់ចាប់តាំងពីសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងចៅក្រមអង្គបុរេជំនុំជម្រះ សុទ្ធតែបានបង្ហាញជំហរពុំគាំទ្រឲ្យមានការចោទប្រកាន់បន្ថែមលើជនសង្ស័យក្នុងសំណុំរឿង០០៣ និង០០៤ ដោយបានផ្តល់នូវហេតុផលផ្សេងៗគ្នា ។ ដំណើរពុំយល់ស្របគ្នារវាងភាគីជាតិ និងភាគីអន្តរជាតិចំពោះការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ ត្រូវបានអ្នកជំនាញអន្តរជាតិ និងអ្នកតាមដានដំណើរវិវឌ្ឍន៍នៃសាលាក្តីខ្មែរក្រហមមើលឃើញថា បណ្តាលមកពីការទទួលរងឥទ្ធិពលនយោបាយពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាដែលបានប្រឆាំងដាច់ខាតចំពោះការចោទប្រកាន់ជនសង្ស័យថ្មីបន្ថែមទៀត ។

មានសហចៅក្រមស៊ើបអង្កេតអន្តរជាតិចំនួន៣រូបហើយដែលបានសម្រេចចិត្តលាឈប់ជាបន្តបន្ទាប់ ក្រោយពីមានបញ្ហាចម្រូងចម្រាសពាក់ព័ន្ធនឹងការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ ។ អង្គការសហប្រជាជាតិបានចេញសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់ ដោយបង្ហាញអំពីការព្រួយបារម្ភយ៉ាងខ្លាំងរបស់ខ្លួនទាក់ទងនឹងដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤

និងបានសម្រេចតែងតាំងចៅក្រមស៊ើបអង្កេតមួយរូបថ្មីទៀត គឺលោក ម៉ាក ហាមិន ដើម្បីបន្តកិច្ចការងារស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ ។

ការវិវឌ្ឍន៍ចុងក្រោយមួយទៀត គឺការស្លាប់របស់ ស៊ូ ម៉េត ដែលជាជនសង្ស័យមួយរូបក្នុងចំណោមជនសង្ស័យចំនួនពីររូបក្នុងសំណុំរឿង០០៣ កាលពីខែមិថុនា ឆ្នាំ២០១៣ ។ ជនសង្ស័យរូបនេះ ត្រូវបានរំពឹងថា អាចនឹងត្រូវបានចាប់ខ្លួនមកកាត់ទោសដោយសាលាក្តីខ្មែរក្រហម ។ ជនសង្ស័យ ស៊ូ ម៉េត បានស្លាប់កាលថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ ដោយសារជំងឺ ។ ស៊ូ ម៉េត ធ្លាប់ធ្វើជាទីប្រឹក្សាក្រសួងការពារជាតិមានឋានន្តរសក្តិជាឧត្តមសេនីយ៍ទោ ក្រោយពេលចូលសមាហរណកម្ម ដែលត្រូវបានដឹងថាចាប់ផ្តើមតាំងពីខែសីហា ឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៩ ។ នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ស៊ូ ម៉េត ធ្លាប់មានតួនាទីជាមេបញ្ជាការកងពល៥០២ និងជាមេបញ្ជាការកងទ័ពអាកាសរបស់ខ្មែរក្រហម ។ ការស្លាប់នេះ ត្រូវបានមេធាវី ម៉ៃ យើល កាណាវាស ដែលជាអតីតមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី ក្នុងសំណុំរឿង០០២ និងត្រូវបានចាត់តាំងឲ្យធ្វើជាមេធាវីតំណាងឲ្យជនសង្ស័យមួយរូបផ្សេងទៀតក្នុងសំណុំរឿង០០៣ អះអាងថា ការស្លាប់របស់ ស៊ូ ម៉េត នឹងពុំប៉ះពាល់ដល់កិច្ចដំណើរស៊ើបអង្កេតលើកូនក្តីរបស់ខ្លួនក្នុងសំណុំរឿង០០៣នេះឡើយ ។ ទោះបីជាយ៉ាងណាក្តី ឋានៈជាមេធាវីតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៣ របស់មេធាវី ម៉ៃ យើល កាណាវាស និងមេធាវី អាង ឧត្តម ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន ។ ការបដិសេធនេះ គឺដោយសារមានការព្រួយបារម្ភអំពីបញ្ហាទំនាស់ផលប្រយោជន៍ទាក់ទងនឹងការការពារកូនក្តី ។

ចាប់ពីខែមករា រហូតដល់ខែមេសា ឆ្នាំ២០១៤ មានការវិវឌ្ឍន៍ថ្មីៗជាច្រើនក្នុងសំណុំរឿង០០៣ និង០០៤ ។ បើយោងតាមសេចក្តីប្រកាសជាច្រើនរបស់អង្គភាពគាំពារការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង០០៤ មានមេធាវីតំណាងរៀងៗខ្លួនដែលចាត់តាំងដោយអង្គភាពនេះ ដើម្បីការពារជនសង្ស័យនៅចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ ទោះបីជាយ៉ាងណា មេធាវីតំណាងឲ្យជនសង្ស័យទាំងអស់នោះនៅពុំទាន់ត្រូវបានអនុញ្ញាតឲ្យពិនិត្យមើលឯកសារដែលមាននៅក្នុងសំណុំរឿងនៅឡើយទេ ។

ការវិវឌ្ឍចុងក្រោយបង្អស់នៃសំណុំរឿងទាំងពីរនេះ គឺនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក្នុងសំណុំរឿង០០៤ ដោយស្នើឲ្យមានកិច្ចស៊ើបសួរទៅលើអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅតាមបណ្តាស្រុកសំខាន់ៗមួយចំនួនដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរនៃសំណុំរឿងនេះ ។

ខាងក្រោមនេះ នឹងមានការបង្ហាញពិស្តារអំពីប្រវត្តិនីតិវិធីនៃសំណុំរឿង០០៣ និង០០៤ ចាប់តាំងពីការចាប់ផ្តើមដំបូងរហូតដល់ដំណើរវិវឌ្ឍន៍ថ្មីៗចុងក្រោយបង្អស់នៃសំណុំរឿងទាំងពីរនេះ រួមទាំង ឧបសគ្គជាច្រើនដែលបានធ្វើឲ្យរាំងស្ទះ និងបានអូសបន្លាយការស៊ើបអង្កេតអស់រយៈពេលជាច្រើនឆ្នាំ ។

## ប្រវត្តិនីតិវិធីនៃសំណុំរឿង០០៣ និង០០៤

នៅក្នុងឆ្នាំ២០០៨ អតីតសហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូបឺត ប៉ុទីត បានសម្រេចបើកការស៊ើបអង្កេតថ្មីចំនួនពីរ នៅក្នុងសំណុំរឿង០០៣ និង០០៤ បន្ទាប់ពីមានការចោទប្រកាន់ជនសង្ស័យចំនួន៥រូប ក្នុងសំណុំរឿង០០១ និង០០២ នៅខែកក្កដា ឆ្នាំ២០០៧ ។ ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានធ្វើឡើង ទោះបីជាមានការជំទាស់ពីសំណាក់សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង យ៉ាងណាក្តី ។ លោកស្រី ជា លាង បានបង្ហាញអំពីមូលហេតុដែលនាំឲ្យមានការជំទាស់ថា ដោយសារតែជនសង្ស័យទាំង៥រូបដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងសំណុំរឿង០០៣ និង០០៤ ពុំស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រោះអ្នកទាំង៥រូបនោះពុំមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏ពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមដែរ ។ ដោយសារតែពុំមានការព្រមព្រៀងគ្នារវាងសហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិដើម្បី

បើកការស៊ើបអង្កេតលើសំណុំរឿងទាំងពីរនេះ សហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ើត ប៉ឺទីត បានដាក់ញត្តិមួយស្តីពីកំណត់ហេតុនៃការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ ដើម្បីឲ្យអង្គបុរេជំនុំជម្រះដោះស្រាយបញ្ហានេះ ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូប (បីរូបជាចៅក្រមជាតិ និងពីររូបជាចៅក្រមអន្តរជាតិ) ពុំអាចចេញសេចក្តីសម្រេចណាមួយបានដោយសារមិនអាចស្វែងរកសំឡេងឯកឆន្ទ ឬសំឡេងភាគច្រើនដាច់ខាតដើម្បីចេញសេចក្តីសម្រេចលើញត្តិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។ ដោយសារតែពុំមានសេចក្តីសម្រេចដូច្នេះ យោងតាមវិធាន ៧៤ (១) នៃវិធានផ្ទៃក្នុង សំណុំរឿងនេះត្រូវបានសន្មតថាត្រូវបន្តទៅការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីបើកការស៊ើបអង្កេតតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។

នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរទៅសហចៅក្រមស៊ើបអង្កេតដើម្បីបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការសម្រាប់ សំណុំរឿង០០៣ និង០០៤ ។

ទោះបីជាយ៉ាងណាក្តី ចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៩ សំណុំរឿង០០៣ និង០០៤ បានត្រូវទុកចោលនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយពុំមានជនសង្ស័យណាម្នាក់ត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការ ឬក៏ត្រូវបានចាប់ខ្លួនឡើយ ។ ឧបសគ្គចម្បងដែលត្រូវបានមើលឃើញគឺដោយសារសហព្រះរាជអាជ្ញាជាតិ សហចៅក្រមស៊ើបអង្កេតជាតិ និងចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះទាំងអស់បានចេញសេចក្តីសម្រេចស្របគ្នា រារាំង និងប្រឆាំងនឹងកិច្ចប្រឹងប្រែងរបស់សហភាគាអន្តរជាតិរបស់ខ្លួនដែលចង់ឲ្យកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងទាំងពីរនេះបន្តទៅមុខ ។

## ការលាឈប់ពីតំណែងជាបន្តបន្ទាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

នៅក្នុងឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិទីពីគឺលោក ស៊ីកហ្វ្រេដ ប៊្លុង (Siegfried Blunk) ដែលចូលកាន់តំណែងជំនួសលោកចៅក្រម ម៉ាកសែល ឡឺម៉ុង (Marcel Lemond) ដែលបានលាឈប់ពីមុខតំណែងកាលពីថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១០ ទំនងជាបានយល់ស្របជាមួយសមភាគីជាតិរបស់ខ្លួន គឺចៅក្រម យូ ប៊ុនឡេង សម្រេចបិទបញ្ចប់កិច្ចដំណើរការស៊ើបអង្កេតសំណុំរឿង០០៣ និង០០៤ ដោយពុំមានការចោទប្រកាន់ជនសង្ស័យណាម្នាក់ឡើយ ។ ការសម្រេចរបស់ចៅក្រមស៊ើបអង្កេត ស៊ីកហ្វ្រេដ ប៊្លុង ក្នុងការបិទបញ្ចប់ការស៊ើបអង្កេតលើសំណុំរឿង០០៣ និង ០០៤ បានទទួលរងការរិះគន់ពីសំណាក់អង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិថាមិនបានធ្វើការដោយអព្យាក្រឹត្យ ក្នុងសំណុំរឿងទាំងពីរនេះឡើយ ។ បន្ទាប់ពីទទួលរងការរិះគន់យ៉ាងខ្លាំងពីសំណាក់អង្គការសិទ្ធិមនុស្ស រួមទាំងស្ថាប័នឯករាជ្យជាច្រើនរួចមក ចៅក្រម ស៊ីកហ្វ្រេដ ប៊្លុង បានសម្រេចលាឈប់ពីមុខតំណែងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១ ។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងគឺលោក ឡូរ៉ង់ កាសប៉ឺ អានសឺម៉េត (Laurent Kasper-Ansermet) បានចូលកាន់តំណែងជំនួសចៅក្រម ប៊្លុង ដែលបានលាលែងពីមុខតំណែង ។ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ គឺរយៈពេលបីថ្ងៃបន្ទាប់ពីចូលកាន់តំណែងចៅក្រម អានសឺម៉េត បានចេញដីកាមួយឲ្យបើកការស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ ឡើងវិញ បន្ទាប់ពីពិចារណាឃើញថា ការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប នៅពុំទាន់ធ្វើបានពេញលេញ ។ ទោះបីជាយ៉ាងណាក្តី សិទ្ធិអំណាចក្នុងការស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ របស់ចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង អានសឺម៉េត ត្រូវបានជំទាស់ជានិច្ចជាកាលដោយចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ។ ការជំទាស់នេះត្រូវបានចៅក្រម យូ ប៊ុនឡេង ផ្តល់ហេតុផលថា ដោយសារតែចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងពុំទាន់ត្រូវបានតែងតាំងជាផ្លូវការណាមួយ ដូចដែលមានចែងនៅក្នុងវិធាន៧(៤) នៃវិធានផ្ទៃក្នុង មាត្រា២៦ និង មាត្រា២៧ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមាត្រា៣ និងមាត្រា៥ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០១២ ចៅក្រម យូ ប៊ុនឡេង បានចេញបញ្ជាជាលាយលក្ខណ៍អក្សរមួយផ្ញើជូនចៅក្រម អានសឺម៉េត ដោយបង្គាប់ថា ចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង អានសឺម៉េត “ត្រូវតែបញ្ឈប់ជាបន្ទាន់នូវសកម្មភាពខុសច្បាប់របស់ខ្លួន” ។

បន្ទាប់ពីមានការបដិសេធពុំទទួលស្គាល់ពីសំណាក់សហចៅក្រមស៊ើបអង្កេតជាតិ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា ចំពោះតួនាទីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង លោក ឡូរ៉ង់ កាសប៉ឺ អានសឺម៉េត បានចេញសេចក្តីថ្លែងការណ៍មួយដោយប្រកាសលាឈប់ពីមុខតំណែង និងបានអះអាងថា "ការជំទាស់យ៉ាងសកម្មដោយលោកចៅក្រម យូ ប៊ុនឡេង នៅក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង០០៤ បាននាំទៅដល់ស្ថានការណ៍នៃភាពមិនអាចដំណើរការបាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ កាលៈទេសៈបច្ចុប្បន្ននេះ លែងអនុញ្ញាតឲ្យខ្ញុំបំពេញការងាររបស់ខ្ញុំដោយត្រឹមត្រូវ និងដោយសេរីទៀតហើយ" ។ នៅក្នុងសេចក្តីថ្លែងការណ៍ដដែលនេះ ចៅក្រម អានសឺម៉េត បានបញ្ជាក់ថា ការលាលែងពីមុខតំណែងនេះមានអានុភាពគិតចាប់ពីថ្ងៃ៤ ខែឧសភា ឆ្នាំ២០១២ តទៅ ។

ក្រោយពីការប្រកាសលាឈប់ពីតំណែងរបស់ចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង អង្គការសហប្រជាជាតិបានចេញសេចក្តីថ្លែងការណ៍មួយ ដោយប្រកាសអំពីក្តីព្រួយបារម្ភយ៉ាងខ្លាំងរបស់ខ្លួនចំពោះដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង ០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គការសហប្រជាជាតិបានថ្លែងសង្កត់ធ្ងន់ថា កិច្ចស៊ើបអង្កេតក្នុងសំណុំរឿងទាំងពីរនេះត្រូវតែត្រឡប់មកក្នុងស្ថានភាពវិជ្ជមាន និងថា នីតិវិធីក្នុងការជ្រើសរើសសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីកំពុងចាប់ផ្តើម ។

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន (Mark B. Harmon) ត្រូវបានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាសម្រេចតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃសាលាក្តីខ្មែរក្រហម តាមសំណើរបស់អង្គការសហប្រជាជាតិដើម្បីបន្តកិច្ចការស៊ើបអង្កេតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

## ការបង្ហាញព័ត៌មានស្តីពីទីតាំងឧក្រិដ្ឋកម្ម និងបទចោទប្រកាន់

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ ដោយពុំមានការចូលរួមពីសំណាក់សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង បង្ហាញអំពីទីតាំងឧក្រិដ្ឋកម្មបន្ថែមចំនួន១៤ ដែលស្ថិតនៅក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង០០៤ និងបានអញ្ជើញសាក្សី និងជនរងគ្រោះ ដែលមានជាប់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងអស់នោះ ឲ្យមកទំនាក់ទំនាក់ជាមួយនឹងសាលាក្តីខ្មែរក្រហម ។ សេចក្តីថ្លែងការណ៍នេះ បានបង្ហាញថា ការស៊ើបអង្កេតលើសំណុំរឿងនេះនៅតែបន្តដំណើរការ ហើយព័ត៌មានចាំបាច់មួយចំនួនត្រូវបានបង្ហាញជូនជនរងគ្រោះ ដែលមានបំណងចង់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ ។ ទីតាំងឧក្រិដ្ឋកម្មបន្ថែមទាំង១៤កន្លែងនោះមានដូចជា ៖

### ក) ខេត្តបាត់ដំបង

◆ មន្ទីរសន្តិសុខធិបតី និងការដ្ឋានទួលម្រេស ៖ ស្ថិតនៅឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង

◆ ភ្នំត្រដាក់ចិត្ត និងអន្លង់វិលប្រែង ៖ ស្ថិតនៅភូមិឫស្សីព្រះ ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង

◆ មន្ទីរសន្តិសុខតំបន់១ និងកន្លែងសម្លាប់ដំណាក់រាំង ៖ ស្ថិតនៅភូមិបាណន់ ឃុំកន្ទឺ ស្រុកបាណន់ ខេត្តបាត់ដំបង

### ខ) ខេត្តពោធិ៍សាត់

◆ រណ្តៅទួលសេះញ៉ូវ និងវាលពិឃាតព្រៃក្រចៅ ៖ ស្ថិតនៅឃុំរំលេច និងឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តលើខ្មែរក្រោម)

◆ គុកភូមិវាល ៖ ស្ថិតនៅឃុំតាឡូ ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តលើខ្មែរក្រោម)

◆ គុកស្វាយជ្រុំ ហៅគុកភូមិថ្កោល និងគុកបឹងបាគកណ្តាល ហៅត្រាក្រោល ៖ ស្ថិតនៅឃុំបឹង បាគកណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តលើខ្មែរក្រោម)

◆ ទីតាំងសម្លាប់វត្តច័ន្ទរង្សី-រណ្តៅសាកសពរូម និងអណ្តូងសាកសពរូមនៅភូមិកូនត្នោត ឬភូមិចាម ៖ ស្ថិតនៅឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា)

◆ កន្លែងសម្លាប់វាលបាក់ចិញ្ចៀន ៖ ស្ថិតនៅឃុំស្រែស្តុក

ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តទៅលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា)

### គ) ខេត្តតាកែវ

◆ កន្លែងសម្លាប់ព្រៃសុខុន និងមន្ទីរឃុំឃាំងវត្តអង្គសិរីមុនីៈ ស្ថិតនៅភូមិស៊ីស្វា ឃុំផ្លាប្រជុំ ស្រុកកោះអណ្ដែត ខេត្តតាកែវ (ការប្រព្រឹត្តទៅលើខ្មែរក្រោម)

◆ ព្រៃភូមិស្វែង វត្តអង្គញ កន្លែងសម្លាប់ភូមិព្រាល និងភូមិសោម និងគុកវត្តសុបិនៈ ស្ថិតនៅ ឃុំគោព្រេច និងឃុំកំពែង ស្រុកគិរីវង្ស ខេត្តតាកែវ (ការប្រព្រឹត្តទៅលើខ្មែរក្រោម)

◆ មន្ទីរសន្តិសុខវត្តប្រធាតុ ៈ ស្ថិតនៅក្នុងឃុំគោកព្រេច ស្រុកគិរីវង្ស ខេត្តតាកែវ (ការប្រព្រឹត្តលើខ្មែរក្រោម)

◆ មន្ទីរសន្តិសុខក្រាំងតាចាន់ ៈ ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ (ការប្រព្រឹត្តលើខ្មែរក្រោម និងជនជាតិដទៃទៀត)

### ឃ) ខេត្តកំពង់ធំ

◆ គុកសម័យអាណានិគមៈ ស្ថិតនៅទីរួមខេត្តកំពង់ធំ (ការបោសសម្អាតភូមិភាគកណ្ដាល)

### ង) ខេត្តកំពង់ចាម

◆ កន្លែងសម្លាប់ថ្នល់បែក ៈ ស្ថិតនៅឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ទាក់ទងនឹង (មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក)

បន្ទាប់មក នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន និងសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង បានចេញសេចក្ដីប្រកាសពីរដាច់ពីគ្នាទាក់ទងនឹងសំណុំរឿង០០៣ ។ នៅក្នុងសេចក្ដីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតជាតិយូ ប៊ុនឡេង បានលើកឡើងថាដីកាដែលលោក (យូ ប៊ុនឡេង) និងអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេដ ប្លុង បានចេញរួមគ្នាដើម្បីការបិទបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ ដោយពុំមានការចោទប្រកាន់នៅតែបន្តមានសុពលភាពដដែល ។ ប៉ុន្តែ សម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន យល់ថា សំណុំរឿង០០៣ នៅពុំទាន់បិទបញ្ចប់នៅឡើយទេ ហើយកិច្ចដំណើរការស៊ើបអង្កេតនៅតែអាចបន្តធ្វើបាន ។ ចៅក្រម ហាមិន ថែមទាំងបានប្រើប្រាស់សេចក្ដីប្រកាសនេះដើម្បីជាការជូនដំណឹងដល់ជនរងគ្រោះ និងសាធារណជនទូទៅអំពីព័ត៌មាននៃសំណុំរឿង០០៣ ដោយបង្ហាញអំពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងទីតាំងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមការស៊ើបអង្កេត ។ បន្ថែមពីលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហាមិន បានអំពាវនាវឲ្យជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនោះ និងអ្នកដែលធ្លាប់បានដឹងឮអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មទាំងនោះ អាចចូលរួមក្នុងសំណុំរឿង០០៣ ក្នុងនាមជាសាក្សី ជាដើមបណ្ដឹងរដ្ឋប្បវេណី ឬជាអ្នកដាក់ពាក្យបណ្ដឹង ។ បទចោទប្រកាន់ និងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿង០០៣ ដែលត្រូវបានបង្ហាញក្នុងសេចក្ដីប្រកាសដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានដូចខាងក្រោម ៖

> *“នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ សម្រាប់សំណុំរឿង០០៣ សហព្រះរាជអាជ្ញាបានចោទថាសមាជិកកងទ័ពបដិវត្តន៍កម្ពុជា កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពអាកាសកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើមនុស្សឃាត និងអំពើទារុណកម្ម នៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ នៅចន្លោះពីខែមេសា ឆ្នាំ១៩៧៥ ទៅខែមករា ឆ្នាំ១៩៧៩ ។ យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ សហព្រះរាជអាជ្ញាធ្វើការបញ្ជាក់ ដូចតទៅ ៈ កងទ័ពបដិវត្តន៍កម្ពុជា កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពអាកាសកម្ពុជាប្រជាធិបតេយ្យបានបោសសម្អាតកងពលយោធា ។ មនុស្សដែលត្រូវបានបោសសម្អាតត្រូវបានចាប់ខ្លួនតាមអំពើចិត្ត ដាក់ឃុំឃាំងដោយខុសច្បាប់ ធ្វើទារុណកម្ម ធ្វើមនុស្សឃាត និងទទួលរងពលកម្មដោយបង្ខំ ។ កម្មករ អ្នកនេសាទ និងប្រជាជនដែលត្រូវបានសម្គាល់ថាជា “ជនក្បត់” ជនបរទេស (លោកខាងលិច ថៃ និងវៀតណាម)*

*ដែលត្រូវបានចាប់ខ្លួននៅក្នុងដែនទឹករបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬត្រូវបានចាប់ពង្រត់ពីតំបន់ព្រំដែនគឺជាជនរងគ្រោះនៃបទឧក្រិដ្ឋទាំងនោះ ហើយបទឧក្រិដ្ឋទាំងនោះត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាលនៃកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលវាយលុកចូលប្រទេសវៀតណាមនៅចុងឆ្នាំ១៩៧៧ និងឆ្នាំ ១៩៧៨ ។»*

បន្ថែមពីលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅតំបន់ឆ្នេរប្រទេសកម្ពុជា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញាសម្រាប់សំណុំរឿង០០៣ បានបង្ហាញទីតាំងជាក់លាក់មួយចំនួនដែលឧក្រិដ្ឋកម្មទាំងនោះបានកើតឡើង ។ ទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង០០៣ មានដូចជា ៖

◆ មន្ទីរសន្តិសុខ ស-២១ ៖ ស្ថិតនៅភ្នំពេញ

◆ ទីតាំងសម្ងាប់ស៊ីងតូច ៖ ស្ថិតនៅស្រុកពញាក្រែក ខេត្តកំពង់ចាម

◆ ការដ្ឋានសាងសង់ព្រលានយន្តហោះ ៖ ស្ថិតនៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

◆ មន្ទីរសន្តិសុខកងពល៨០១ ៖ ស្ថិតនៅស្រុកវីនសៃ ខេត្តរតនគិរី

◆ ការដ្ឋានវាយថ្មស្ទឹងហាវ ៖ ស្ថិតនៅខេត្តកំពង់សោម

◆ មន្ទីរសន្តិសុខ និងទីតាំងសម្ងាប់វត្តឥន្ទញាណ ៖ ស្ថិតនៅខេត្តកំពង់សោម

◆ មន្ទីរសន្តិសុខស-២២ ៖ នៅខណ្ឌមានជ័យ រាជធានីភ្នំពេញ

◆ ចម្ការដូរេន ៖ ស្ថិតនៅភូមិរាម សង្កាត់រាម ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ

◆ ការដ្ឋានបិតត្រាំង ៖ ស្ថិតនៅសង្កាត់បិតត្រាំង ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ

## ការទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ទោះបីជាមានការជំទាស់ពីសំណាក់សហចៅក្រមស៊ើបអង្កេតជាតិ លើការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ ដំណើរវិវឌ្ឍន៍នៃសំណុំរឿងទាំងពីរត្រូវបានមើលឃើញថា កំពុងមានការវិវឌ្ឍន៍ជឿនលឿនទៅមុខៗ ។

ជាក់ស្តែង នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ គឺពីរថ្ងៃនៅមុនពេលចេញសេចក្តីប្រកាសទាក់ទងនឹងសំណុំរឿង០០៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន បានចេញសេចក្តីសម្រេចមួយ ផ្តល់និតិសម្បទា ទទួលស្គាល់ និងអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿងដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៤រូប ដែលតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៣ ។ បន្ទាប់មក នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៣ ចៅក្រម ម៉ាក ហាមិន បានចេញសេចក្តីសម្រេចមួយទៀត ស្រដៀងគ្នានឹងសេចក្តីសម្រេចចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ដោយបានផ្តល់និតិសម្បទាទទួលស្គាល់ និងអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿងដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន២០រូបទៀត ដែលមានបំណងតំណាងឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០៤ ។ សេចក្តីសម្រេចនេះ ស្របគ្នាជាមួយនឹងទស្សនៈរបស់ចៅក្រមអន្តរជាតិទាំងពីររូបនៃអង្គបុរេជំនុំជម្រះ ដែលបានលើកឡើងថា វិធានផ្ទៃក្នុងបានផ្តល់លទ្ធភាពឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពិនិត្យសំណុំរឿងតាមរយៈមេធាវីតំណាងរបស់ខ្លួន គិតចាប់ពីពេលដាក់ពាក្យសុំ រហូតដល់ពេលសេចក្តីសម្រេចបដិសេធចោលពាក្យសុំនេះចូលជាស្ថាពរ ។

## ការចាត់តាំងមេធាវីតំណាងជនសង្ស័យ

ដូចគ្នានឹងជនរងគ្រោះដែរ ជនសង្ស័យទាំង៥រូប ដែលមានឈ្មោះក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងសំណុំរឿង០០៣ និង០០៤ ត្រូវបានជូនដំណឹងអំពីការចោទប្រកាន់ និងសិទ្ធិក្នុងការមានមេធាវីការពារក្តី ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ។ នៅពេលដំបូង អ្វីដែលត្រូវបានដឹងជាសាធារណៈ គឺមានតែជនសង្ស័យមួយរូបនៅក្នុងសំណុំរឿង០០៣ និងជនសង្ស័យមួយរូបនៅក្នុងសំណុំរឿង០០៤ ដែលបានអនុវត្តសិទ្ធិក្នុងការមានមេធាវីការពារនេះ ។

ក្នុងសំណុំរឿង០០៤ ជនសង្ស័យបានជ្រើសរើសអតីតប្រធានអង្គភាពគាំពារក្តី លោក រីឆាត រ៉ូជឺ (Richard Rogers) ធ្វើជាមេធាវីការពារក្តីអន្តរជាតិរបស់ខ្លួន និងលោក មុំ លុជ្ស ធ្វើជាមេធាវី

ជាតិ ។ ប៉ុន្តែ ដោយសារមានការជំទាស់ពីសំណាក់អង្គភាពគាំពារការពារក្តីចំពោះការជ្រើសរើសលោក រីឆាត រ៉ូជឺ ជនសង្ស័យបានជ្រើសរើសយកលោក ហ្គោរ៉ែន ស្លូតឃឺ (Goran Sluiter) ជាមេធាវីអន្តរជាតិមួយរូប ទៀតរបស់ខ្លួន ។ នៅក្នុងខែតុលា ឆ្នាំ២០១២ លោក ស្លូតឃឺ ត្រូវបានតែងតាំងជាមេធាវីការពារក្តីជាផ្លូវការ ។ ចំណែកឯ ជនសង្ស័យមួយរូបក្នុងសំណុំរឿង០០៣ បានជ្រើសរើសយកមេធាវី ម៉ៃឃើល ការណាវ៉ាស និងមេធាវី អាង ឧត្តម ដើម្បីការពារក្តីឲ្យខ្លួននៅចំពោះមុខការចោទប្រកាន់របស់តុលាការ ។ មេធាវីទាំងពីររូបត្រូវបានតែងតាំងជាផ្លូវការ ដោយអង្គភាពគាំពារការពារក្តីនៅខែធ្នូ ឆ្នាំ២០១២ នៅខណៈពេលដែលមេធាវីទាំងពីររូបនេះកំពុងបំពេញភារកិច្ចការពារក្តីឲ្យជនជាប់ចោទ អៀង សារី ក្នុងសំណុំរឿង០០២ ។ ប៉ុន្តែនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន បានចេញសេចក្តីសម្រេចមួយបដិសេធចំពោះការតែងតាំងមេធាវីទាំងពីររូប ដោយលើកឡើងថា កិច្ចការរបស់មេធាវីទាំងពីររូបក្នុងការការពារក្តីឲ្យជនជាប់ចោទ អៀង សារី និងការធ្វើជាមេធាវីតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៣ អាចនឹងបង្កឲ្យមានបញ្ហាជម្លោះផលប្រយោជន៍ ទោះបីជា អៀង សារី បានស្លាប់ហើយក៏ដោយ ។ ចៅក្រម ហាមិន បានបញ្ជាក់នៅក្នុងសេចក្តីសម្រេចនោះថា មេធាវី ការណាវ៉ាស និងមេធាវី អាង ឧត្តម ពុំមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីធ្វើជាអ្នកតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៣ទេ និងបានបញ្ជាឲ្យតុលាការតែងតាំងមេធាវីការពារក្តីថ្មីជំនួសកន្លែងរបស់មេធាវីទាំងពីររូប ។ រហូតមកដល់ពេលនេះ ពុំទាន់ឃើញមានការតែងតាំងមេធាវីថ្មីជំនួសឲ្យមេធាវី ការណាវ៉ាស និងមេធាវី អាង ឧត្តម នៅឡើយទេ ។

រហូតដល់ខែមករា ឆ្នាំ២០១៤ ទើបឃើញមានការតែងតាំងមេធាវីតំណាងឲ្យជនសង្ស័យពីររូបផ្សេងទៀតដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ក្នុងសំណុំរឿង០០៤ ។ នៅក្នុងសេចក្តីប្រកាសចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ អង្គភាពគាំពារការពារក្តីនៃសាលាក្តីខ្មែរក្រហមបានសម្រេចចាត់តាំង លោក ប៊ិត ស៊ាំងលីម និងលោក សូ មូស្សេទ្ធី ធ្វើជាសហមេធាវីជាតិតំណាងឲ្យ ជនសង្ស័យពីររូបផ្សេងគ្នានៅក្នុងសំណុំរឿង០០៤ ។ បន្ទាប់មក នៅក្នុងសេចក្តីប្រកាសចុះនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ អង្គភាពគាំពារការពារក្តីបានចាត់តាំងមេធាវីអន្តរជាតិមួយរូបផ្សេងទៀត គឺលោកស្រី ស៊ូហ្សាណា តូមាណូវិច (Suzana Tomanovic) ធ្វើជាសហមេធាវីអន្តរជាតិតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៤ ដែលនឹងត្រូវធ្វើការងាររួមគ្នាជាមួយលោក សូ មូស្សេទ្ធី ។ បន្ទាប់ពីលោកស្រី មេធាវី ស៊ូហ្សាណា តូមាណូវិច មេធាវីអន្តរជាតិមួយរូបទៀតត្រូវបានចាត់តាំងឲ្យតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៤ ។ នៅក្នុងសេចក្តីប្រកាសចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ អង្គភាពគាំពារការពារក្តី បានចាត់តាំងលោក ចន ចូន (John R.W.D. Jones) សញ្ជាតិអង់គ្លេស ធ្វើជាសហមេធាវីអន្តរជាតិតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៤ ដោយត្រូវធ្វើកិច្ចការរួមគ្នាជាមួយនឹងលោក ប៊ិត ស៊ាំងលីម ។ ដូច្នេះ បើយោងតាមសេចក្តីប្រកាសទាំងអស់នេះ ជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង ០០៤ ទំនងជាមានមេធាវីតំណាងរៀងៗខ្លួន ដើម្បីការពារខ្លួននៅចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅមុនពេលមានការចាត់តាំងមេធាវីតំណាងឲ្យជនសង្ស័យទាំង៥រូប ដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៣ និង០០៤ អ្នកឃ្លាំមើលដំណើរការវិវឌ្ឍន៍នៃសាលាក្តីខ្មែរក្រហម ព្រមទាំងចៅក្រមនៃអង្គបុរេជំនុំជម្រះ ធ្លាប់បានបង្ហាញអំពីក្តីព្រួយបារម្ភថា សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនសង្ស័យក្នុងសំណុំរឿង០០៣ និង០០៤ អាចនឹងត្រូវបានរំលោភបំពាន នៅពេលដែលជនសង្ស័យទាំងនោះស្ថិតនៅក្រោមការស៊ើបអង្កេតចាប់តាំងពីឆ្នាំ២០០៩ ដោយពុំមានមេធាវីតំណាង ។

## មេធាវីតំណាងជនសង្ស័យពុំទាន់ត្រូវបានអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿង

បច្ចុប្បន្ននេះ ទោះបីជាជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង០០៤ ទទួលបានមេធាវី តំណាងហើយក៏ដោយ ក៏មេធាវីតំណាងឲ្យជនសង្ស័យទាំងអស់នោះនៅពុំទាន់ទទួលបានការអនុញ្ញាតឲ្យចូលពិនិត្យមើលឯកសារនៅក្នុងសំណុំរឿងនៅឡើយទេ ។ អង្គភាពគាំពារការពារក្តី និងស្ថាប័នការពារសិទ្ធិមនុស្សមួយ

ចំនួនបានលើកឡើងថា ការរារាំងមិនអនុញ្ញាតឲ្យមេធាវីតំណាងជនសង្ស័យចូលពិនិត្យមើលឯកសារក្នុងសំណុំរឿងបង្ហាញពីការខកខានក្នុងការផ្តល់ការការពារសិទ្ធិជូនជនសង្ស័យឲ្យបានគ្រប់គ្រាន់ ។ ក្រុមមេធាវីការពារក្តីមិនអាចផ្តល់កិច្ចការពារដល់កូនក្តីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពបានទេ ប្រសិនបើពួកគេមិនត្រូវបានអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿង ឬមិនអាចចូលរួមក្នុងកិច្ចដំណើរការស៊ើបអង្កេតបាននោះ ។

គោលការណ៍ផ្តល់សិទ្ធិឲ្យមេធាវីការពារក្តីអាចចូលពិនិត្យមើលឯកសារក្នុងសំណុំរឿង គឺធ្វើឡើងក្នុងគោលបំណងដើម្បីធានាថា សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានការពារ និងលើកស្ទួយប្រសិទ្ធភាពនៃការស៊ើបអង្កេត និងដំណើរការក្តី និងដើម្បីអនុញ្ញាតឲ្យមេធាវីតំណាងអាចធ្វើសំណើដើម្បីធ្វើការស៊ើបអង្កេត ។

### សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យមានការស៊ើបអង្កេតបន្ថែមលើសំណុំរឿង០០៤

ការវិវឌ្ឍចុងក្រោយបង្អស់នៃសំណុំរឿង០០៤ គឺការស្នើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីឲ្យមានកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងអំពើហិង្សាផ្លូវភេទ រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតាមបណ្តាលស្រុកសំខាន់ៗមួយចំនួនដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរ ដែលជាផ្នែកនៃសំណុំរឿងនេះ ។ នៅក្នុងសេចក្តីប្រកាសមួយចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិលោក នីកូឡាស គូមជេន (Nicholas Koumjian) បានបញ្ជាក់ថា អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាខាងផ្លូវភេទ ដូចបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តិឡើងដោយកម្មាភិបាលខ្មែរក្រហម និងបានកើតឡើងនៅក្នុងតំបន់នានាដែលជនសង្ស័យក្នុងសំណុំរឿង០០៤ គឺជាអ្នកកាន់មុខនាទីជាអ្នកបញ្ជា ឬនយោបាយដ៏មានឥទ្ធិពល ។ សហព្រះរាជអាជ្ញាអន្តរជាតិបានបន្ថែមទៀតថា បន្ទាប់ពីវិភាគដោយយកចិត្តទុកដាក់លើព័ត៌មាននៅក្នុងអំឡុងពេលប៉ុន្មានខែកន្លងមក សហព្រះរាជអាជ្ញាជឿជាក់ថា ការចោទប្រកាន់លើអង្គហេតុទាំងឡាយដែលមាននៅក្នុងភស្តុតាងថ្មី គឺអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលរួមមាន ៖ ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ។ អំពើទាំងនេះក៏បង្កើតបានជាអំពើមនុស្សឃាត និងអំពើទារុណកម្ម ដែលជាការរំលោភទៅលើក្រុមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។

### សន្និដ្ឋាន

ទោះបីជាការវិវឌ្ឍចុងក្រោយនេះ បានបង្ហាញថា សំណុំរឿង០០៣ និង០០៤ កំពុងដំណើរការទៅមុខប្រកបដោយភាពរឹងមាំក៏ដោយ សាធារណជនទូទៅហាក់បីដូចជានៅពុំទាន់ទទួលបានព័ត៌មានទូលំទូលាយអំពីកិច្ចដំណើរការស៊ើបអង្កេតលើសំណុំរឿងទាំងពីរនេះនៅឡើយ ។ បន្ថែមពីលើនេះ អត្តសញ្ញាណរបស់ជនសង្ស័យនៅតែបន្តស្ថិតនៅក្នុងភាពសម្ងាត់ ពុំទាន់ត្រូវបានប្រកាសជាផ្លូវការទោះបីជាការស៊ើបអង្កេតបានចាប់ផ្តើមតាំងពីឆ្នាំ២០០៩ យ៉ាងណាក្តី ។ ការមិនអនុញ្ញាតឲ្យមេធាវីតំណាងជនសង្ស័យចូលពិនិត្យមើលឯកសារក្នុងសំណុំរឿង និងការបដិសេធមិនទទួលស្គាល់មេធាវីតំណាងជនសង្ស័យ ក៏ជាឧបសគ្គរារាំងជនសង្ស័យពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។ ប្រជាជនកម្ពុជាជាពិសេស ជនរងគ្រោះដោយសាររបបខ្មែរក្រហមគប្បីសមនឹងទទួលបានព័ត៌មានទូលំលាយអំពីការវិវឌ្ឍន៍នៃសំណុំរឿង០០៣ និង០០៤ ច្រើនជាងនេះដើម្បីធ្វើឲ្យប្រាកដថា ការចូលរួមរបស់ជនរងគ្រោះនឹងធ្វើឡើងប្រកបដោយអត្ថន័យ ។

**លីម ច័យឫទ្ធ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍន៍ថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបញ្ចប់សវនាការដេញដោលកាលពីខែតុលា ឆ្នាំ២០១៣ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី “សហកម្មឧក្រិដ្ឋកម្មរួម” ដែលភាសាអង់គ្លេសហៅថា “Join Criminal Enterprise” ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម “ផែនការឧក្រិដ្ឋរួម” ដែលភាសាអង់គ្លេសហៅថា “Common Criminal Plan” ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**ភ៊ន់ថាន់ ពៅដាភ៊**

# សំណួរ-ចម្លើយទាក់ទងទៅនឹងជំងឺ ផ្លូវចិត្តដែលកើតឡើងក្រោយរបបខ្មែរក្រហម



វេជ្ជបណ្ឌិត កា សុីនបូណាត ឆ្លើយតបទៅនឹងសំណួររបស់លោកគ្រូ-អ្នកគ្រូ

**សំណួរ** ៖ មានមនុស្សម្នាក់ចូលចិត្តកេះដី សើចតែម្នាក់ឯង អង្គុយនៅតែឯង ។ តើគាត់កើតជំងឺផ្លូវចិត្តឬទេ? ពេលមានគេនិយាយជាមួយគាត់ គាត់អាចនិយាយជាមួយបាន ។ តើមានវិធីបង្ការឬទេ? ហើយព្យាបាលយ៉ាងណាដែរ?

**ចម្លើយ** ៖ ជាទូទៅ ផ្អែកលើអាការៈរោគមួយឬពីរ គេមិនអាចធ្វើរោគវិនិច្ឆ័យបានទេ គេត្រូវសួរនាំយកព័ត៌មានឲ្យបានច្បាស់លាស់ និងគ្រប់គ្រាន់ ចាប់ពីពេលនៅក្នុងពោះម្តាយរហូតដល់ពេលមកជួបគ្រូពេទ្យ ទើបយើងអាចវិភាគ ធ្វើការថ្លឹងថ្លែងជាមួយក្បួនកំណត់រោគវិនិច្ឆ័យ ដើម្បីអាចចាត់ទុកថាជាជំងឺអ្វី? ការអាចនិយាយជាមួយបាន មិនពិតជាមានន័យថា ជនម្នាក់នោះត្រឹមត្រូវទាំងស្រុងនោះទេ ។ ជាពិសេស ត្រូវចេះសួរដេញដោលឲ្យដឹងច្បាស់ការឆ្លើយ ការសួររបស់ជននោះមានភាពត្រឹមត្រូវ និង ស្ថិតក្នុងដែននៃតក្កវិទ្យាឬទេ? ។ សូមរំឭកថា ជំងឺផ្លូវចិត្តមិនមែនមានតែមួយដែលមានឈ្មោះថា ជំងឺផ្លូវចិត្តនោះទេ ។ តាមក្បួនកំណត់ជំងឺផ្លូវចិត្តរបស់អង្គការសុខភាពពិភពលោក ជំងឺផ្លូវចិត្តមានប្រមាណពីជាង ៣០០ ដល់ជាង ៤០០ យ៉ាងខុសៗគ្នា ។ អាការៈបែបនេះ ច្រើនតែជាមនុស្សដែលមិនរវល់នឹងគេឯង ហើយមិនចូលចិត្តនៅជិតគេឯង និង អាចមានអារម្មណ៍ខ្លាចគេឯង ជិតខាង ឬ ធុញនឹងនៅជាមួយគេឯង ។ អាការៈសើចម្នាក់ឯងនេះ ច្រើនតែមកពីក្នុងខួរក្បាលឃើញ ឬ ដឹងឮ ឃើញអ្វីមួយ ដែលធ្វើឲ្យហួសចិត្តសប្បាយ តែដែលគេឯងគ្រាប់គ្នាមិនបានដឹងឮ ឬ ឃើញ ដូចម្នាក់នោះទេ ។ ការដែលឃើញម្នាក់ឯងបែបនេះមកពីសភាពជំងឺ ធ្វើឲ្យកើតមាននូវអាការៈបែបនេះ ហើយដែលច្រើនតែមកពី មានរោគសញ្ញាម៉្យាងដែលគេហៅថា មមាល (hallucination) ។ ជំងឺដែលមានអាការៈនេះ ច្រើនជាជំងឺវិកលចរិត ជំងឺវិកលចរិតរ៉ាំរ៉ៃ ដែលជាភាសាអង់គ្លេសគេហៅថា (schizophrenia) ឬជំងឺបាក់ស្បាតធ្ងន់ធ្ងរ ឬ ជាជំងឺធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ ដោយមានរោគសញ្ញាវិកលចរិត ។ សម្រាប់រាល់ជំងឺផ្លូវចិត្ត ពិសេសជំងឺនេះ វិធីបង្ការយ៉ាងសាមញ្ញ ត្រូវអនុវត្តតាមព្រហ្មវិហារធម៌ឲ្យបានសព្វគ្រប់ និងជាប្រចាំ ចាប់ពីវ័យទារកដល់ធំពេញវ័យ ។ ជាពិសេស មុននឹងធ្វើការព្យាបាល គេត្រូវធ្វើរោគវិនិច្ឆ័យឲ្យបានច្បាស់លាស់ត្រឹមត្រូវ ដូចដែលមានក្បួនកំណត់ដូចបានជម្រាបក្នុងចម្លើយរបស់សំណួរទីមួយ ត្រូវធ្វើចិត្តវិភាគដើម្បីស្វែងរកមូលហេតុដំណើរដើមទងដែលបង្កឲ្យកើតជំងឺ និងបញ្ហានានាដែលគេទទួលពេលកំពុងកើតជំងឺ ស្ថានភាពដែលត្រូវប្រឈម និងសង្គមមនុស្ស ទោះជានៅប្រទេសក្រីក្រក្តី ប្រទេសចម្រើនជឿនលឿនក្តី តែងតែកើតមានដូចគ្នានូវរាល់ជំងឺផ្លូវចិត្តទាំងអម្បាលម៉ាននេះ ។ ការព្យាបាលត្រូវស្វែងរកវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា ដែលមានបទពិសោធត្រឹមត្រូវ ទោះជាវេជ្ជបណ្ឌិតថ្នាក់ណាក៏ដោយ ដែលមិនមានឯកទេសនេះច្បាស់លាស់ ទោះជាមានតិចតួចក៏ដោយ ក៏មិនអាចយល់ដឹងបានឡើយ ព្រោះអ្វីៗទាក់ទងនឹងផ្លូវចិត្ត ពិតជាពិបាកមើលឲ្យឃើញខ្លាំងណាស់ រស់នៅជាមួយគ្នាក៏ដោយ ក៏មិនអាចដឹងបានដែរ ។

***សំណួរ*** ៖ មនុស្សម្នាក់ញ័រ ស្រាប់តែពេលទៅណាមកណា មានជួបគេឯង កាន់តែញ័រខ្លាំង ។ តើជាបញ្ហាផ្លូវចិត្តទេ? ហើយព្យាបាលដោយវិធីណា តើមានវិធីបង្ការដែររឺទេ?

***ចម្លើយ*** ៖ យើងត្រូវសួរ សង្កេត និងស្វែងយល់ឲ្យច្បាស់ និងត្រូវបេះបកស្រាយតាមទស្សនៈតក្កវិទ្យា ឲ្យបានត្រឹមត្រូវ ពិតនូវអាការៈនេះ ។ អាការៈនេះច្រើនតែមកពីមានការភ័យព្រួយខ្លាំង ដែលមិនអាចម្ចាស់ការលើបាន ។ សាមីខ្លួនអ្នកជំងឺ មានការពិបាក និងកង្វល់យ៉ាងខ្លាំង ក្នុងការទប់អារម្មណ៍របស់ខ្លួនឲ្យបាននឹងនរ ។ ផ្អែកលើអាការៈបែបនេះ វាជាជំងឺផ្លូវចិត្តមួយចំនួន ដូចជា ថប់អារម្មណ៍ ភ័យខ្លាច ចាញ់ប្រាប បាក់ស្បាត វិកលចរិតរ៉ាំរ៉ៃ ធ្លាក់ទឹកចិត្តដែលមានរោគសញ្ញាថប់អារម្មណ៍លាយជាមួយ ។ល ។ ពេលកើតជំងឺហើយយើងមិនអាចបង្ការបានទេ ។ វិធីបង្ការត្រូវធ្វើដូចករណីសំណួរខាងលើ ។ ការព្យាបាលត្រូវធ្វើដោយវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា ដោយប្រើឱសថ ប្រើការព្យាបាលដោយចិត្តសាស្ត្រ (ព្យាបាលដោយនិយាយ) និងអន្តរាគមន៍ជាច្រើនផ្សេងទៀត ទៅតាមមូលហេតុ និងស្ថានភាពដែលត្រូវប្រឈម ។

***សំណួរ*** ៖ ពេលនិយាយនៅខាងមុខគេ មានអារម្មណ៍ភ័យ មានសំឡេងប្លែកពីនិយាយធម្មតា ជាជំងឺផ្លូវចិត្តឬទេ? ហើយត្រូវព្យាបាលដូចម្តេចខ្លះ?

***ចម្លើយ*** ៖ សំណួរនេះ មានន័យមិនប្រាកដ ធ្វើឲ្យពិបាកយល់ ។ បើតាមតម្រុយរបស់វា សំណួរនេះមានន័យថា មនុស្សម្នាក់ ពេលនិយាយជាមួយគេឯង មានអារម្មណ៍ភ័យៗ ពេលមានសំឡេងអ៊ូអរ ការនិយាយកាន់តែប្លែកពីធម្មតា ។ តើនេះជាជំងឺឬទេ? តើត្រូវព្យាបាលដូចម្តេច? បើបែបនេះមែនការឆ្លើយនឹងត្រូវធ្វើតាមដូចតទៅ ។

យោងលើអាការៈខាងលើ គេអាចដឹងថា នេះជាការភ័យមួយហួសពីការភ័យក្នុងក្របខណ្ឌធម្មតា ព្រោះមនុស្សម្នាក់អាចភ័យ នៅពេលជួបនឹងព្រឹត្តិការណ៍ដែលគួរឲ្យភ័យខ្លាចសម្រាប់មនុស្ស ជាទូទៅ តែការភ័យខ្លាចនេះមិនកើតមានយូរទេ គឺតែរយៈមួយទៅពីរអាទិត្យប៉ុណ្ណោះ វានឹងបាត់ទៅវិញឯង ហើយមនុស្ស



លោកគ្រូសួរសំណួរទាក់ទងនឹងជំងឺផ្លូវចិត្ត ទៅវេជ្ជបណ្ឌិត ការ ស៊ុនបូណាត

ណាក៏ភ័យដែរ ។ បើការភ័យនោះគ្មានហេតុផលសមរម្យ និងដែលមានរយៈពេលយូរលើសពីរយៈពេលខាងលើនេះ ពិតជាការភ័យដែលសម្គាល់បានថា អ្នកនោះមានជំងឺផ្លូវចិត្តហើយ ។ ឯការព្យាបាល ត្រូវធ្វើដូចក្នុងសំណួរមុនដែរ ។

**សំណួរ** ៖ ខ្ញុំបាទឈ្មោះ ឈាង គឹមស៊ុំ គ្រូបង្រៀននៅអនុវិទ្យាល័យជ្រោយតាកែវ ។ តើការគិតច្រើន ហេតុអ្វីបានជាចេះតែស្រមើស្រមៃឃើញអ្វីៗផ្សេងទៅវិញ?

**ចម្លើយ** ៖ ការគិតច្រើនតែងកើតមានលើមនុស្សធម្មតា ។ តែការគិតច្រើនជ្រុល និងគ្មានហេតុផលសមរម្យ ហើយជាប្រចាំវាជាភាពមិនប្រក្រតីមួយ ដែលអាចចាត់ទុកបានថា ជារោគសញ្ញានៃជំងឺផ្លូវចិត្ត ។ ធម្មតា បើការគិតច្រើនដែលបង្កដោយជំងឺផ្លូវចិត្តវាបណ្តាលមកពីការគ្រប់គ្រងអារម្មណ៍មិនបាន ហើយការផ្តង់គំនិតក៏មិនអាចធ្វើទៅបានដែរ ជាហេតុធ្វើអោយបាត់ម្ចាស់ការក្នុងការគ្រប់គ្រងអារម្មណ៍ ។ ហេតុនេះហើយបានជាកាលណាអ្នកណាម្នាក់មានការគិតច្រើន វាចេះតែធ្វើឲ្យចេះតែគិត ទោះជាមិនចង់ គិតក៏វាគិតដោយខ្លួនឯងដែរ ហើយដែលធ្វើឲ្យអារម្មណ៍ចេះតែហោះហើរមិនឈប់ឈរ ធ្វើឲ្យការប្រុងប្រយ័ត្នស្តាប់មិនបានជាប់លាប់នឹងអ្នកកំពុងនិយាយ ដែលធ្វើឲ្យការចងចាំកាន់តែត្រូវចុះខ្សោយ ។ ការស្រមើស្រមៃនេះ បណ្តាលមកពីអារម្មណ៍ហោះហើរនេះឯង ដែលធ្វើឲ្យអ្នកគិតច្រើន ចេះអណ្តែតអណ្តូងទៅតាមអារម្មណ៍ដែលហោះហើរនោះ និយាយឲ្យងាយស្តាប់ គឺខ្លួននៅនឹងដី អារម្មណ៍ហោះហើរទៅឆ្ងាយពីអ្វីដែលនៅជុំវិញខ្លួន មិនចាប់អារម្មណ៍នឹងអ្វីដែលនៅជុំវិញខ្លួនសោះទេ ជួនកាលគេ អាចចូលដល់ដំណាក់ ប្រដូចគ្នានឹងការលក់ក្នុងបានដែរ ។ ចង់ពិចារណា ឬគិតពីអ្វីមួយក៏មិនអាចធ្វើទៅបានដែរ ដូចពាក្យសាមញ្ញតែងនិយាយថា ព្រលឹងចេញដើររកស៊ីបាត់អស់ហើយ ឬព្រលឹងចេញពីខ្លួន ឬអារម្មណ៍មិននៅនឹងខ្លួន ។

**សំណួរ** ៖ នៅពេលដែលខ្ញុំអង្គុយរៀន ខិតខំស្តាប់គ្រូពន្យល់ ប៉ុន្តែវាហាក់ដូចជាគ្មានអារម្មណ៍ផ្តោតទៅលើមេរៀននេះសោះ តើទាំងនេះ បណ្តាលមកពីមូលហេតុអ្វី?

**ចម្លើយ** ៖ នេះជាករណីដូចគ្នានឹងក្នុងសំណួរមុនដែរ ។

**សំណួរ** ៖ តើជំងឺផ្លូវចិត្តកើតឡើងដោយសារអ្វី? ព្យាបាលដូចម្តេច?

ជាធម្មតា មនុស្សយើងរស់នៅតែងតែជួបប្រទះនឹងបញ្ហារឿងរ៉ាវ ហេតុការណ៍ បរិយាកាស ព្រឹត្តិការណ៍ ឧបទ្ទវហេតុ គ្រោះថ្នាក់ គ្រោះមហន្តរាយនានា ពីសង្គម ពីមនុស្សផ្សេង ពីក្រុមមនុស្សពីរបបនយោបាយ ពីអង្គភាព ពីប្រពន្ធ ពីគ្រួសារ ពីដៃគូ ពីគូបដិបក្ខពីកល្យាណមិត្ត ពីធម្មជាតិ ប្រពៃណីទម្លាប់ ពីប្រវត្តិសាស្ត្រ ពីទស្សនៈ ពីវិទ្យាសាស្ត្រនានា ពីការសាកល្បង ពីភាពចៃដន្យ ពីសត្វពីសង្គម ឬ បរិយាកាសសង្គម សុខភាពរាងកាយ ។ ទាំងអស់នេះគេអាចកំណត់បានត្រឹមតែបួន ដូចតទៅ ៖ កត្តាផ្លូវចិត្ត កត្តាផ្លូវកាយ កត្តាសង្គម និងកត្តាជំនឿ ។ ជាទូទៅ ជំងឺផ្លូវចិត្តច្រើនកើតមកពីបញ្ហាទាំងបួន គ្រាន់តែករណីខ្លះ កត្តាណាមួយនៃកត្តាទាំងបួន ដើរតួខ្លាំងជាងកត្តាដទៃផ្សេងទៀត ហើយដែលឥទ្ធិពលដែលកត្តាទាំងនេះ វាច្រើនលើសលប់លើការអត់ទ្រាំ ឬការអត់ធន់ ឬវាមានភាពម្ចាស់ការលើមនុស្សម្នាក់ៗ ទើបវាបង្កឲ្យទៅជាជំងឺផ្លូវចិត្ត ។ ការព្យាបាល ត្រូវធ្វើដូចគ្នានឹងករណីនៃសំណួរមុនដែរ ។

**សំណួរ** ៖ នៅពេលមនុស្សម្នាក់មានជំងឺបាក់ស្បាត តើត្រូវដោះស្រាយរបៀបណា?

**ចម្លើយ** ៖ ត្រូវរកគ្រូពេទ្យព្យាបាល ។ ជាទូទៅអ្នករស់នៅជុំវិញត្រូវមានព្រហ្មវិហារធម៌ដល់អ្នករងគ្រោះនោះ ព្រោះអ្នកជំងឺប្រភេទនេះ ត្រូវការយកចិត្តទុកដាក់ ការយល់ចិត្ត ការធ្វើឲ្យកក់ក្តៅ ជួយលើកទឹកចិត្ត ត្រូវចៀសវាងឥរិយាបថកោងកាច ភាពប្រផេងប្រផាង មិនត្រូវឲ្យដឹងរឿងរ៉ាវ ដែលធ្វើឲ្យភ័យតក់ស្លុតទេ ។ មិនត្រូវឲ្យនៅម្នាក់ឯង ហើយគួរជួយស្វែងរកគ្រូពេទ្យឯកទេសឲ្យឆាប់បានជួយពិនិត្យ និងព្យាបាលអោយទាន់ពេល ។

**សំណួរ** ៖ តើការដេកមិនលក់ ជាជំងឺផ្លូវចិត្តដែរឬទេ? បើជាជំងឺផ្លូវចិត្ត តើយើងត្រូវធ្វើដូចម្តេច?

**ចម្លើយ** ៖ ការដេកមិនលក់ អាចជាករណីធម្មតារបស់មនុស្សម្នាក់ៗ តែក៏អាចជារោគសញ្ញានៃជំងឺទាំងផ្លូវកាយ ទាំងផ្លូវចិត្តដែរ ។ អាការៈដេកមិនលក់មួយមុខ មិនអាចកំណត់បានថាជាជំងឺបានទេ ទាល់តែកើតមានអាការៈរោគផ្សេងជាច្រើនទៀតទើបអាចចាត់ទុកបានថាជាជំងឺបាន ។ ជាទូទៅគេមិនព្យាបាល ដើម្បីបន្ធូររោគសញ្ញាទេ តែគេព្យាបាលជំងឺទាំងមូលតែម្តង ។ បើតាម

អាការៈដេកមិនលក់ត្រូវទៅរកគ្រូពេទ្យពិនិត្យឲ្យបានច្បាស់ ទើបគេអាចកំណត់ធ្វើការព្យាបាលបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ។

**សំណួរ** ៖ តើហេតុអ្វីបានជា នួន ជា ឬ មេដឹកនាំដទៃទៀតក្នុងរបបនោះមិនទទួលកំហុសពេលដែលគេកាត់ទោសខ្មែរក្រហម?

**ចម្លើយ** ៖ នេះជាបញ្ហានយោបាយ ដែលមិនអាចដោះស្រាយ ឬ បកស្រាយតាមក្បួនចិត្តវិទ្យាបានទេ ព្រោះនយោបាយ ជាវិទ្យាសាស្ត្រមួយផ្សេងទៀត ដែលមានសមាសភាពចម្រុះច្រើន ដែលត្រូវផ្សារភ្ជាប់នឹងប្រវត្តិសាស្ត្រ និងមនោគមវិជ្ជា មនុស្សសាស្ត្រ សង្គមសាស្ត្រ ចិត្តសាស្ត្រនយោបាយ និង វិទ្យាសាស្ត្រនយោបាយ ។

**សំណួរ** ៖ តើការផ្ដើមយល់ពីអត្តចរិតរបស់មនុស្ស គេត្រូវកំណត់លើអ្វីខ្លះ? ដើម្បីបង្ហាញពីសភាពរបស់មនុស្ស គេត្រូវធ្វើដូចម្ដេច?

វិទ្យាសាស្ត្រដែលអាចអោយយល់ពីអត្តចរិតមនុស្សបាន គឺចិត្តសាស្ត្រ ជាពិសេសវិទ្យាសាស្ត្រដែលទាក់ទងនឹងចរិយាសាស្ត្រ និងអត្តចរិតមនុស្ស ។ វិទ្យាសាស្ត្រនេះ មានការលាយឡំចូលជាមួយនឹងជីវវេជ្ជសាស្ត្រ ពិន្ទុវិទ្យា ចិត្តសាស្ត្របុគ្គល ចិត្តសាស្ត្រសង្គម ការសិក្សាវប្បធម៌ជាដើម ។ យោងលើទ្រឹស្ដីច្បាប់ រូបមន្តដែលទាក់ទងទៅនឹងវិទ្យាសាស្ត្រទាំងប៉ុន្មានខាងលើនេះ ទើបយើងអាចពិនិត្យ សង្កេតលើសកម្មភាព ពាក្យសម្ដី កាយវិការ ប្រតិកម្ម សម្ដីសំដៅ ការគិតគូរ ផ្នត់គំនិត និន្នាការ ការចូលចិត្ត ការមិនចូលចិត្ត ដោយប្រៀបធៀបទៅនឹងខ្នាតដែលមានកំណត់បញ្ជាក់អំពីប្រភេទអត្តចរិតមនុស្ស ទើបយើងអាចកំណត់អំពីអត្តចរិតនៃមនុស្សម្នាក់ឲ្យបានជាក់ច្បាស់ ត្រឹមត្រូវតាមក្បួនដែលសាកលលោកប្រើប្រាស់ជាទូទៅ និង ទៅតាមស្តង់ដារនៃមនុស្សដែលភាគច្រើនមាន ។

**សំណួរ** ៖ សិស្សម្នាក់ ពេលធម្មតានិយាយត្រដិតៗ ប៉ុន្តែពេលគ្រូហៅសួរសំណួរឆ្លើយកាន់តែត្រដិតៗ តើនេះបណ្ដាលមកពីមូលហេតុអ្វី? តើគួរជួយគេដោយវិធីណា?

**ចម្លើយ** ៖ បើនៅពីក្មេង មានចាប់ផ្ដើមកើតត្រដិត នោះមកពីកុមារនោះមានការភិតភ័យ ដែលធ្វើឲ្យគេមិនអាចទប់ចិត្តទប់អារម្មណ៍បាននឹងនរក្នុងការរកពាក្យមកនិយាយ ។ ធម្មតា បើយើងចង់និយាយអំពីអ្វីមួយ យើងត្រូវរកនឹកពាក្យជាមុនសិន ទើបយើងអាចនិយាយចេញមកនូវពាក្យនោះបានដោយឥតមានរអាក់រអួល ។ បើយើងមានការភ័យព្រួយ តិច ឬ ច្រើន វាធ្វើឲ្យការរកនឹកពាក្យមកនិយាយមិនដំណើរការល្អចប់ចុងចប់ដើម ហើយត្រូវរអាក់រអួល ឯការរកពាក្យសម្រាប់និយាយក៏រអាក់រអួលដែរ ដែលធ្វើឲ្យនិយាយត្រដិត ។ យើងមិនត្រូវបង្ខំអ្នកត្រដិតឲ្យច្រើននិយាយ ឬធ្វើឲ្យគេខ្លាចពេលនិយាយទេ តែត្រូវលើកទឹកចិត្ត ជំរុញឲ្យគេនិយាយចេញមកបានកាន់តែស្រួលឡើងៗ និងមិន ត្រូវសើចពេលគេនិយាយមិនបានល្អនោះទេ ។

**សំណួរ** ៖ តើកត្តាអ្វីខ្លះដែលធ្វើអោយមនុស្សបាត់បង់សតិបញ្ញាញាណ?

**ចម្លើយ** ៖ មិនមានពាក្យថា សតិបញ្ញាញាណទេ មានតែពាក្យសតិ ឬ សតិអារម្មណ៍ ឬ សតិស្មារតី សតិសម្បជញ្ញៈ តែប៉ុណ្ណោះ ។ សតិ គឺជាការរំឭកដឹងខ្លួនដោយខ្លួនឯង ។ មនុស្សដែលបាត់សតិមានន័យខុសគ្នា ទៅតាមបរិបទដែលយើងកំពុងនិយាយបែបផ្សេងៗគ្នាដែរ ។

◆ សតិក្នុងសីលធម៌ មានន័យថា ការរំឭកដឹងខ្លួន យល់ខុសត្រូវប្រកាន់យកសេចក្ដីថ្លៃថ្នូរ និងត្រឹមត្រូវ

◆ សតិក្នុងវេជ្ជសាស្ត្រទូទៅ មានន័យថា ភាពដឹងខ្លួន បើមនុស្សម្នាក់បាត់សតិគឺគេសន្លប់បាត់មាត់ មិនដឹងអ្វីទាំងអស់

◆ សតិក្នុងចិត្តសាស្ត្រ ឬ វិកលវិទ្យា មានន័យថា ការដឹងខ្លួនថាខ្លួនកំពុងធ្វើអ្វីដោយមនុស្សនោះមិនមានសន្លប់បាត់ស្មារតីទេ ។

មនុស្សមានសតិ គឺមនុស្សដឹងថាខ្លួនធ្វើអ្វីមួយខុស ឬ ត្រូវ នៅពេលណា ថ្ងៃណាជាដើម ។ បើមនុស្សមិនមានសតិ គឺមនុស្សនោះនៅរស់កន្ទើកធ្វើអ្វីៗ ដោយមិនដឹង មិនចាំថាខ្លួនធ្វើអ្វីមួយទេ ។ ឧទាហរណ៍ មនុស្សម្នាក់ពេលមានកំរោលចូល នៅរស់ធម្មតា ធ្វើអ្វីៗដោយមិនដឹង មិនចាំថាខ្លួនធ្វើអ្វីមួយទេក្នុងពេលនោះ ។ មនុស្សកើត ជំងឺឆ្កួតជ្រូក ពេលកំពុងធ្វើទុក្ខ ទោះជាប្រកាច់ ឬមិនប្រកាច់ ធ្វើឲ្យគេមិនដឹងថា ខ្លួនពេលនោះមានហេតុការណ៍យ៉ាងណាទេ តែគេមិនមែនជាមនុស្សសន្លប់ទេ ។

**សំណួរ** ៖ ដូចម្ដេចដែលហៅថា មនុស្សបែកឆ្វេង? តើមនុស្សប្រភេទនេះ បណ្ដាលមកពីអ្វីខ្លះ?

**ចម្លើយ** ៖ មនុស្សបែកឆ្វេង នេះជាពាក្យប្រើប្រាស់ក្នុងវប្បធម៌ប្រពៃណីខ្មែរ តែមិនមានក្នុងចិត្តសាស្ត្រទេ ។ នេះជាប្រភេទមនុស្ស ដែលប្រកាន់យកនូវរបៀបរបបមួយសម្រាប់ការនិយាយស្តី ការត្រិះរិះពិចារណា ចំណង់ចំណូលចិត្ត គោលគំនិតរបៀបរបបរស់នៅជាដើម ដែលមិនចុះនឹងគេឯងជាទូទៅ តែមនុស្សប្រភេទនេះ មានការចុះសម្រុងនឹងមនុស្សប្រភេទដូចគ្នា ដែលបុរាណតែងនិយាយថា នាងរត់រកអ្នក ឯខាតលក្ខណ៍រត់រកកំបាក់អន្ទារ ។ មនុស្សប្រភេទនេះ មិនសូវមានមិត្តភក្តិ និងញាតិសន្តានទេ ហើយធ្វើអ្វីក៏ត្រូវនឹងគេឯងដែរ ហើយតែងតែទទួលនូវភាពចម្រូងចម្រាសជាមួយអ្នកដទៃ ។

**សំណួរ** ៖ តម្រូវការមនុស្សគ្មានដែនកំណត់ទេ ។ ការឲ្យកម្រៃទឹកប្រាក់តិចតួចក្នុងការមករៀនវគ្គបំប៉ននេះត្រឹមតែ ១០ ដុល្លារក្នុងមួយថ្ងៃ តើវាអាចបណ្តាលឲ្យប៉ះពាល់ដួងចិត្តដែរ ឬទេ? តើប៉ះពាល់ដល់កម្រិតណា?

**ចម្លើយ** ៖ ការពិតនេះ ជាគោលការណ៍របស់ក្រសួងអប់រំដែលបានកំណត់រួចមកហើយ ហើយដែលមិនអាចអ្នកណាធ្វើឲ្យខុសពីការកំណត់បានឡើយ ។ ធម្មតា ការសិក្សានេះ ជាការសិក្សាបន្តដើម្បីបង្កើនចំណេះដឹង និងសមត្ថភាពដល់សិក្ខាកាម ដែលមកចូលរួមសម្រាប់បំពេញការងារទៅមុខបានកាន់តែប្រសើរឡើងៗជាលំដាប់ ។ អ្នកប្រកបវិជ្ជាជីវៈណាក៏ត្រូវការវគ្គបណ្តុះបណ្តាលបន្តនេះដែរ ។ ជាទូទៅអ្នកចូលរួម ត្រូវបង់ថវិកាដែលជាសិទ្ធិសម្រាប់ចូលរួមសិក្ខាសាលានេះ ព្រោះវាមិនបាននាំយកមកនូវចំណេះដឹងថ្មីសម្រាប់សិក្ខាកាម មានសមត្ថភាពធ្វើការងារទៅមុខទៀត ដែលមិនទៅដដែលនោះទេ ហើយដើម្បីឲ្យសិក្ខាកាមពង្រីកចំណេះដឹង ចំណេះធ្វើរបស់ខ្លួនជាបន្តបន្ទាប់ ។ នេះជាភារកិច្ចរបស់សិក្ខាកាមទៅវិញទេ ។ ទឹកប្រាក់មានចំនួនតិចតួចមែនពិត តែចំណេះដឹងសម្រាប់យកទៅពង្រីកគុណភាពគរុកោសល្យមានតម្លៃមិនអាចគិតបានទេ ។

**សំណួរ** ៖ មនុស្សម្នាក់ដែលចូលចិត្តអង្គុយសើច តែម្នាក់ឯងគ្មានការចូលចិត្តលេងជាមួយអ្នកដទៃ ។ តើវាបណ្តាលមកពីកត្តាអ្វីខ្លះ?

**ចម្លើយ** ៖ ដូចគ្នានឹងករណីសំណួរខាងលើដែរ ។

**សំណួរ** ៖ សិស្សតែងមិនចូលចិត្តរៀនប្រវត្តិសាស្ត្រ ។ តើត្រូវធ្វើដូចម្តេចដើម្បីឲ្យសិស្សចូលចិត្តរៀនប្រវត្តិសាស្ត្រ?

**ចម្លើយ** ៖ ជាទូទៅសិស្សអាចមិនសូវរៀនមុខវិជ្ជានេះ ព្រោះគេយល់ថា វិជ្ជានេះត្រូវប្រើការចងចាំ ហើយត្រូវរំពុកកាលបរិច្ឆេទ ដែលជាហេតុធ្វើឲ្យពិបាកទន្ទេញឲ្យចាំ ។ មួយវិញទៀត ជាទូទៅការបង្រៀនមុខវិជ្ជានេះច្រើនតែនិយាយបរិយាយដោយមិនមានការពន្យល់ ឲ្យយល់ហើយចងចាំ ដូចវិជ្ជាផ្សេងៗទៀត មានដូចជាគណិតវិទ្យា រូបវិទ្យា ជីវវិទ្យា ។ល ។ ប៉ុន្តែ មានមុខវិជ្ជាខ្លះទៀតក៏សិស្សពិបាករៀនហើយមិនចូលចិត្តរៀនដែរ ព្រោះការរៀនតម្រូវឲ្យទន្ទេញចាំមាត់ក្នុងនោះមានគីមី សីលធម៌ រូបមន្តនានា ។ តែរាល់ការបង្រៀនដែលមានគរុកោសល្យខ្ពស់ ហើយដែលគ្រូអាចធ្វើឲ្យសិស្សជក់ចិត្ត ងាយស្តាប់ ងាយយល់ ងាយចងចាំ ឃ្លោងឃ្លាមេរៀនងាយយល់ នោះសិស្សពិតជាចង់រៀនដែរហើយ ។ ទាំងនេះអាស្រ័យ ការឈ្លាសវៃរបស់គ្រូក្នុងការប្រើប្រាស់គរុកោសល្យអោយត្រឹមត្រូវទៅតាមសាច់មេរៀននីមួយៗ ។

**សំណួរ** ៖ ហេតុអ្វីបានជាមនុស្សឆាប់ខឹងនៅពេលធ្វើអ្វីមួយមិនបានសម្រេច? តើយើងត្រូវធ្វើដូចម្តេចសម្រាប់ទប់ស្កាត់នូវអារម្មណ៍បែបនេះ? តើយើងត្រូវធ្វើដូចម្តេចដើម្បីបន្ធូរអារម្មណ៍ទាំងនោះ?

**ចម្លើយ** ៖ ករណីដែលធ្វើអោយឆាប់ខឹង គឺមកពីប្រព័ន្ធទប់សន្ទុះចិត្តត្រូវបានចុះខ្សោយដោយប្រការផ្សេងៗ ។ ជាធម្មតាមនុស្សណាក៏ចេះខឹងដែរ តែវាមានហេតុផលសមរម្យរបស់វាដែលគេឯងគ្រប់គ្នាទទួលយកបាន ហើយការខឹងនេះក៏វាមានការផ្សារភ្ជាប់ទៅអាយុ និងរបៀបរបប វប្បធម៌ និងទំនៀមទម្លាប់នៃការរស់នៅ ។ ការងាយឆាប់ខឹងឆេវឆាវ អាចជាករណីធម្មតា និងមិនប្រក្រតី ។ ករណីធម្មតា មានដូចជា ប្រជាជននៃជនជាតិ ពូជសាសន៍មួយចំនួនខាងលើមានការខឹង ឆេវឆាវ ជាងជនជាតិ ពូជសាសន៍មួយចំនួន ដោយការរស់នៅរបស់គេត្រូវប្រឈមនឹងការលំបាក ហើយដែលតម្រូវឲ្យគេប្រឹងរើបម្រះតទល់នឹងស្ថានភាពនោះទើបអាចរស់បាន ។

ជាធម្មតា មនុស្សពូជសាសន៍មួយ ជនជាតិមួយ មានចរិត

តាមទម្រង់មួយរបស់គេ កាលណាមានការខុសជ្រុលខ្លាំង វាជាការមិនប្រក្រតី ។ ដូចនេះ ការខឹងឆេវឆាវ ក៏ដូចគ្នាដែរ ។ ជាការពិត មនុស្សហេវហត់ មនុស្សអត់ងងុយ មនុស្សឆាប់ភ័យ មនុស្សត្រូវគេគាបសង្កត់ មនុស្សត្រូវគេធ្វើឲ្យមិនទុកចិត្ត ខកចិត្ត ។ ប្រការមួយទៀត ប្រទេសយើងច្រើនលេងញោះមនុស្ស កាលពីនៅវ័យក្មេងឲ្យជេរ ឲ្យកាច ឲ្យប្រឡោត ឲ្យខ្លាច ដែលយូរមក ក៏ជាមនុស្សកាចឆាប់មួម៉ៅឆាប់ខឹង ។ តែមានមនុស្សមួយចំនួនទៀត ដែលមិនធ្លាប់កាច តែក្រោយមកត្រូវទទួលរងគ្រោះប្រការណាមួយ ហើយបានបណ្ដាលអោយកើតជំងឺផ្លូវចិត្ត ក៏បានធ្វើឲ្យប្រព័ន្ធគ្រប់គ្រងចិត្ត សន្ទុះចិត្តត្រូវចុះខ្សោយក៏ធ្វើឲ្យទៅជាឆាប់ខឹងឆេវឆាវ ជួនកាលរហូតដល់ខឹងមិនសមហេតុផល ឬ នឹងជ្រុលហួសដែលបង្កឲ្យទៅជាបង្កើតបានជាហិង្សា ឬឈានរហូតដល់ធ្វើមនុស្សឃាតទៀតផងក៏មាន ។

**សំណួរ :** ត្រូវធ្វើយ៉ាងណាកុំឲ្យពិបាកចិត្ត?

ការពិបាកចិត្ត ជាប្រតិកម្ម ប្រឈមទៅនឹងការស្មុគស្មាញ ការប្រឈមនឹងឧបសគ្គ ការមិនអាចធ្វើម្ចាស់ការលើបញ្ហាណាមួយបាន ឬ ជាផលប៉ះពាល់នេះការបរាជ័យលើអ្វីមួយ ដោយប្រការណាមួយ ។ រាល់ការពិបាកចិត្តមិនសុទ្ធតែជាអាការៈ រាល់ការពិបាកចិត្តមិនសុទ្ធតែជាអាការៈនៃជំងឺផ្លូវចិត្តទាំងអស់ទេ ។ ជាធម្មតា មនុស្សតែងតែមានការពិបាកចិត្តនៅពេលប្រឈមនឹងការពិបាកណាមួយ ដែលពេលនោះមិនទាន់អាចស្មានថាអាចបន្ធូរទៅបាន ឬ មិនទាន់រកបាននូវដំណោះស្រាយ វាក៏ធ្វើអោយពិបាកចិត្តមួយរយៈ ក្រោយមកក៏រសាយអស់ទៅ ហើយក្រោយមកក៏មានជួបប្រទះថ្មីម្ដងទៀត ។ ក្នុងជីវិតមនុស្ស មិនមានអ្នកណាមិនចេះពិបាកចិត្តនោះទេដូចដែលព្រះបានសម្ដែងថា មានរូប មានទុក្ខ ឬ រូបំ ទុក្ខំ អនត្តា ។ តែការដែលចេះតែមានការពិបាកចិត្តជាប្រចាំ អាចបណ្ដាលមកពីក្នុងជីវិតរបស់គេ មានការជួបប្រទះ ភាពបរាជ័យមិនឈប់មិនឈរ ឬ គេមានទុក្ខធំ ដែលមិនអាចដោះស្រាយបានភ្លាមៗ ហើយដែលត្រូវប្រើពេលច្រើនឆ្នាំទើបដោះរួច ។ ក្នុងប្រការផ្សេងទៀត ការពិបាកចិត្តជាអាការៈនៃជំងឺផ្លូវចិត្តផងដែរ ។

គេពិបាករកឲ្យបានមនុស្សមិនចេះពិបាកចិត្តណាស់ ។ ករណីខ្លះមនុស្សមិនចេះពិបាកចិត្ត ពេលគេខ្វាយខ្វល់គ្រប់គ្នា ខ្លួនមិនមានស្មុគអ្វីសោះ នេះក៏ជាករណីមិនធម្មតាដែរ ព្រោះមានជំងឺផ្លូវចិត្តខ្លះ ធ្វើឲ្យអ្នកជំងឺមិនចេះពិបាកចិត្ត ហើយសប្បាយខុសគេខុសឯងរហូត ។

ដូចដែលព្រះពុទ្ធបានលើកឡើងថា អវិជ្ជាជាទុក្ខ ដូចនេះ ការខំរៀនឲ្យចេះដឹង ការស្វែងយល់ការពិត យល់បញ្ហា ធ្វើឲ្យរសាយការពិបាកចិត្ត ។ លើសពីនេះ ការរកជំនួយ ដូចរកអ្នកណាម្នាក់ឲ្យជួយដោះស្រាយការលំបាក ឬ ឲ្យគេយល់អំពីខ្លួន គេព្យាយាមបន្ធូរបន្ថយភាពតានតឹងនោះឲ្យបាន ។ ជួនកាលគេអាចបន្ធូរអារម្មណ៍ដោយការសម្រាក ការលេងកីឡា ការធ្វើសមាធិវិបស្សនា ការតាំងធម៌ ការដើរកំសាន្ត ការជួបជុំមិត្តភក្តិដើម្បីសួរយោបល់ ឬពិភាក្សានិយាយគ្នាលេង ការធ្វើការហត្ថកម្ម ការងារដែលធ្វើឲ្យយើងជក់ចិត្ត ការរកគ្នាជួបជុំសើចសប្បាយ ។ល ។ បើការពិបាកចិត្តដោយមានជំងឺផ្លូវចិត្ត ត្រូវរកវេជ្ជបណ្ឌិតឯកទេសរិកលវិទ្យាជួយព្យាបាល ។

**សំណួរ :** ដើម្បីចូលរួមសម្រាលនូវវិបត្តិរបស់ជនរងគ្រោះនៅសម័យខ្មែរក្រហម ដែលបាននៅសល់ជីវិតដល់សព្វថ្ងៃ យើងគួរធ្វើយ៉ាងណាខ្លះ? តើយើងត្រូវអប់រំក្មេងជំនាន់ក្រោយយ៉ាងដូចម្ដេច ដើម្បីឲ្យគេចងចាំអំពីរបបខ្មែរក្រហម?

**ចម្លើយ :** យើងត្រូវចាត់ទុកថា រាល់អ្នករងគ្រោះដោយរបបខ្មែរក្រហមសុទ្ធតែជាជនរងគ្រោះ ដែលយើងត្រូវផ្ដល់នូវព្រហ្មវិហារធម៌ មិនធ្វើការប្រកាន់គ្នាទៅវិញទៅមក ។ ត្រូវស្វែងយល់ឥរិយាបថ អាការៈ កាយវិការខុសឆ្គងរបស់ជនទាំងនោះ បណ្ដាលមកពីជំងឺផ្លូវចិត្ត ដែលបានបន្សល់ទុកមកឲ្យដោយរបបខ្មែរក្រហម ។

ដើម្បីឲ្យក្មេងជំនាន់ក្រោយចងចាំត្រូវបង្រៀនទៅគេនូវឯកសារមេរៀន ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកជូនដើម្បីបង្រៀន ។

**សំណួរ :** ទរមៀរ?

**ចម្លើយ :** ពាក្យថា tremor មានន័យថា ញ័រ ដែលអាចជាទូទៅមាន ញ័រដៃ ញ័រជើង ជាដើម ។ អាការៈញ័រនេះ អាចបណ្ដាលមកពីប្រព័ន្ធខួរក្បាលមានជំងឺ ជួលកាលមកពីជំងឺផ្លូវកាយមួយចំនួនដែលមានការប៉ះពាល់ដល់ប្រព័ន្ធខួរក្បាល ។ ករណីមួយចំនួនទៀតវាមានការទាក់ទងនឹងជំងឺផ្លូវចិត្ត ។ **ភារ ស៊ុនបូណាត**

# ប្តូរឈ្មោះដើម្បីរក្សាជីវិត

សុន វណ្ណា មានអាយុ៥៨ឆ្នាំ ជាសាស្ត្រាចារ្យផ្នែកប្រវត្តិវិទ្យា នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ គាត់មានស្រុកកំណើតនៅសង្កាត់លេខ៥ ក្នុងទីក្រុងភ្នំពេញ ។ វណ្ណា មានឪពុកធ្វើការជាលេខាធិការទី៥ នៃក្រសួងពាណិជ្ជកម្ម ក្នុងរដ្ឋការ លន់ នល់ និងម្តាយជាមេផ្ទះ ។ គាត់ជាកូនទីពីរនៅក្នុងចំណោមបងប្អូនប្រាំបួននាក់ ។



អ្នកគ្រូ ស៊ុន វណ្ណា ថតនៅមហាវិទ្យាល័យប្រវត្តិវិទ្យា

នៅក្នុងឆ្នាំ១៩៧៥ យុវតី សុន វណ្ណា គឺជាសិស្សម្នាក់ដែលកំពុងតែរៀននៅថ្នាក់បញ្ចប់នៃវិទ្យាល័យយុគន្ធរ នៅក្នុងវ័យ១៩ឆ្នាំ ។

ពេលចូលឆ្នាំខ្មែរ នាខែមេសា ឆ្នាំ១៩៧៥ គឺជាពេលវេលាវិស្សមកាលរបស់ វណ្ណា ។ កំពុងតែជួបជុំគ្រួសារនៅផ្ទះក្នុងពេលចូលឆ្នាំខ្មែរ ស្រាប់តែមានយោធាខ្មែរក្រហមមកប្រាប់គ្រួសារទាំងមូលឲ្យចាកចេញពីផ្ទះដើម្បីធ្វើការបោសសម្អាតខ្មាំង ។ យោធាទាំងនោះបានប្រាប់ទៀតថាឲ្យចេញទៅតែខ្លួនទទេតែប៉ុណ្ណោះ មិនចាំបាច់យកអ្វីទៅជាមួយនោះទេនាំតែលំបាក ។ មិនតែប៉ុណ្ណោះយោធាទាំងនោះបានបញ្ជាក់ទៀតថា កុំបារម្ភពីទ្រព្យសម្បត្តិ ព្រោះមិនបាត់បង់ទៅណាទេ អង្គការចេះថែរក្សាឲ្យហើយ ។ វណ្ណា ព្រមទាំងគ្រួសារត្រូវយោធាខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ការជម្លៀសនេះ គោលដៅរបស់យោធាខ្មែរក្រហមគឺត្រូវជម្លៀសប្រជាជន ក៏ដូចជាគ្រួសារវណ្ណា ទៅតាមផ្លូវជាតិលេខ១ ។ លុះទៅដល់កៀនស្វាយ យោធាខ្មែរក្រហមប្រាប់ឲ្យគ្រួសាររបស់គាត់ឈប់សម្រាកនៅទីនោះមួយយប់ ។ បន្ទាប់មកទៀត វណ្ណា និងគ្រួសារបានបន្ត ដំណើរទៅមុខដោយឆ្លងកាត់កោះក្របី និងតាខ្មៅឡើងមកផ្លូវជាតិលេខ២វិញ ។ ការធ្វើការឆ្លងមកខាងផ្លូវជាតិលេខ២នេះ មិនមែនជាទិសដៅដែលខ្មែរក្រហមឲ្យគ្រួសារគាត់ទៅទេ ។

នៅពេលធ្វើដំណើរកាត់តាខ្មៅ វណ្ណា បានឃើញសាកសពមនុស្សស្លាប់ជាច្រើនអណ្តែតតាមទន្លេ និងស្អុំងព្រែកត្នោត ។ ក្រោយពីទៅដល់កណ្តាលស្ទឹង ខ្មែរក្រហមបានសួរអំពីឪពុកគាត់ថាតើគាត់ធ្វើអ្វីខ្លះកាលពីមុន? ដំបូង វណ្ណា បានឆ្លើយប្រាប់ទៅកងឈ្លបនូវការពិតថា ឪពុករបស់គាត់អ្នកធ្វើការរដ្ឋការ ។ តែក្រោយមកគាត់ក៏បានកុហកវិញ ដោយសារតែគាត់បានដឹងរឿងខ្លះៗថាមានការសម្លាប់អ្នកមានចំណេះដឹងនៅក្នុងរបប លន់ នល់ ។ ការជម្លៀសទៅកណ្តាលស្ទឹង វណ្ណា បានឃើញប្រជាជនចាស់មានសិទ្ធិសម្រេចកិច្ចការផ្សេងៗបាន ប៉ុន្តែចំពោះអ្នកដែលជាប្រជាជន១៧ មេសា ឬប្រជាជនថ្មីវិញមិនមានសិទ្ធិទេ ។ ពេលដែល វណ្ណា ទៅដល់ដំបូងគឺមិនមានផ្ទះសម្រាប់ស្នាក់នៅទេ គឺគាត់បានយកតង់មកសង់ជាខ្ទមសម្រាប់ស្នាក់នៅសិន ។ បន្ទាប់ពីនោះមកមេភូមិបានហៅគ្រួសារគាត់ទៅចុះឈ្មោះ ក្រោយពីចុះឈ្មោះហើយ



អ្នកគ្រូ ស៊ុន វណ្ណា ថតជាមួយនាយកសាលា និងគ្រូៗ នៅឆ្នាំ១៩៨៤



អ្នកគ្រូ សុន វណ្ណា ថតជាមួយយុវសិស្សថ្នាក់ទី ៧“ក” ស្ម័គ្រចិត្តចូលកងទ័ព នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

អង្គការបានចាត់ឲ្យគ្រួសារ វណ្ណា ទៅរស់នៅក្នុងសាលាព្រៃទ្រព្យ ជាអតីតសាលាគរុកោសល្យ ។ វណ្ណា បានរៀបរាប់ទាំងក្តីខ្សឹកខ្សួលថា ការទៅរស់នៅទីនោះគឺមានការលំបាកខ្លាំងណាស់ ព្រោះពេលនោះមានខ្យល់ផងភ្លៀងផង ហើយរឿងដែលគួរឲ្យសង្វេគបំផុតនោះគឺ វណ្ណា ត្រូវបានបាត់បង់ជីដូន ។ ដោយសារតែយាយរបស់គាត់មានវ័យចំណាស់ខ្លាំងពេក (មានអាយុជាង៨០ឆ្នាំ) គឺគាត់មិនមានស្មារតីនឹងនរទេ គាត់តែងតែមានការភ័យតក់ស្លុតនឹងការបាញ់គ្នារបស់ខ្មែរក្រហម និងការទម្លាក់គ្រាប់បែកផ្សេងៗ ។ រឿងទាំងអស់នេះហើយបានធ្វើឲ្យយាយរបស់ វណ្ណា មិនអាចទ្រាំទ្រនឹងហេតុការណ៍នេះ គាត់ក៏បានស្លាប់នៅពេលដែលទើបនឹងជម្លៀសទៅដល់ភ្លាម ។ ក្រោយមកអង្គការបានចាត់តាំងប្រជាជនថ្មីទាំងអស់ឲ្យទៅនៅតាមមុខសញ្ញាដែលបានដាក់ឲ្យរស់នៅ ។

ក្រោយពីមានលំនៅនឹងធឹងហើយអង្គការបានចាប់ផ្តើមជ្រើសរើសមនុស្ស ដើម្បីទៅធ្វើការតាមមុខងារដែលអង្គការបានដាក់ ។ ប្រជាជនទាំងអស់ត្រូវតែធ្វើការចុះឈ្មោះទៅតាមក្រុម ក្រុមនារីផ្សេង យុវជនផ្សេង ។ ក្នុងនោះអង្គការបានស្រង់ប្រវត្តិរូប ហើយដំបូងឡើយ វណ្ណា បានឆ្លើយប្រវត្តិពិតរបស់ខ្លួន ។ កាលពីមុនឈ្មោះរបស់គាត់គឺឈ្មោះ ឌីចាន់ សុវណ្ណា ប៉ុន្តែក្រោយមកទៀត វណ្ណា បានឆ្លើយដោយកុហកថាគាត់មានឈ្មោះថា សុន វណ្ណា វិញ ព្រោះបើឆ្លើយតាមត្រង់នោះខ្មែរក្រហមនឹងអាចយកគាត់ទៅសម្លាប់ ព្រោះតែគាត់ជាកូនអ្នករដ្ឋការ និងជាសិស្សថ្នាក់បញ្ចប់ ។ លុះដល់ខែសីហា ឆ្នាំ១៩៧៥ ឪពុក វណ្ណា បានស្លាប់ដោយសារតែភាពអត់ឃ្លាន និងជំងឺ ។ នៅឆ្នាំ១៩៧៦ វណ្ណា ធ្វើការនៅតែក្នុងស្រុកភូមិប៉ុណ្ណោះ ។

រហូតមកដល់ឆ្នាំ១៩៧៨ អង្គការបានដាក់ទិសឲ្យទៅនៅតាមការដ្ឋានវិញ ។ វណ្ណា ត្រូវបានអង្គការចាត់ឲ្យនៅក្នុងកងពិសេសលេខ៥៣ ដោយធ្វើការលើកទំនប់ ជីកប្រឡាយ និងធ្វើស្រែតាមទិសដែលអង្គការកំណត់ ។ មុននឹងធ្វើការជីកប្រឡាយ អង្គការតែងតែធ្វើមីទ្ទីងមួយដើម្បីប្រមូលយុវជន យុវនារី មកស្តាប់នៅវត្តអន្លុងរមៀត ។ លុះធ្វើមីទ្ទីងចប់ ទើបឲ្យធ្វើដំណើរទៅ



អ្នកគ្រូ សុន វណ្ណា (រូបទីរាប់ពីឆ្វេង) ថតនៅបរិវេណសាលាកម្រិតសិក្សាទី១ រលួស នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៨៣

ការដ្ឋានដើម្បីទៅជីកប្រឡាយនៅខាងត្បូងព្រែកហូរ ។ ពេលទៅធ្វើការនៅទីនោះ វណ្ណា ក៏ចាប់ផ្តើមមានជំងឺខ្វះជីវជាតិ ។ ថ្ងៃមួយត្រូវដល់វេន វណ្ណា ធ្វើជាចុងភៅ ពេលនោះគាត់បានចុះទៅក្នុងត្រពាំងដើម្បីបេះកំប្លោក ជាអកុលសក៏ត្រូវមុតអំបែងនៅក្នុងទឹក ។ របួសនោះមុតនៅត្រង់បាតជើងខាងស្តាំរបស់គាត់ដែលធ្វើឲ្យគាត់ដើរមិនចង់រួច ។ អង្គការបានបញ្ជូនទៅកាន់មន្ទីរពេទ្យ ។ បន្ទាប់ពីព្យាបាលហើយរយៈពេល៧ថ្ងៃ របួសរបស់ វណ្ណា បានធូរស្រាល អង្គការបានចាត់ឲ្យគាត់ទៅធ្វើការនៅការដ្ឋានវិញ ។ ធ្វើការបានបីថ្ងៃ អង្គការក៏បញ្ជូនគាត់មកកាន់មន្ទីរពេទ្យវិញ ព្រោះរបួសរើឡើងវិញ និងបានបន្តសម្រាកព្យាបាលនៅពេទ្យប្រហែលប្រាំមួយខែ ។

បន្ទាប់ពីជាសះស្បើយ អង្គការបញ្ជូនគាត់ទៅកាន់កងដើមវិញ ។ ពេលទៅដល់ទីនោះភ្លាម វណ្ណា ត្រូវទទួលរងការមើលងាយពីសំណាក់មេកង ដោយស្តីថា ជាជនជិះជាន់លើកម្លាំងអ្នកដទៃ និងគ្មានកន្លែងសម្រាប់សម្រាកទៀតផង ។ វណ្ណា តែងតែលួនទៅដេកនៅក្រោមជើងរបស់មេកងទាំងក្តីអាម៉ាស ប៉ុន្តែគាត់មិនដឹងធ្វើយ៉ាងម៉េចក៏ចេះតែទ្រាំៗទៅដើម្បីឲ្យរួចរស់ជីវិត ។ នៅការដ្ឋានម៉ោងធ្វើការគឺចាប់ផ្តើមនៅប្រហែលម៉ោង៣ទៀបភ្លឺរហូតដល់ពេលយប់ទើបត្រឡប់មកកន្លែងសម្រាកវិញ ។ ចំពោះការហូបចុកវិញគឺហូបមួយថ្ងៃពីរពេល (បបរ ឬបាយ) ។ នៅទីនោះ វណ្ណា មិនដែលឃើញខ្មែរក្រហមយកមនុស្សទៅសម្លាប់ផ្ទាល់ភ្នែកទេ ធ្លាប់តែឮប៉ុណ្ណោះ ប៉ុន្តែគាត់គ្រាន់តែដឹងថា មានពាក្យថា "យកទៅរៀនសូត្រ" ហើយពាក្យនេះគឺស្មើនឹងយកទៅសម្លាប់ ។ ការរស់នៅបែកគ្នាពីបងប្អូន ឪពុកម្តាយពិតជាមានការលំបាកណាស់សម្រាប់ វណ្ណា ហេតុនេះ គាត់តែងតែប្រថុយជីវិតទៅជួបឪពុកម្តាយ បងប្អូន ព្រោះតែសេចក្តីនឹករឭកជាពន់ពេក ។ ពេលស្អាត់ជួបជាមួយបងប្អូនគាត់ ម្តងៗមិនដែលហ៊ាននិយាយអ្វីទេ គ្រាន់តែយកម្ហូបបន្តិចបន្តួចដែលគាត់រកបានទៅឲ្យ និងត្រឡប់មកវិញភ្លាម ។ ពេលកំពុងធ្វើការនៅក្នុងកងចល័ត អង្គការបានរៀបការឲ្យ វណ្ណា ដោយខ្លាចខ្មែរក្រហមយកទៅសម្លាប់គាត់ក៏យល់ព្រមរៀបការ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ វណ្ណា បានសុំបែកគ្នាពីប្តីដែលអង្គការផ្សំផ្គុំឲ្យទៅតាមផ្លូវរៀងៗខ្លួន ព្រោះគាត់មិនមានចិត្តស្រឡាញ់បុរសម្នាក់នោះទេ ។ ក្រោយថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ វណ្ណា បានត្រឡប់ទៅគ្រួសារវិញ ហើយក៏មិនបានវិលត្រឡប់មកភ្នំពេញវិញដែរ វណ្ណា និងគ្រួសារបានទៅរស់នៅក្នុងភូមិទៀន ក្នុងស្រុកកណ្តាលស្ទឹង ជាស្រុកកំណើតវិញ ។ នៅទីនោះ វណ្ណា បានធ្វើជាគ្រូបង្រៀន ។ ឆ្នាំ១៩៨០ ទើបមានការបង្កើតជាសាលារៀន វណ្ណា បានចូលបង្រៀននៅក្នុងសាលាបឋមសិក្សាមួយ ។ រហូតដល់ឆ្នាំ១៩៨២ គាត់មករៀនបន្តនៅសាលាគរុវិជ្ជាជាន់ខ្ពស់ និងបានបង្រៀននៅអនុវិទ្យាល័យកំពង់កន្ទួតនៅឆ្នាំ១៩៨៣ ផ្នែកអក្សរសាស្ត្រខ្មែរ ។ រហូតដល់ឆ្នាំ១៩៨៧ វណ្ណា បានដាក់ពាក្យមករៀនបន្តថ្នាក់បរិញ្ញាបត្រ ។ មកដល់ឆ្នាំ១៩៩១ គាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងធ្វើជាគ្រូបង្រៀននៅសាលកវិទ្យាល័យភូមិន្ទភ្នំពេញ រហូតមកដល់សព្វថ្ងៃនេះ ។

**អឿង ណារី**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# រឿងរ៉ាវរបស់យាយខ្ញុំ

យាយរបស់នាងខ្ញុំមានឈ្មោះ នូ សារឿន សព្វថ្ងៃអាយុ ៦៩ឆ្នាំ រស់នៅភូមិស្តៅ ឃុំក្រាំងស្វាយ ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ គាត់បានរៀបរាប់ថា កាលពីសម័យ លន់ នល់ គាត់ជាកសិករដែលមានជីវភាពមធ្យមនៅក្នុងភូមិ ។

មកដល់ឆ្នាំ១៩៧៤ គាត់បានឃើញមានយន្តហោះទម្លាក់គ្រាប់បែក និងរថក្រោះជាច្រើន ។ គាត់មានការភ័យតក់ស្លុតយ៉ាងខ្លាំង ដោយបានឃើញយន្តហោះទម្លាក់គ្រាប់នៅភូមិល្វាស្ទឹងស្លូត និងនៅម្តុំភូមិរបស់គាត់រស់នៅ ។ គាត់បន្តទៀតថា នៅពេលមានការទម្លាក់គ្រាប់ គាត់រួមជាមួយក្រុមគ្រួសាររត់ចូលលេណដ្ឋានដើម្បីគេចខ្លួន ។ គាត់និងគ្រួសារបានលាក់ខ្លួនរហូតដល់សភាពការណ៍ស្ងប់ស្ងាត់ទើបឡើងមកផ្ទះវិញ តែសម្ភារមួយចំនួនត្រូវបានបំផ្លាញ ។

មួយរយៈក្រោយមកខ្មែរក្រហមរំដោះបានភូមិ យាយរបស់ខ្ញុំក៏បានប្រមូលរបស់របរ ទ្រព្យសម្បត្តិ និង មាស ប្រគល់ជូនដល់អង្គការទាំងអស់ ។ ចំណែកគាត់ ត្រូវអង្គការបែងចែកឲ្យទៅធ្វើការនៅភូមិកាំភ្លើង ដែលជា ភូមិកំណើតខាងប្តី (ត្រូវជាតារបស់ខ្ញុំ) ។ នៅទីនោះ អង្គការបានចាត់តាំងគាត់ឲ្យធ្វើស្រែ លើកភ្លឺ និង ជីកប្រឡាយ ។ លុះដល់ឆ្នាំ១៩៧៥ គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះឃើញអង្គការជម្លៀសប្រជាជនយ៉ាងច្រើនមកដល់កន្លែងគាត់រស់នៅ ប៉ុន្តែមិនដឹងថាអ្នកទាំងនោះមកពីតំបន់ណាទេ ។ នៅពេលនោះ ប្រជាជនខ្លះបានស្លាប់ដោយសារការនឿយហត់ និងអត់អាហារ និងអ្នកខ្លះទៀតវង្វេងសាច់ញាតិ ។

មិនយូរប៉ុន្មាន អង្គការបានផ្លាស់យាយរបស់ខ្ញុំពីភូមិកាំភ្លើងឲ្យទៅនៅភូមិស្តៅវិញ ។ អង្គការបានចាត់តាំងឲ្យគាត់ត្បាញ ដោយមួយថ្ងៃផ្តល់របបអាហារឲ្យគាត់ពីរពេល តែមួយពេលៗគាត់ទទួលបានបបរមួយវែកប៉ុណ្ណោះ ។ ចំណែកជីតារបស់ខ្ញុំ អង្គការបញ្ជូនឲ្យទៅធ្វើស្រែ ជីកប្រឡាយ និងលើកភ្លឺស្រែ ។ ដោយសារតែការធ្វើការនឿយហត់ពេក និងការស្រេកឃ្លាន តារបស់ខ្ញុំបានលួចបេះស្លឹកផ្ទី យកមកស្ងោរលាយជាមួយអំបិលហូប ។

ពេលខ្លះ ជីតារបស់ខ្ញុំបានឃើញខ្មែរក្រហមយកក្មេងតូចៗទៅបោកផ្ទប់នឹងគល់រាំង និងយកដងចប ពូថៅ វាយសម្លាប់ជាដើម ។ ឃើញដូច្នេះ គាត់មានការភ័យខ្លាចយ៉ាងខ្លាំង និងខិតខំព្យាយាមធ្វើការដោយមិនហ៊ានរអ៊ូឡើយ ។ ក្រោយមក គាត់ត្រូវអង្គការចោទថា យួន និងបានបញ្ជាឲ្យគាត់ជីករណ្តៅ ដោយកុហកថាទុកសម្រាប់ដាក់ស្រូវ ។ ប៉ុន្តែសំណាងល្អ នៅពេលយប់ យាយរបស់ខ្ញុំឮសំឡេងរថក្រោះជាច្រើនបើកនៅលើផ្លូវ ។ នៅពេលនោះ ក៏ផ្ទុះការវាយប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម ជាមួយនឹងយោធាខ្មែរក្រហម ។

ឆ្លៀតឱកាសនោះ ខ្មែរក្រហមក៏បានកៀរប្រជាជនចេញ ដោយប្រាប់ថា ទៅកន្លែងមានសុវត្ថិភាព ។ តែពេលទៅដល់ស្រុកពាមរក៍ (ជាប់នឹងទន្លេអ្នកលឿង) គាត់ក៏បានរត់ទៅពួននៅគុម្ពោធព្រៃ ព្រោះភ័យខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោល ។ ចំណែកអ្នកខ្លះដែលជឿទៅតាមខ្មែរក្រហម ខ្មែរក្រហមបានវាយសម្លាប់ចោលអស់ជាច្រើននាក់នៅពេលទៅដល់កណ្តាលទន្លេ ។ គាត់មានការភ័យតក់ស្លុតយ៉ាងខ្លាំង ពេលគាត់ត្រឡប់មកភូមិវិញ ព្រោះនៅតាមផ្លូវគាត់ឃើញសាកសពជាច្រើន ។ នៅពេលមកដល់ភូមិ គាត់មិនចង់បានរបស់របរអ្វីក្រៅតែពីអង្ករនោះទេ ទោះបីក្នុងឃ្លាំងដែលខ្មែរក្រហមបោះបង់ចោលមានរបស់របរដែលគាត់អាចយកមកប្រើប្រាស់បានក៏ដោយ ។

គាត់បានបន្តថា គាត់បានរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ក៏ព្រោះតែថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ហើយគាត់ក៏នៅតែចាំមិនភ្លេចពីរបបសាហាវនេះ ។ គាត់មិនចង់ឲ្យរបបនេះកើតមានឡើងជាលើកទីពីរទេ ។

**យុន មុន្នីរ័ត្ន**

# ជីវិតក្នុងរបបខ្មែរក្រហម

អៀង អេង មានអាយុ៥៥ឆ្នាំ មានស្រុកកំណើតនៅភូមិដងគាល់ ក្រុងកែប ខេត្តកំពត ។ នៅក្នុងរបបខ្មែរក្រហម អេង ធ្វើការនៅកងយុវជន នៅភូមិព្រៃធំ ស្រុកកំពត ខេត្តកំពត ។

អេង រៀបរាប់ថា គាត់បានបែកពីឪពុកម្តាយ និងសាច់ញាតិរបស់គាត់ពីរឆ្នាំ មុនពេលរបបកម្ពុជាប្រជាធិបតេយ្យចូលមកដល់ ។ នៅពេលនោះ អេង ទើបតែមានអាយុ៩ឆ្នាំ ប៉ុណ្ណោះ និងកំពុងរៀននៅសាលា ។ លុះដល់ពេលខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនដែលរស់នៅទីក្រុងភ្នំពេញឲ្យទៅរស់នៅតាមទីជនបទ ។ ប៉ុន្តែ មុនដំបូងការរស់នៅប្រចាំថ្ងៃរបស់គាត់ មិនសូវជាលំបាកប៉ុន្មានទេ គឺប្រជាជននៅក្នុងភូមិរបស់គាត់អាចបរិភោគអាហារដែលខ្លួនមាន និងរកបាន ប៉ុន្តែមួយរយៈក្រោយមក អង្គការក៏ដាក់ផែនការយ៉ាងតឹងរ៉ឹងចំពោះការងារ និងត្បិតត្បៀតរបបអាហារទៅលើប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ។

ស្របពេលជាមួយនោះ ខ្មែរក្រហមជម្លៀស អេង ឲ្យទៅនៅក្តាត និងស្ទឹងកែវ ស្ថិតនៅខាងលិចខេត្តកំពត ។ ប៉ុន្តែរយៈពេលប្រហែលជាកន្លះខែ ក្រោយមកអង្គការបានឲ្យទៅនៅព្រៃធំ ។ នៅពេលនោះ អេង មានអាយុ១៥ឆ្នាំ គាត់ត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅកង យុវជន និងមានភារកិច្ច ជីកប្រឡាយ លើកទំនប់ ។ លើសពីនេះ អេង ទទួលការងារជីកអង្ករ ឬ ជីកស្រូវយកទៅកិននៅឯរោងកិនស្រូវបន្ថែមទៀត ។

នៅទីនោះបានមួយរយៈអង្គការបានផ្លាស់ អេង ឲ្យទៅធ្វើការនៅឯរោងចក្រស៊ីម៉ងត៍ ដែលមាន តាចេង គ្រប់គ្រង រហូតដល់កងទ័ពវៀតណាមចូលមករំដោះ ។

ចំពោះការហូបចុកប្រចាំថ្ងៃនៅក្នុងរោងចក្រស៊ីម៉ងត៍ អេង ទទួលបានអាហារចំនួនពីរពេលក្នុងមួយថ្ងៃ ហើយអាហារដែលគាត់ទទួលបាន គឺមានតែបាយលាយជាមួយពោត ។ នៅពេលខ្លះ មានអំបែងកញ្ចក់នៅលាយជាមួយបាយក៏មាន ដូច្នេះពេលហូបម្តងៗ អេង ត្រូវរើសគ្រាប់បាយម្តងមួយគ្រាប់ៗយកមកហូប ព្រោះគាត់ខ្លាចប៉ះចំអំបែង ។ ចំណែកស្ថានភាពការងារនៅក្នុងរោងចក្រនោះ ក៏មានការលំបាកខ្លាំងដែរ ព្រោះមានម៉ាស៊ីនតិចដែលធ្វើឲ្យអ្នកគ្រប់គ្រងប្រើកម្លាំងមនុស្សស្ទើរតែទាំងស្រុង ។ អ្នកជិតខាងនិងអ្នកធ្លាប់ស្គាល់ អេង ខ្លះបានស្លាប់ដោយអង្គការចាប់យកទៅសម្លាប់ និងខ្លះបាត់ខ្លួនដោយពុំមានមូលហេតុច្បាស់លាស់ នៅពេលដែលអ្នកទាំងនោះត្រឡប់មកពីសែងថ្ម និងវាយថ្មនៅរោងចក្រស៊ីម៉ងត៍ ។ ចំណែកអ្នកមួយចំនួនទៀត ស្លាប់ដោយសារការឆក់ខ្សែភ្លើង និង ដោយសារ ចូលម៉ាស៊ីនកិនស៊ីម៉ងត៍ ។

ក្រោយពីនោះ អេង ត្រូវបានអង្គការផ្លាស់ឲ្យទៅធ្វើការនៅខាងកិនស៊ីម៉ងត៍ និងដុតឥដ្ឋ ។ ក្រៅពីនោះ អេង ត្រូវអង្គការចាត់តាំងឲ្យយាមម៉ាស៊ីននៅរោងចក្រ ប្រាំមួយម៉ោងនៅពេលថ្ងៃ និងប្រាំមួយម៉ោង នៅពេលយប់ទៀត ដូច្នេះគាត់ដេកបានតែពីរទៅបីម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃ ។

នៅក្នុងរបបខ្មែរក្រហមកាន់កាប់ ការរស់នៅរបស់ អេង មានការលំបាក ដោយសារគ្មានអាហារគ្រប់គ្រាន់ ។ ប្រសិនក្នុងករណីប្រជាជនណាម្នាក់លួចបរិភោគអាហារជាលក្ខណៈឯកជន ហើយត្រូវអង្គការតាមទាន់ អង្គការនឹងយកអ្នកទាំងនោះទៅសម្លាប់ចោលមិនខាន ។ ជាក់ស្តែង អេង និងពូរបស់គាត់ត្រូវបានខ្មែរក្រហមយកទៅក្នុងគោលបំណងយកទៅសម្លាប់ចោល ប៉ុន្តែនៅពេលនោះ អេង បានតដៃ ហើយខ្មែរក្រហមបានបាញ់សម្លាប់ពូរបស់គាត់ ចំណែកគាត់ និងបងប្រុសរត់គេចខ្លួន និងរួចរស់រានមានជីវិតមកដល់សព្វថ្ងៃនេះ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ អេង បានត្រឡប់មករស់នៅភូមិ និងបានប្រកបមុខរបរធ្វើស្រែចម្ការវិញ ។

**សៀ ធី**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។




**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 172, April 2014 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.